ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIFRS 2

# ការទូទាត់ដោយផ្អែកលើ សន្លឹកប័ណ្ណភាគហ៊ុន

## Share-based Payment

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ **"ឈ្នះ-ឈ្នះ"** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣"**, **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨"**, **"យុទ្ធសាស្ត្រត្រីកោណ"**, **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០"** និង **"យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨"** ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី **"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា"** ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**” របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# **អារម្ភកថា**

៙

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ឋិ តាយី**

## កម្មវត្ថុ

១. កម្មវត្ថុនៃស.រ.ហ.អ នេះគឺដើម្បីកំណត់នូវការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នៅពេលអនុវត្តនូវ*ប្រត្តិការទូទាត់ ដោយផ្អែកតាមភាគហ៊ុន* ជាពិសេស ស្តង់ដាតម្រូវឱ្យឆ្លុះបញ្ចាំងទៅក្នុងប្រាក់ចំណេញ ឬការខាតបង់ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នូវរាល់ផលប៉ះពាល់នៃ*ប្រតិបត្តិការទូទាត់ដោយផ្អែកលើសន្លឹកប័ណ្ណភាគហ៊ុន* រួមទាំងចំណាយដែលជាប់ពាក់ព័ន្ធនឹងប្រត្តិការសិទ្ធិទិញភាគហ៊ុននាពេលអនាគតដែលបានផ្តល់ឱ្យនិយោជិត។

## វិសាលភាព

២. ក្រុមហ៊ុនត្រូវអនុវត្តនូវ ស.រ.ហ.អ នេះ សម្រាប់ការកត់ត្រាគណនេយ្យចំពោះ*ប្រត្តិការទូទាត់ដោយផ្អែកតាមគហ៊ុន* មិនថាក្រុមហ៊ុនអាច ឬមិនអាចកំណត់ជាក់លាក់នូវទំនិញ ឬសេវាកម្មមួយចំនួនដែលបានទទួល រួមមានៈ

(ក) *ប្រត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុនដោយទូទាត់ជាទ្រព្យម្ចាស់*

(ខ) *ប្រត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុនដោយទូទាត់ជាសាច់ប្រាក់* និង

(គ) ប្រតិបត្តិការដែលក្រុមហ៊ុនទទួល ឬទិញទំនិញ ឬសេវាកម្ម ហើយលក្ខខ័ណ្ឌនៃការព្រមព្រៀផ្តល់ឲ្យ ក្រុមហ៊ុន ឬអ្នកផ្គត់ផ្គង់ទំនិញ

ឬសេវាកម្មទាំងនោះមានជំរើសក្នុងការទូទាត់ជាសាច់ប្រាក់ (ឬទ្រព្យសម្បត្តិដ៏ទៃទៀត) ឬដោយចេញនូវឧបករណ៍ទ្រព្យម្ចាស់។

លើកលែងតែបានកត់សំគាល់ក្នុងកថាខ័ណ្ឌ ៣ក-៦។ ស.រ.ហ.អ នេះនឹងត្រូវអនុវត្តក្នុងករណីមិនមានទំនិញ ឬសេវាកម្មដែលអាចកំណត់បានជាក់លាក់ ហើយមានកាលៈទេសៈផ្សេងទៀតអាចបង្ហាញថាទំនិញ ឬសេវាកម្មត្រូវបាន (ឬនឹងត្រូវបាន) ទទួល។

៣. លប់ចេញ

៣ក *ប្រត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុន* អាចត្រូវបានទូទាត់ដោយក្រុម នៃក្រុមហ៊ុនផ្សេងទៀត(ឬដោយភាគហ៊ុនិករបស់ក្រុមនៃក្រុមហ៊ុនផ្សេងទៀត) តាងនាមឱ្យក្រុមហ៊ុនដែលទទួល ឬទិញទំនិញ ឬសេវាកម្ម។ កថាខ័ណ្ឌ២ក៏អនុវត្តផងដែរចំពោះ ក្រុមហ៊ុនដែល

(ក) ទទួលទំនិញ ឬសេវាកម្ម នៅពេលដែលក្រុមហ៊ុនដ៏ទៃក្នុងក្រុមដូចគ្នា (ឬដោយភាគហ៊ុនិករបស់ ក្រុមនៃក្រុមហ៊ុនផ្សេងទៀត) មានកាតព្វកិច្ចទូទាត់ប្រត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុន ឬ

(ខ) មានកាតព្វកិច្ច ដើម្បីទូទាត់ប្រត្តិការទូទាត់ ដោយផ្អែកតាមភាគហ៊ុន នៅពេលដែលក្រុមហ៊ុនផ្សេងទៀត ក្នុងក្រុមដូចគ្នាទទួលទំនិញ ឬសេវាកម្ម។

លើកលែងតែប្រតិបត្តិការមានគោលបំណងច្បាស់លាស់ក្រៅពីការបង់លើទំនិញ ឬសេវាកម្មដែលបាន ផ្គត់ផ្គង់ទៅឱ្យក្រុមហ៊ុនដែលទទួលទំនិញនិងសេវាកម្មនោះ។

៤. សម្រាប់គោលបំណងនៃ ស.រ.ហ.អ នេះ ប្រតិបត្តិការជាមួយនិយោជិត (ឬភាគីដ៏ទៃ) ក្នុងសមត្ថភាព របស់គាត់ជាម្ចាស់នៃឧបករណ៍ទ្រព្យម្ចាស់

របស់អង្គភាពមិនមែនជា*ប្រត្តិការបង់ដោយផ្អែកតាមភាគហ៊ុន*។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនផ្តល់ឱ្យអ្នកកាន់កាប់ថ្នាក់នៃឧបករណ៍ទ្រព្យម្ចាស់ពិសេស នូវសិទ្ធិដើម្បីទទួលបាននូវឧបករណ៍ទ្រព្យម្ចាស់បន្ថែម នៅក្នុងតំលៃ ដែលទាបជាងតំលៃសមស្របរបស់ឧបករណ៍ទ្រព្យម្ចាស់ទាំងនោះ ហើយនិយោជិត បានទទួលសិទ្ធិនេះ ពីព្រោះគាត់ជាអ្នកកាន់កាប់ នូវឧបករណ៍ទ្រព្យម្ចាស់នៃថ្នាក់ពិសេស ដូចនេះការផ្តល់ និងការអនុវត្តន៍នូវសិទ្ធិ មិនស្ថិតក្នុងប្រធានបទនៃស្តង់ដានេះទេ។

៥. ដូចដែលមានចែងក្នុងកថាខ័ណ្ឌ២ ស្តង់ដានេះប្រើប្រាស់ ចំពោះប្រត្តិការបង់ដោយផ្អែកតាមភាគហ៊ុនដែលក្រុមហ៊ុនបានទទួលទំនិញនិងសេវាកម្ម។ ទំនិញរួមមានសន្និធិ វត្ថុប្រើប្រាស់ ទ្រព្យ រោងចក្រ និងបរិក្ខារ ទ្រព្យសម្បត្តិអរូបី ព្រមទាំងទ្រព្យសម្បត្តិមិនមែនហិរញ្ញវត្ថុដ៏ទៃទៀត។ ប៉ុន្តែ ក្រុមហ៊ុនមិនត្រូវអនុវត្តស្តង់ដានេះ ចំពោះប្រតិបត្តិការ ដែលក្រុមហ៊ុនទិញទំនិញ ដែលជាផ្នែកមួយនៃ ទ្រព្យសម្បត្តិសុទ្ធដែលបានទទួលក្នុងការរួមបញ្ចូលអាជីវកម្ម ដូចមានចែងក្នុង ស.រ.ហ.អ ៣ *ការរួមបញ្ចូលអាជីវកម្ម* (ដែលបានកែសម្រួលឡើងវិញឆ្នាំ ២០០៨) ក្នុងការរួមបញ្ចូលនូវក្រុមហ៊ុន ឬអាជីវកម្មដែលស្ថិតនៅក្រោមការគ្រប់គ្រងរួមដូចមានចែងក្នុងកថាខណ្ឌ ខ១-ខ៤ នៃស.រ.ហ.អ ៣ ឬការរួម ចំណែកនៃអាជីវកម្មលើការបង្កើតនូវក្រុមហ៊ុនរួមទុន ដូចដែលបានកំណត់ន័យក្នុង ស.គ.អ ៣១ *ភាគកម្មក្នុងក្រុមហ៊ុនរួមទុន*។ ដូច្នេះ ឧបករណ៍ទ្រព្យម្ចាស់ដែលបានបោះផ្សាយក្នុងការរួមបញ្ចូលអាជីវកម្ម ដើម្បីដោះដូរនូវការគ្រប់គ្រងរបស់អ្នកលក់ មិនស្ថិតក្នុង វិសាលភាពនៃស្តង់ដានេះទេ។ ប៉ុន្តែឧបករណ៍ ទ្រព្យម្ចាស់ ដែលបានផ្តល់ឱ្យនិយោជិតរបស់អ្នកលក់ក្នុងសមត្ថភាពជានិយោជិត (ឧ. សម្រាប់

ការដោះដូរ នឹងការបន្តការងារ) ត្រូវស្ថិតក្នុងស្តង់ដានេះ។ ស្រដៀងគ្នានេះដែរ ការលប់ចេញ ការជំនួស ឬការកែប្រែ នូវការព្រមព្រៀងទូទាត់តាមភាគហ៊ុនដោយសារតែការរួមបញ្ចូលអាជីវកម្ម ឬការកែទំរង់ទ្រព្យម្ចាស់ត្រូវអនុលោមតាមស.រ.ហ.អ នេះ។ ស.រ.ហ.អ ៣ ផ្តល់នូវការណែនាំលើការកំណត់ថាតើ ឧបករណ៍ទ្រព្យម្ចាស់ដែលបានបោះផ្សាយក្នុងការរួមបញ្ចូលអាជីវកម្ម ដែលជាផ្នែកមួយនៃតំលៃតបស្នងបានផ្ទេរ ជាការដោះដូរនូវការគ្រប់គ្រងរបស់ អ្នកលក់ (ដូច្នេះ ស្ថិតនៅក្រោមវិសាលភាព នៃស.រ.ហ.អ៣) ឬដើម្បីទទួលមកវិញនូវការបន្តការងារ ដែលត្រូវបានទទួលស្គាល់នៅក្រោយកំឡុងពេលរួមបញ្ចូលគ្នា (ដូច្នេះស្ថិតនៅក្រោមវិសាលភាពនៃស.រ.ហ.អ នេះ)។

៦ ស.រ.ហ.អ នេះមិនអនុវត្តចំពោះប្រតិបត្តិការទូទាត់ ដោយប្រើសន្លឹកភាគហ៊ុន ដែលក្រុមហ៊ុនទទួល ឬទិញ ទំនិញ ឬសេវាកម្ម ស្ថិតនៅក្រោមកិច្ចសន្យាដូចមានក្នុងវិសាលភាពនៃ កថាខ័ណ្ឌ៨-១០ នៃស.គ.អ ៣២ *ឧបករណ៍ហិរញ្ញវត្ថុ: ការបង្ហាញ* (បានកែសម្រួលឡើងវិញ ឆ្នាំ២០០៣*) ឬកថាខ័ណ្ឌ ៥-៧ នៃ ស.គ.អ ៣៩ *ឧបករណ៍ហិរញ្ញវត្ថុ: ការទទួលស្គាល់ និងការវាស់វែង* (បានកែសម្រួលឡើងវិញ ឆ្នាំ២០០៣)។

## ការទទួលស្គាល់

**៧ ក្រុមហ៊ុនត្រូវទទួលស្គាល់ទំនិញ ឬសេវាកម្មដែលបានទទួល ឬទិញក្នុងប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន នៅពេលដែលក្រុមហ៊ុនទទួលបាននូវទំនិញ ឬសេវាកម្មត្រូវបានទទួល។ ក្រុមហ៊ុនត្រូវទទួលស្គាល់ នូវការកើន**

* ចំណងជើងនៃស.គ.អ ៣២ បានផ្លាស់ប្តូរក្នុងឆ្នាំ២០០៥

**ឡើងក្នុងទ្រព្យម្ចាស់ ប្រសិនបើទំនិញ ឬសេវាកម្មត្រូវបានទទួល នៅក្នុងប្រតិបត្តិការទូទាត់ដោយផ្អែកតាភាគហ៊ុនដែលទូទាត់ជាទ្រព្យម្ចាស់ ឬកើនឡើងក្នុងបំណុលប្រសិនបើទំនិញ ឬសេវាកម្មត្រូវ បានទទួលនៅក្នុងប្រតិបត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុនដោយទូទាត់ជាសាច់ប្រាក់។**

៨ **នៅពេលទំនិញ និងសេវាកម្មបានទទួល ឬបានទិញនៅក្នុងប្រត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុនមិនសមស្របក្នុងការទទួលស្គាល់ជាទ្រព្យសម្បត្តិទេ ដូច្នេះត្រូវទទួលស្គាល់ជាចំណាយ។**

៩ ជាទូទៅ ការចំណាយកើតឡើងពីការប្រើប្រាស់ នូវទំនិញ ឬសេវាកម្ម ឧទាហរណ៍ សេវាកម្មជាទូទៅត្រូវ បានប្រើប្រាស់ភ្លាមៗ។ ទំនិញអាចត្រូវបានប្រើប្រាស់ក្នុងកំឡុងពេលមួយ ឬក្នុងករណីរបស់សន្និធិ ត្រូវបានលក់ក្នុងកាលបរិច្ឆេទបន្ទាប់ ដែលក្នុងពេលនេះ ត្រូវកត់ត្រាទទួលស្គាល់ជាចំណាយនៅពេលទំនិញត្រូវបានប្រើប្រាស់ ឬលក់។ ប៉ុន្តែពេលខ្លះ ដោយសារតែវាមិនសមស្រប ក្នុងការទទួលស្គាល់ជាទ្រព្យសម្បត្តិ ចាំបាច់ត្រូវទទួលស្គាល់ជាចំណាយមុនពេលទំនិញ ឬសេវាកម្មបានប្រើប្រាស់ ឬលក់ ឧទាហរណ៍ ក្រុមហ៊ុនមួយអាចទិញនូវទំនិញ ដែលជាផ្នែកមួយនៃដំណាក់កាលស្រាវជ្រាវរបស់គំរោងមួយដើម្បីបង្កើតផលិតផលថ្មី ទោះបីជាទំនិញទាំងនោះមិនត្រូវបានប្រើប្រាស់ ក៏វាមិនសមស្របក្នុងការទទួលស្គាល់ជាទ្រព្យសម្បត្តិតាមស.រ.ហ.អ ដែលអាចអនុវត្តបាន។

**ប្រត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុនទូទាត់ជាទ្រព្យម្ចាស់**

**ទិដ្ឋភាពទូទៅ**

១០ **ចំពោះប្រត្តិការទូទាត់ដោយផ្អែកតាមភាគហ៊ុនដែលទូទាត់ជាទ្រព្យម្ចាស់ ក្រុមហ៊ុនត្រូវវាស់វែងនូវទំនិញ ឬសេវាកម្មដែលបានទទួល ព្រមទាំងការកើនឡើងនៃទ្រព្យម្ចាស់ ដោយផ្ទាល់តាមតំលៃសមស្របរបស់ ទំនិញ ឬសេវាកម្មដែលបានទទួល លើកលែងតែតំលៃសមស្របមិនអាចវាស់វែងបានគួរឱ្យជឿជាក់។ ប្រសិនបើក្រុមហ៊ុនមិនអាចប៉ាន់ស្មានគួរឱ្យជឿជាក់នូវតំលៃសមស្របរបស់ទំនិញ ឬសេវាកម្មដែលបាន ទទួល ក្រុមហ៊ុនត្រូវវាស់វែងនូវតំលៃរបស់វា ព្រមទាំងការកើនឡើងនៃទ្រព្យម្ចាស់ ដោយប្រយោល តាមការយោងតាម[1] តំលៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុដែលបានផ្តល់។**

១១ ដើម្បីអនុវត្តនូវ កថាខណ្ឌ១០ ចំពោះប្រតិបត្តិការជាមួយ*និយោជិត និងអ្នកដ៏ទៃដែលផ្តល់សេវា[2] ប្រហាក់ប្រហែល* ក្រុមហ៊ុនត្រូវវាស់វែងនូវតំលៃសមស្របនៃសេវាកម្ម ដែលបានទទួល ដោយយោងតាមតំលៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុដែលបានផ្តល់ ដោយសារតែជាទូទៅវាមិនអាចធ្វើការវាស់វែងគួរឱ្យជឿ ជាក់នូវតំលៃសមស្របនៃសេវាកម្ម ដែលបានទទួល ដូចដែលមានពន្យល់ក្នុងកថាខ័ណ្ឌ១២។ តំលៃសមស្រប នៃឧបករណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានវាស់វែងនាថ្ងៃដែលបានផ្តល់។

---

[1] ស.រ.ហ.អ ប្រើប្រាស់នូវពាក្យ “យោងដល់” ជាជាងពាក្យ “នា” ពីព្រោះប្រតិបត្តិការត្រូវបានវាស់វែងចុងក្រោយដោយគុណតំលៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ ដែលបានផ្តល់វាស់វែងនាកាលបរិច្ឆេទដែលបានបញ្ជាក់ក្នុង កថាខ័ណ្ឌ១១ ឬ១៣ (មួយណាដែលអាចអនុវត្តបាន) ជាមួយនឹងចំនួននៃឧបករណ៍ហិរញ្ញ វត្ថុដែលផ្ទេរឱ្យ

[2] ផ្នែកដែលនៅសល់នៃស្តង់ដារនេះ រាល់ការយោងចំពោះពាក្យនិយោជិតរួមមានអ្នកដ៏ទៃដែលផ្តល់សេវាប្រហាក់ប្រហែល

១២ ជាទូទៅ ប័ណ្ណភាគហ៊ុន សិទ្ធិក្នុងការទិញភាគហ៊ុន នាពេលអនាគត ឬឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀត បានផ្តល់ឱ្យនិយោជិត ដែលជាផ្នែកមួយនៃកញ្ចប់លាភការបន្ថែមទៅលើប្រាក់ខែជាសាច់ប្រាក់ និងអត្ថប្រយោជន៍នៃការបំរើការងារដ៏ទៃទៀត។ ជាធម្មតា គេមិនអាចធ្វើការវាស់វែងដោយផ្ទាល់នូវសេវាកម្ម ដែលបានទទួលសម្រាប់សមាសធាតុជាក់លាក់នៃកញ្ចប់លាភការនិយោជិត ហើយគេក៏មិនអាចធ្វើការវាស់ វែងនូវតំលៃសមស្របនៃកញ្ចប់លាភការសុរុបដាច់ដោយឡែកពីគ្នា ដោយមិនវាស់វែង ដោយផ្ទាល់នូវ តំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់បានទេ។ ម្យ៉ាងទៀតភាគហ៊ុន ឬសិទ្ធិក្នុងការទិញភាគហ៊ុននាពេលអនាគត ត្រូវបានផ្តល់ជាផ្នែកមួយនៃគំរោងការប្រាក់លើកទឹកចិត្ត ជាជាងជាផ្នែកមួយនៃការផ្តល់លាភការជាមូលដ្ឋាន ឧ. ជាការលើកទឹកចិត្តដល់និយោជិតក្នុងការបន្តការងារក្នុងក្រុមហ៊ុន ឬដើម្បីផ្តល់រង្វាន់ពួកគេ ចំពោះកិច្ចខិប្រឹងប្រែងក្នុងការ ធ្វើឱ្យប្រសើរនូវការអនុវត្តការងាររបស់ក្រុមហ៊ុន តាមរយៈការផ្តល់នូវប័ណ្ណភាគហ៊ុន ឬសិទ្ធិក្នុងការទិញភាគហ៊ុននាពេលអនាគត បន្ថែមទៅលើលាភការដ៏ទៃទៀត ក្រុមហ៊ុនកំពុងបង់នូវលាភការបន្ថែមដើម្បីទទួលបាន នូវអត្ថប្រយោជន៍បន្ថែម។ ការប៉ាន់ស្មាន នូវតំលៃសមស្រប នៃអត្ថប្រយោជន៍បន្ថែមទាំងនេះគឺមានការលំបាក ដោយសារតែភាពលំបាកនៃការវាស់ វែងដោយផ្ទាល់នូវតំលៃសមស្របនៃសេវាកម្មដែលបានទទួលក្រុមហ៊ុន ត្រូវវាស់វែងតំលៃសមស្រប នៃសេវាកម្មនិយោជិតដែលបានទទួលដោយយោងលើតំលៃសមស្រប នៃឧបករណ៍ហិរញ្ញវត្ថុ ដែលបានផ្តល់។

១៣ ដើម្បីអនុវត្តនូវលក្ខខ័ណ្ឌតំរូវនៃកថាខ័ណ្ឌ ១០ ចំពោះប្រតិបត្តិការជាមួយភាគីក្រៅពីនិយោជិត នឹងត្រូវមានការសន្មតថាតំលៃសមស្របនៃទំនិញ ឬសេវាកម្មបានទទួលអាចវាស់វែងបានគួរឱ្យជឿជាក់។ តំលៃសមស្រប នឹងត្រូវបានវាស់វែង នាថ្ងៃដែលក្រុមហ៊ុនទទួលទំនិញ ឬភាគីដៃគូផ្តល់សេវាកម្ម។ ក្នុងករណីកំរ ប្រសិនបើក្រុមហ៊ុនមិនមានការសន្មតនេះ ដោយសារតែគេមិនអាចប៉ាន់ស្មានគួរឱ្យជឿជាក់ នូវតំលៃសមស្រប នៃទំនិញ ឬសេវាកម្មដែលបានទទួល ព្រមទាំងការកើនឡើងនូវទ្រព្យម្ចាស់ដោយប្រយោល ដោយយោងលើតំលៃសមស្រប នៃឧបករណ៍ហិរញ្ញវត្ថុបានផ្តល់ការវាស់វែងនាថ្ងៃ ដែលក្រុមហ៊ុនទទួលទំនិញ ឬភាគីដៃគូផ្តល់សេវាកម្ម។

១៣ក ជាពិសេស ប្រសិនបើតំលៃតបស្នង ដែលអាចកំណត់បាន បានទទួល (ប្រសិនបើមាន) ដោយក្រុមហ៊ុន បង្ហាញថាតិចជាងតំលៃសមស្រប នៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ ឬបំណុល ដែលបានកើតឡើង ជាទូទៅស្ថានភាពនេះ បង្ហាញថាតំលៃតបស្នងផ្សេងទៀត(ដូចជាទំនិញ ឬសេវាកម្មដែលមិនអាចកំណត់បាន) បានត្រូវ (ឬនឹងត្រូវ)ទទួលដោយក្រុមហ៊ុន។ ក្រុមហ៊ុននឹងវាស់វែងនូវទំនិញ ឬសេវាកម្ម អាចកំណត់បាន ដែលបានទទួល ដោយអនុលោមតាមស.រ.ហ.អ នេះ។ ក្រុមហ៊ុនវាស់វែងនូវទំនិញ ឬសេវាកម្មមិនអាច កំណត់បាន ដែលបានទទួល (ឬនឹងត្រូវទទួល) ជាភាពខុសគ្នារវាងតំលៃសមស្របនៃការទូទាត់ផ្អែកតាម ប័ណ្ណភាគហ៊ុន និងតំលៃសមស្របនៃទំនិញ ឬសេវាកម្មអាចកំណត់បាន ដែលបានទទួល (ឬនឹងត្រូវទទួល)។ ក្រុមហ៊ុនវាស់វែងនូវទំនិញ ឬសេវាកម្មមិនអាចកំណត់បានដែលបានទទួល នាថ្ងៃដែលត្រូវបានផ្តល់ឱ្យ។ ក៏ប៉ុន្តែ សម្រាប់

ប្រតិបត្តិការទូទាត់ជាសាច់ប្រាក់ បំណុលត្រូវបានវាស់វែងសារជាថ្មីនាចុង គ្រា រាយការណ៍នីមួយៗ រហូតដល់វាត្រូវបានទូទាត់ដូចមានចែង ក្នុង កថាខណ្ឌ ៣០-៣៣។

## ប្រតិបត្តិការដែលសេវាកម្មត្រូវបានទទួល

១៤ ភាគីដៃគូ មិនតំរូវឱ្យបំពេញនូវរយៈពេលជាក់លាក់នៃសេវាកម្មមុនពេល ក្លាយជាមានសិទ្ធិដោយគ្មានលក្ខខណ្ឌចំពោះឧបករណ៍ទ្រព្យម្ចាស់ទាំងនោះ ប្រសិនបើ ឧបករណ៍ទ្រព្យម្ចាស់ផ្តល់ឱ្យ*ផ្ទេរ*ភ្លាមៗ។ ក្នុងករណីមិនមាន ភស្តុតាងផ្ទុយពីនេះ ក្រុមហ៊ុនត្រូវសន្មតថាសេវាកម្ម ដែលបានផ្តល់ឱ្យ ដោយភាគីដៃគូជាតំលៃតបស្នងរបស់ឧបករណ៍ទ្រព្យម្ចាស់ដែលបានទទួល ក្នុងករណីនេះ នៅថ្ងៃដែលបានផ្តល់ក្រុមហ៊ុនត្រូវទទួលស្គាល់ថាសេវាកម្ម បានទទួលទាំងអស់ ដោយឆ្លើយតបទៅនឹងការកើនឡើងនូវទ្រព្យម្ចាស់។

១៥ ក្រុមហ៊ុនត្រូវសន្មតថាសេវាកម្មនឹងត្រូវបានផ្តល់ដោយភាគីដៃគូជាតំលៃ តបស្នងសម្រាប់ ឧបករណ៍ទ្រព្យម្ចាស់ដែលនឹង ត្រូវបានទទួលនាពេល អនាគតក្នុងកំឡុងពេលនៃការផ្ទេរនេះប្រសិនបើឧបករណ៍ទ្រព្យម្ចាស់ដែល បានផ្តល់មិនបាន*ផ្ទេរ* រហូតដល់ភាគីដៃគូបានបំពេញនូវរយៈពេលជាក់នៃ សេវាកម្ម។ ក្រុមហ៊ុនត្រូវកត់ត្រាសេវាកម្មទាំងនោះដូចដែលបានផ្តល់ឱ្យ ដោយភាគីដៃគូក្នុងកំឡុងពេលនៃការផ្ទេរ ដែលឆ្លើយ តបដោយមានការ កើនឡើងនៃទ្រព្យម្ចាស់។ ឧទាហរណ៍:

(ក) ប្រសិនបើ និយោជិត ត្រូវបានផ្តល់នូវសិទ្ធិ នៃការទិញភាគហ៊ុន នាពេលអនាគតដោយមានលក្ខខណ្ឌ ថាបានបញ្ចប់នូវការបំពេញ សេវាកម្មចំនួន៣ឆ្នាំ ដូចនេះក្រុមហ៊ុនត្រូវសន្មតថាសេវាកម្មដែល

បានផ្តល់ដោយនិយោជិតជាតំលៃតបស្នងសម្រាប់សិទ្ធិនៃការទិញភាគហ៊ុន នាពេលអនាគត ដែលនឹងត្រូវបានទទួល នាពេលអនាគត ក្នុងកំឡុងពេលនៃការផ្ទេរទាំង៣ឆ្នាំនេះ។

(ខ) ប្រសិនបើនិយោជិតត្រូវបានផ្តល់នូវសិទ្ធិនៃការទិញភាគហ៊ុន នាពេលអនាគត ដោយមានលក្ខខណ្ឌ ថាបានសម្រេចនូវលក្ខខណ្ឌនៃការអនុវត្តការងារមួយ ព្រមទាំងបន្តធ្វើការក្នុងក្រុមហ៊ុនរហូតដល់ លក្ខខណ្ឌនៃការអនុវត្តន៍ការងារនេះត្រូវបានពេញចិត្ត ហើយចំនួនរយៈពេលនៃការផ្ទេរ ខុសៗគ្នា អាស្រ័យទៅនឹងពេលដែលលក្ខខណ្ឌនៃការអនុវត្តន៍ការងារនេះត្រូវបានពេញចិត្ត ក្រុមហ៊ុនត្រូវសន្មតថា សេវាកម្មដែលនឹងត្រូវបានផ្តល់ដោយនិយោជិតដូចជាតំលៃតបស្នង សម្រាប់សិទ្ធិនៃការទិញភាគហ៊ុន នាពេលអនាគត នឹងត្រូវបានទទួលនាអនាគត តាមកំឡុងពេលនៃការផ្ទេរដែលបាន រំពឹងទុក។ ក្រុមហ៊ុនត្រូវប៉ាន់ស្មាននូវថេរវេលានៃរយៈពេលនៃការផ្ទេរដែលបានរំពឹងទុកនាថ្ងៃផ្តល់ ដោយផ្អែកលើលទ្ធផលប្រសើរបំផុតនៃលក្ខខណ្ឌការអនុវត្តន៍ការងារ។ ប្រសិនបើលក្ខខណ្ឌនៃការ អនុវត្តការងារជា*លក្ខខណ្ឌទីផ្សារ* នោះការប៉ាន់ស្មាននូវថេរវេលានៃរយៈពេលនៃការផ្ទេរដែលបានរំពឹងទុកត្រូវសង្គតភាពជាមួយការសន្មតដែលបានប្រើប្រាស់ក្នុងការប៉ាន់ស្មាននូវតំលៃសមស្របនៃ សិទ្ធិទិញនាពេលអនាគត ដែលបានផ្តល់ ហើយនឹងមិនត្រូវមានការពិនិត្យមើលឡើងវិញពេលក្រោយទេ។ ប្រសិនបើ លក្ខខណ្ឌនៃការអនុវត្តន៍មិនមែនជាលក្ខខណ្ឌទីផ្សារ ក្រុមហ៊ុនត្រូវពិនិត្យមើលឡើងវិញនូវថេរវេលានៃរយៈពេល

នៃការផ្ទេរដែលបានរំពឹងទុក បើចាំបាច់ប្រសិនបើព័ត៌មានពេលក្រោយបង្ហាញថាថេរវេលានៃរយៈពេលនៃការផ្ទេរខុសពីការប៉ាន់ស្មានកន្លងមក។

## ប្រតិបត្តិការវាស់វែងដោយយោងតាមតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់

### ការកំណត់នូវតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់

១៦ ចំពោះប្រតិបត្តិការវាស់វែងដោយយោងតាមតំលៃសមស្រប នៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ ក្រុមហ៊ុន ត្រូវវាស់វែងតំលៃសមស្រប នៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ នាថ្ងៃដែលធ្វើការវាស់វែង ដោយផ្អែកលើតំលៃទីផ្សារបើអាចរកបាន ដោយគិតគូនូវរយៈពេល និងលក្ខខណ្ឌ ដែលកើតមានពេលឧបករណ៍ទ្រព្យម្ចាស់ទាំងនោះបានផ្តល់ (អាស្រ័យតាម លក្ខខណ្ឌតម្រូវនៃកថាខណ្ឌ ១៩-២២)។

១៧ ប្រសិនបើតំលៃទីផ្សារមិនអាចរកបាន ក្រុមហ៊ុនត្រូវប៉ាន់ស្មាន នូវតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ ដោយប្រើវិធីការ វាយតំលៃដើម្បីប៉ាន់ស្មានពីតំលៃ ដែលឧបករណ៍ទ្រព្យម្ចាស់អាចមាននាថ្ងៃ ដែលធ្វើការវាស់វែងក្នុងប្រតិបត្តិការស្មើភាពរវាងភាគីដែលមានបំណងនិងមានចំណេះដឹង។ វិធីសាស្រ្ត វាយតំលៃត្រូវស្របជាមួយនឹងវិធីសាស្រ្តវាយតំលៃដែលគេទទួលស្គាល់ជាទូទៅ សម្រាប់ការកំណត់ថ្លៃនៃ ឧបករណ៍ហិរញ្ញវត្ថុ និងត្រូវរួមបញ្ចូលនូវរាល់លក្ខខណ្ឌ និងការសន្មតទាំងអស់ដែលអ្នកចូលរួមមានបំណង និងអាចដឹងបាន នឹងត្រូវយកមកពិចារណាក្នុងការកំណត់ថ្លៃ (អាស្រ័យតាមលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ ១៩-២២)។

១៨ ឧបសម្ព័ន្ធខ រួមមានការណែនាំបន្ថែមស្តីពីការវាស់វែងតំលៃសមស្របនៃភាគហ៊ុន និងសិទ្ធិនៃការទិញភាគហ៊ុននាពេលអនាគត ដោយផ្តោតលើរយៈពេល និងលក្ខខណ្ឌជាក់លាក់ ដែលជាលក្ខណៈរួម នៃការផ្តល់ភាគហ៊ុន និងសិទ្ធិនៃការទិញភាគហ៊ុននាពេលអនាគតដល់និយោជិត។

## ប្រព្រឹត្តកម្មនៃលក្ខខណ្ឌផ្ទេរ

១៩ ការផ្តល់ឧបករណ៍ទ្រព្យម្ចាស់អាចកើតឡើង ដោយមានលក្ខខណ្ឌតាមការពេញចិត្តនៃលក្ខខណ្ឌផ្ទេរជាក់លាក់ ឧទាហរណ៍ ការផ្តល់ភាគហ៊ុន និងសិទ្ធិនៃការទិញភាគហ៊ុន នាពេលអនាគតទៅកាន់និយោជិត គឺជាទូទៅមានលក្ខខណ្ឌតាមការនៅបន្តបំពេញការងាររបស់និយោជិតក្នុងកំឡុងពេលមួយជាក់លាក់ វាអាចមានជាលក្ខខណ្ឌនៃការអនុវត្តដែលត្រូវបំពេញ ដូចជាការសំរេចបាននូវកំណើនជាក់លាក់នៃប្រាក់ចំណេញរបស់ក្រុមហ៊ុន ឬការកើនឡើងជាក់លាក់នៃថ្លៃភាគហ៊ុនរបស់ក្រុមហ៊ុនជាដើម។ លក្ខខណ្ឌផ្ទេរ ក្រៅពីលក្ខខណ្ឌទីផ្សារ មិនត្រូវបានយកមកគិតនៅពេលប៉ាន់ស្មានតំលៃសមស្រប នៃភាគហ៊ុន និងសិទ្ធិនៃការទិញភាគហ៊ុននាពេលអនាគតនៅថ្ងៃធ្វើការវាស់វែង ជំនួសមកវិញលក្ខខណ្ឌផ្ទេរត្រូវយកមកគិតដោយធ្វើការកែតម្រូវចំនួននៃឧបករណ៍ទ្រព្យម្ចាស់ ដែលបានរួមបញ្ចូលទៅក្នុងការវាស់វែងចំនួនប្រតិបត្តិការ ដូច្នេះជាចុងក្រោយចំនួនដែលបានទទួលស្គាល់ជាទំនិញ ឬសេវាកម្មជាតំលៃតបស្នងនៃឧបករណ៍ទ្រព្យម្ចាស់ ដែលបានផ្តល់ត្រូវផ្អែកលើចំនួននៃឧបករណ៍ទ្រព្យម្ចាស់ដែលត្រូវផ្ទេរ។ ហេតុនេះតាមមូលដ្ឋានបង្គរ មិនមានចំនួនណានៃទំនិញ ឬសេវាកម្ម បានទទួលត្រូវបានទទួលស្គាល់ប្រសិនបើឧបករណ៍ទ្រព្យម្ចាស់បានផ្តល់មិនត្រូវបាន

ផ្ទេរដោយសារបរាជ័យក្នុងការបំពេញលក្ខខណ្ឌនៃការផ្ទេរ ឧ.ភាគីដៃគូមិនអាចបំពេញនូវកំឡុងពេលសេវាកម្មជាក់លាក់ ឬលក្ខខណ្ឌនៃការអនុវត្តន៍មិនត្រូវបានពេញចិត្ត តាមលក្ខខណ្ឌតំរូវនៃកថាខណ្ឌ២១។

២០ ដើម្បីអនុវត្តលក្ខខណ្ឌតំរូវនៃកថាខ័ណ្ឌ១៩ ក្រុមហ៊ុនត្រូវទទួលស្គាល់ចំនួននៃទំនិញ ឬសេវាកម្មបានទទួល ក្នុងកំឡុងពេលនៃការផ្ទេរ ដោយផ្អែកលើការប៉ាន់ស្មានប្រសើរបំផុតលើចំនួននៃឧបករណ៍ទ្រព្យម្ចាស់ ដែលរំពឹងថានឹងត្រូវផ្ទេរ ព្រមទាំងត្រូវពិនិត្យឡើងវិញនូវការប៉ាន់ស្មាន ប្រសិនបើចាំបាច់ ប្រសិនបើព័ត៌មានពេលក្រោយបង្ហាញថាថេរវេលានៃរយៈពេលនៃការផ្ទេរខុសពីការប៉ាន់ស្មានកន្លងមក។ នាថ្ងៃផ្ទេរ ក្រុមហ៊ុន ត្រូវពិនិត្យឡើងវិញនូវការប៉ាន់ស្មានឱ្យស្មើនឹងចំនួននៃឧបករណ៍ទ្រព្យម្ចាស់ដែលនឹងត្រូវផ្ទេរតាមលក្ខខណ្ឌតំរូវនៃកថាខណ្ឌ២១។

២១ លក្ខខណ្ឌទីផ្សារ ដូចជាទិសដៅថ្លៃសន្លឹកប័ណ្ណភាគហ៊ុន ដែលការផ្ទេរ (ឬភាពអាចអនុវត្តបាន) មានលក្ខខណ្ឌ ត្រូវគិតគូនៅពេលដែលការប៉ាន់ស្មាននូវតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់។ ដូច្នេះចំពោះការផ្តល់ឧបករណ៍ទ្រព្យម្ចាស់ដែលមានលក្ខខណ្ឌទីផ្សារ ក្រុមហ៊ុនត្រូវទទួលស្គាល់ទំនិញឬសេវាកម្មបានទទួលពីភាគីដៃគូ ដែលបានបំពេញនូវរាល់លក្ខខណ្ឌនៃការផ្ទេរទាំងឡាយ (ឧទាហរណ៍ សេវា កម្មបានទទួលពីនិយោជិត ដែលបន្តនៅធ្វើការក្នុងកំឡុងគ្រាសេវាកម្មមួយជាក់លាក់) ដោយមិនគិតថាតើលក្ខខណ្ឌទីផ្សារត្រូវបានបំពេញដែរឬទេ។

### ប្រព្រឹត្តកម្មនៃលក្ខខណ្ឌនៃការមិនផ្ទេរ

២២ ស្រដៀងគ្នានេះដែរ ក្រុមហ៊ុនត្រូវគិតគូទូវរាល់លក្ខខណ្ឌ នៃការមិនផ្ទេរទាំងអស់ នៅពេលប៉ាន់ស្មានទូវ តំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់។ ដូច្នេះសម្រាប់ការផ្តល់ឧបករណ៍ទ្រព្យម្ចាស់ដែលមានលក្ខខណ្ឌមិនផ្ទេរ ក្រុមហ៊ុនត្រូវទទួលស្គាល់ទំនិញ ឬសេវាកម្មដែលបានទទួលពីភាគីដៃគូ ដែលបំពេញបានលក្ខខណ្ឌ នៃការផ្ទេរទាំងអស់ ដែលមិនមែនជាលក្ខខណ្ឌទីផ្សារ (ឧទាហរណ៍ សេវាកម្មបានទទួលពីនិយោជិតដែលបន្តនៅធ្វើការ ក្នុងកំឡុងគ្រាសេវាកម្មមួយជាក់លាក់) ដោយមិនគិត ថាតើលក្ខខណ្ឌនៃការមិនផ្ទេរត្រូវបានបំពេញ។

### ប្រព្រឹត្តកម្មនៃលក្ខណៈពិសេសសម្រាប់ការបំពេញវិញ

២២ សម្រាប់សិទ្ធិទិញនាពេលអនាគត ដែលមានលក្ខណៈពិសេសសម្រាប់ការបំពេញវិញ មិនត្រូវយកមកគិតនៅពេលធ្វើការប៉ាន់ស្មានតំលៃសមស្របនៃសិទ្ធិទិញនាពេលអនាគត ដែលបានផ្តល់នៅថ្ងៃធ្វើការវាស់វែង ប៉ុន្តែជំរើសសម្រាប់ការបំពេញវិញ ត្រូវបានគិតដូចជាការផ្តល់សិទ្ធិនៃការទិញ នាពេលអនាគត ប្រសិនបើនិងនៅពេលដែលជំរើសសម្រាប់ការបំពេញវិញ ត្រូវបានផ្តល់។

### បន្ទាប់ពីថ្ងៃផ្ទេរ

២៣ ដោយបានទទួលស្គាល់ទំនិញ ឬសេវាកម្មបានទទួលតាមកថាខណ្ឌ១០-២២ ព្រមទាំងការកើនឡើងនៃទ្រព្យម្ចាស់ ក្រុមហ៊ុនមិនត្រូវធ្វើការកែតំរូវនាពេលក្រោយលើទ្រព្យម្ចាស់សរុបបន្ទាប់ពីថ្ងៃផ្ទេរនោះទេ។ ឧទាហរណ៍

ក្រុមហ៊ុនមិនត្រូវទាញត្រលប់មកវិញនាពេលក្រោយនូវចំនួនដែលបានទទួលស្គាល់សម្រាប់ សេវាកម្មបានទទួលពីនិយោជិត ប្រសិនបើឧបករណ៍ទ្រព្យម្ចាស់បានផ្ទេរត្រូវបានដកហូតនាពេលក្រោយ ឬសិទ្ធិក្នុងការទិញ នាពេលអនាគតមិន ត្រូវបានអនុវត្ត ក្នុងករណីនៃសិទ្ធិនៃការទិញភាគហ៊ុននាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយលក្ខខណ្ឌតំរូវនេះមិនបានរាំងស្ទះក្រុមហ៊ុនពីការទទួលស្គាល់នូវការ ផ្ទេរនៅក្នុងក្រុមហ៊ុន ដូចជាការផ្ទេរពីសមាសធាតុទ្រព្យម្ចាស៍មួយទៅសមាសធាតុទ្រព្យម្ចាស់មួយទៀត។

**ប្រសិនបើតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់មិនអាចប៉ាន់ស្មានគួរឱ្យជឿជាក់**

២៤ លក្ខខណ្ឌតំរូវក្នុងកថាខណ្ឌ១៦-២៣ អនុវត្តនៅពេលដែលក្រុមហ៊ុន ត្រូវបានទាមទារឱ្យវាស់វែងប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន យោងតាមតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់។ ក្នុងករណីកំរ ក្រុមហ៊ុនអាចនឹងមិនអាចប៉ាន់ស្មានគួរឱ្យជឿជាក់នូវតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់នាថ្ងៃធ្វើការវាស់វែងបានដូចស្របតាមលក្ខខណ្ឌតំរូវចែងក្នុងកថាខណ្ឌ ១៦-២២។ សម្រាប់តែករណីកំរនេះប៉ុណ្ណោះ ក្រុមហ៊ុនត្រូវៈ

(ក) វាស់វែងនូវឧបករណ៍ទ្រព្យម្ចាស់តាមតំលៃមជ្ឈន្តិកៈ ជាដំបូងនាថ្ងៃដែលក្រុមហ៊ុន បានទទួលទំនិញ ឬភាគីដៃគូផ្តល់សេវាកម្ម ហើយនៅពេលក្រោយនាចុងការិយនៃការរាយការណ៍នីមួយៗ និងនៅថ្ងៃ នៃការទូទាត់ចុងក្រោយ នូវការប្រែប្រួលនៃតំលៃមជ្ឈន្តិកៈត្រូវទទួលស្គាល់ក្នុងចំណេញ ឬខាត។ សម្រាប់ការផ្តល់នូវសិទ្ធិនៃការទិញភាគហ៊ុន នាពេលអនាគត ការព្រមព្រៀង

ទូទាត់ផ្អែកតាមភាគហ៊ុននឹងត្រូវទូទាត់ចុងក្រោយនៅពេលដែលសិទ្ធិត្រូវបានអនុវត្ត ត្រូវបានដកហូត (ឧ. បន្ទាប់ពីការឈប់បន្តការងារ) ឬហួសពេល (ឧ. នាចុងអាយុកាលនៃសិទ្ធិទិញនាពេលអនាគត)។

(ខ) ទទួលស្គាល់ទំនិញ ឬសេវាកម្មដែលបានទទួលផ្អែកលើចំនួននៃឧបករណ៍ទ្រព្យម្ចាស់ ដែលចុងក្រោយបានផ្ទេរ ឬ(ដែលអាចអនុវត្តបាន)អនុវត្ត។ ឧទាហរណ៍ដូចជាដើម្បីអនុវត្តនូវលក្ខខណ្ឌតំរូវចំពោះសិទ្ធិនៃការទិញភាគហ៊ុននាពេលអនាគត នោះក្រុមហ៊ុនត្រូវទទួលស្គាល់ទំនិញ ឬសេវា កម្មបានទទួល ក្នុងកំឡុងពេលនៃការផ្ទេរ ស្របតាមកថាខ័ណ្ឌ១៤ និង១៥ លើកលែងចំពោះ លក្ខខណ្ឌតំរូវដែលមានក្នុងកថាខ័ណ្ឌ១៥(ខ) ពាក់ព័ន្ធនឹងលក្ខខណ្ឌទីផ្សារមិនអាចអនុវត្តបាន។ ចំនួនដែលត្រូវទទួលស្គាល់សម្រាប់ទំនិញ ឬសេវាកម្មបានទទួលក្នុងកំឡុងពេលនៃការផ្ទេរ ត្រូវផ្អែកតាមចំនួននៃសិទ្ធិក្នុងការទិញភាគហ៊ុននាពេលអនាគតដែលរំពឹងថានឹងផ្ទេរឱ្យ។ ក្រុមហ៊ុនត្រូវពិនិត្យឡើងវិញនូវការប៉ាន់ស្មាននេះបើចាំបាច់ ដូចជាប្រសិនបើព័ត៌មានពេលក្រោយបង្ហាញ

ថាចំនួនរំពឹងទុកនៃសិទ្ធិទិញភាគហ៊ុននាពេលអនាគតដែលនឹងផ្ទេរខុសពីការប៉ាន់ស្មានពេលមុននាថ្ងៃផ្ទេរ ក្រុមហ៊ុនត្រូវពិនិត្យឡើងវិញនូវការប៉ាន់ស្មានដើម្បីឱ្យស្មើទៅនឹងចំនួននៃឧបករណ៍ទ្រព្យម្ចាស់ដែលចុងក្រោយបានផ្ទេរ ក្រោយពីថ្ងៃផ្ទេរ ក្រុមហ៊ុនត្រូវទាញយកមកវិញនូវចំនួន ដែលបានទទួលស្គាល់សម្រាប់

ទំនិញ ឬសេវាកម្មបានទទួល ប្រសិនបើសិទ្ធិទិញភាគហ៊ុន នាពេល អនាគតត្រូវដកហូតនាពេលក្រោយ ឬហួសរយៈពេលនៃអាយុកាលរបស់សិទ្ធិនៃការទិញភាគហ៊ុននោះ។

២៥ ប្រសិនបើក្រុមហ៊ុនអនុវត្តតាមកថាខ័ណ្ឌ ២៤ ក្រុមហ៊ុនមិនចាំបាច់ប្រើប្រាស់កថាខ័ណ្ឌ២៦-២៩ទេ ពីព្រោះរាល់ការកែសម្រួលលើរយៈពេល និងលក្ខខណ្ឌចំពោះឧបករណ៍ទ្រព្យម្ចាស់ដែលនឹងត្រូវបានផ្តល់ នឹងត្រូវបានយកមកគិតនៃពេលអនុវត្តវិធីសាស្រ្តតំលៃមជ្ឈន្តិកៈដូចចែងក្នុងកថាខ័ណ្ឌ ២៤ ប៉ុន្តែប្រសិនបើ ក្រុមហ៊ុនទូទាត់ការផ្តល់នូវឧបករណ៍ទ្រព្យម្ចាស់ដូចដែលកថាខ័ណ្ឌ២៤ បានចែងត្រូវ

(ក) ប្រសិនបើការទូទាត់កើតឡើងនៅកំឡុងពេលនៃការផ្ទេរ ក្រុមហ៊ុនត្រូវកត់ត្រាការទូទាត់នោះដូចជា ការបន្ថែមល្បឿន នៃការផ្ទេរ ហេតុដូចនេះត្រូវទទួលស្គាល់ភ្លាមៗនូវចំនួននៅសល់ដែលនឹងត្រូវទទួលស្គាល់សម្រាប់ទំនិញ ឬសេវាកម្ម បានទទួលក្នុងកំឡុងពេលនៃការផ្ទេរ។

(ខ) រាល់ការទូទាត់ដែលធ្វើឡើងនៅពេលទូទាត់ ត្រូវកត់ត្រាដូចជាការទិញត្រលប់វិញនូវឧបករណ៍ទ្រព្យម្ចាស់ គឺដូចជាការកាត់បន្ថយពីទ្រព្យម្ចាស់ លើកលែងទឹកប្រាក់ ទូទាត់នោះ លើសពីតំលៃមជ្ឈន្តិកៈ របស់ឧបករណ៍ទ្រព្យម្ចាស់វាស់វែងនាថ្ងៃទិញត្រលប់វិញ ភាពលើសទាំងអស់ត្រូវកត់ត្រា ជាចំណាយ។

**ការកែសម្រួលលើរយៈពេល និងលក្ខខណ្ឌរបស់ឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ រួមមានការលប់ និងការទូទាត់ជំរះ**

២៦ ក្រុមហ៊ុនអាចកែសំរួលលើរយៈពេល និងលក្ខខណ្ឌឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់ ឧទាហរណ៍ ក្រុមហ៊ុនអាចកែប្រែនូវថ្លៃអនុវត្ត នៃសិទ្ធិការទិញនាពេលអនាគតដែលបានផ្តល់ឱ្យនិយោជិត (កំណត់ថ្លៃនៃសិទ្ធិទិញឡើងវិញ) ដែលធ្វើឱ្យកើនឡើងតំលៃសមស្រប នៃសិទ្ធិទិញទាំងនោះ។ លក្ខខណ្ឌតំរូវក្នុងកថាខ័ណ្ឌ ២៧-២៩ សម្រាប់ការកត់ត្រាផលប៉ះពាល់នៃការកែសម្រួលដូចបានបង្ហាញក្នុងបរិបថ នៃប្រតិបត្តិការទូទាត់ ជាមួយនិយោជិតផ្អែកតាមភាគហ៊ុន ប៉ុន្តែលក្ខខណ្ឌតំរូវក៏ត្រូវបានអនុវត្ត ចំពោះប្រតិបត្តិការទូទាត់ ជាមួយភាគីក្រៅពីនិយោជិតផ្អែកតាមភាគហ៊ុន ដែលវាស់វែងយោងតាមតំលៃសមស្របនៃឧបករណ៍ទ្រព្យ ម្ចាស់បានផ្តល់ក្នុងករណីក្រោយនេះ ការយោងចំពោះថ្ងៃផ្តល់ដែលមានក្នុងកថាខ័ណ្ឌ២៧-២៩ ត្រូវជំនួស ដោយការយោងលើថ្ងៃក្រុមហ៊ុនទទួលទំនិញ ឬដៃគូភាគីផ្តល់សេវាកម្ម។

២៧ ក្រុមហ៊ុនត្រូវទទួលស្គាល់ក្នុងកំរិតអប្បរមានូវទំនិញ បានទទួលវាស់វែងនៅថ្ងៃផ្តល់នូវតំលៃសមស្របនៃ ឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ លើកលែងតែឧបករណ៍ទាំងនោះមិនត្រូវបានផ្ទេរដោយសារការ មិនបានបំពេញនូវលក្ខខណ្ឌការផ្ទេរត្រឹមត្រូវ (ក្រៅពីលក្ខខណ្ឌទីផ្សារ) ដែលបានកំណត់នាថ្ងៃផ្តល់។ ករណីខាងលើត្រូវអនុវត្តដោយមិនគិតថាការកែសម្រួលលើរយៈពេល និងលក្ខខណ្ឌឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ ឬការលប់ ឬការទូទាត់ជំរះការផ្តល់ឧបករណ៍ទ្រព្យម្ចាស់នោះទេ។ ជាបន្ថែម ក្រុមហ៊ុនត្រូវទទួលស្គាល់ ផលប៉ះពាល់នៃការកែសម្រួល ដែលធ្វើឱ្យកើនឡើង នូវតំលៃសម

ស្របនៃការព្រមព្រៀងទូទាត់តាមភាគហ៊ុន ឬធ្វើឱ្យមានប្រយោជន៍ដល់និយោជិត។ ការណែនាំស្តីពីការអនុវត្តនេះមានចែងក្នុងឧបសម្ព័ន្ធខ។

២៨ ប្រសិនបើការផ្តល់នូវឧបករណ៍ទ្រព្យម្ចាត្រូវបានលប់ ឬទូទាត់ជំរះក្នុងកំឡុងពេលនៃការផ្ទេរ (ក្រៅពីការ លប់ដោយសារការដកហូតនៃពេល ដែលលក្ខខណ្ឌនៃការផ្ទេរមិនបានបំពេញ):

(ក) ក្រុមហ៊ុនត្រូវកត់ត្រាការលប់ ឬទូទាត់ជំរះដូចជាការបង្កើនល្បឿនក្នុងការផ្ទេរ ហើយដូច្នេះត្រូវទទួលស្គាល់ភ្លាមៗនូវចំនួន ដែលនឹងត្រូវទទួលស្គាល់ សម្រាប់សេវាកម្មបានទទួល ក្នុងរយៈពេលនៅសល់នៃកំឡុងពេលផ្ទេរ។

(ខ) ទឹកប្រាក់ទូទាត់ដែលធ្វើឡើងចំពោះនិយោជិតលើការលប់ ឬការទូទាត់ជំរះការផ្តល់ ត្រូវកត់ត្រាដូចជា ការទិញត្រលប់វិញ នូវភាគកម្មទ្រព្យម្ចាស់ គឺដូចជាការកាត់ចេញពីទ្រព្យម្ចាស់លើកលែងតែទឹកប្រាក់ទូទាត់លើសតំលៃសមស្រប នៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់វាស់វែងនៅថ្ងៃទិញត្រលប់វិញចំនួនលើសទាំងនេះ ត្រូវទទួលស្គាល់ជាចំណាយ។ ប៉ុន្តែប្រសិនបើការព្រមព្រៀងទូទាត់ដោយ ភាគហ៊ុនរួមបញ្ចូលសមាសធាតុបំណុល ក្រុមហ៊ុនត្រូវវាស់វែងជាថ្មីនូវតំលៃសមស្របនៃបំណុល នាថ្ងៃលប់ ឬទូទាត់ជំរះ ទឹកប្រាក់ទូទាត់សម្រាប់ការជំរះសមាសធាតុបំណុលត្រូវកត់ត្រាជាការដោះ បំណុល។

(គ) ប្រសិនបើឧបករណ៍ទ្រព្យម្ចាស់ថ្មីត្រូវផ្តល់ឱ្យនិយោជិត ហើយនៅថ្ងៃដែលឧបករណ៍ទ្រព្យម្ចាស់ថ្មី ទាំងនោះត្រូវបានផ្តល់ ក្រុមហ៊ុនកំណត់ឧបករណ៍ទ្រព្យម្ចាស់ថ្មី ដែលបានផ្តល់ជាការជំនួស នូវ

ឧបករណ៍ទ្រព្យម្ចាស់ដែលបានលប់ ហើយក្រុមហ៊ុនត្រូវកត់ត្រាការផ្តល់ឧបករណ៍ទ្រព្យម្ចាស់ជំនួស ដូចគ្នានឹងការកែសម្រួលលើឧបករណ៍ទ្រព្យម្ចាស់ដំបូង ស្របតាមកថាខណ្ឌ២៧ និងការណែនាំក្នុងឧបសម្ព័ន្ធខ។ ការកើនឡើងតំលៃសមស្របបានផ្តល់ នៅថ្ងៃដែលឧបករណ៍ទ្រព្យម្ចាស់ជំនួសបានផ្តល់ គឺជាភាពខុសគ្នារវាងតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់ជំនួស និងតំលៃសមស្របពិតនៃឧបករណ៍ទ្រព្យម្ចាស់បានលប់។ តំលៃសមស្របពិតនៃឧបករណ៍ទ្រព្យម្ចាស់បានលប់គឺជា តំលៃសមស្របមុនពេលការលប់ ដកចំនួននៃទឹកប្រាក់ទូទាត់ទៅឱ្យនិយោជិតពេលលប់ឧបករណ៍ ទ្រព្យម្ចាស់ដែលបានកត់ត្រាជាការកាត់ពីទ្រព្យម្ចាស់ស្របតាម (ខ) ខាងលើ។ ប្រសិនបើ ក្រុមហ៊ុនមិនកំណត់នូវឧបករណ៍ទ្រព្យម្ចាស់ថ្មីដែលបានផ្តល់ជាឧបករណ៍ទ្រព្យម្ចាស់ជំនួសលើឧបករណ៍ទ្រព្យម្ចាស់បានលប់ ក្រុមហ៊ុនត្រូវកត់ត្រាឧបករ-ណ៍ទ្រព្យម្ចាស់ថ្មីដូចជាការផ្តល់ឧបករណ៍ទ្រព្យម្ចាស់ថ្មី។

២៨ក ប្រសិនបើក្រុមហ៊ុន ឬភាគីដៃគូអាចជ្រើសរើសការបំពេញលកខណ្ឌមិនផ្ទេរ ក្រុមហ៊ុនត្រូវចាត់ទុកការមិន បានបំពេញរបស់ភាគីដៃគូក្រុមហ៊ុនក្នុងការបំពេញលក្ខខណ្ឌមិនផ្ទេរនោះជាការលប់ ក្នុងកំឡុងពេលនៃការផ្ទេរ។

២៩ ប្រសិនបើក្រុមហ៊ុនទិញត្រលប់វិញនូវឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្ទេរ ទឹកប្រាក់ទូទាត់ចំពោះនិយោជិត ត្រូវកត់ត្រាជាការកាត់ចេញពីទ្រព្យម្ចាស់ លើកលែងចំពោះទឹកប្រាក់ទូទាត់ លើសតំលៃសមស្រប នៃឧបករណ៍ទ្រព្យម្ចាស់បានទិញត្រលប់វិញវាស់វែង នៅថ្ងៃទិញត្រលប់វិញ ហើយចំនួនលើសត្រូវទទួលស្គាល់ ជាចំណាយ។

**ប្រតិបត្តិការទូទាត់តាមភាគហ៊ុនដោយទូទាត់ជិរះជាសាច់ប្រាក់**

៣០ **សម្រាប់ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដោយទូទាត់ជិរះជាសាច់ប្រាក់ ក្រុមហ៊ុនត្រូវវាស់វែងទំនិញ ឬសេវាកម្មទទួលបាន និងបំណុលកើតមាន តាមតំលៃសមស្របនៃបំណុល។ រហូតដល់ពេលដែលបំណុល ត្រូវទូទាត់ ជិរះ ក្រុមហ៊ុនត្រូវវាស់វែងឡើងវិញនូវតំលៃសមស្របនៃបំណុលនាចុងគ្រា រាយការណ៍នីមួយៗ និងនៅថ្ងៃទូទាត់ជិរះនូវការប្រែប្រួលនៃតំលៃសមស្រប ដែលបានទទួលស្គាល់ក្នុងចំណេញ ឬខាតប្រចាំគ្រា។**

៣១ ឧទាហរណ៍ ក្រុមហ៊ុនអាចផ្តល់ភាគហ៊ុនដែលមានសិទ្ធិទៅកាន់និយោជិត ដែលជាផ្នែកមួយនៃកញ្ចប់លាភការរបស់គេ ដែលនិយោជិតអាចក្លាយជា អ្នកមានសិទ្ធិ ចំពោះការទូទាត់ ជាសាច់ប្រាក់នាពេលអនាគត (ជាជាង ឧបករណ៍ទ្រព្យម្ចាស់) ដោយអាស្រ័យតាមការកើនឡើងនៃតំលៃភាគហ៊ុន របស់របស់ក្រុមហ៊ុនពី កំរិតជាក់លាក់មួយក្នុងកំឡុងពេលមួយជាក់លាក់ ឬក្រុមហ៊ុនអាចផ្តល់ឱ្យនិយោជិតរបស់ខ្លួន នូវសិទ្ធិ ដើម្បីទទួលបានការ ទូទាត់សាច់ប្រាក់នាពេលអនាគត ដោយផ្តល់ឱ្យពួកគេនូវសិទ្ធិទិញភាគ ហ៊ុនដែលអាចទិញ មកវិញបាន (រួមមានភាគហ៊ុន ដែលត្រូវបោះផ្សាយនា ពេលអនុវត្តសិទ្ធិទិញភាគហ៊ុននាពេលអនាគត)ទោះបីជាដោយបង្ខំ (ពេល បញ្ចប់ការងារ) ឬដោយជំរើសនិយោជិត។

៣២ ក្រុមហ៊ុនត្រូវទទួលស្គាល់សេវាកម្មបានទទួល និងបំណុល ដែលត្រូវសង ចំពោះសេវាកម្មទាំងនោះតាមការផ្តល់សេវាកម្មរបស់និយោជិតឧទាហរណ៍ ភាគហ៊ុនដែលមានសិទ្ធិមួយចំនួនត្រូវបានផ្ទេរឱ្យភ្លាមៗ ដោយនិយោជិត មិនតំរូវឱ្យបញ្ចប់នូវសេវាកម្មក្នុងកំឡុងពេលមួយជាក់លាក់ដើម្បីអាចមាន សិទ្ធិចំពោះការទូទាត់ជាសាច់ប្រាក់។ ក្នុងពេលមិនមានភស្តុតាងដែលផ្ទុយ

ទៅនេះ ក្រុមហ៊ុនត្រូវសន្មតថាសេវាកម្មដែលបាន ផ្តល់ដោយនិយោជិត ដើម្បីដោះដូរនូវការទទួលភាគហ៊ុនដែលមានសិទ្ធិ។ ដូច្នេះ ក្រុមហ៊ុនត្រូវទទួលស្គាល់ ភ្លាមៗនូវសេវាកម្មបានទទួលនិងបំណុល ដែលត្រូវសងពួកគេ។ ប្រសិនបើភាគហ៊ុនដែលមានសិទ្ធិមិនបានផ្ទេរទេរហូតដល់និយោជិតបានបញ្ចប់នូវរយៈពេលជាក់លាក់នៃសេវាកម្ម ក្រុមហ៊ុនត្រូវទទួលស្គាល់សេវាកម្មបានទទួល និងបំណុលដើម្បីសងឱ្យពួកគេតាមរយៈពេលដែលនិយោជិតផ្តល់សេវាកម្ម។

៣៣ បំណុលត្រូវបានវាស់វែងជាដំបូងនិងនៅចុងគ្រានៃការរាយការណ៍នីមួយៗ រហូតដល់វាត្រូវបានទូទាត់ជំរះ តាមតំលៃសមស្របនៃភាគហ៊ុន ដែលមានសិទ្ធិ ដោយប្រើនូវគំរូកំណត់ថ្លៃ សិទ្ធិការទិញនាពេលអនាគត រួមបញ្ចូលរយៈពេល និងលក្ខខណ្ឌដែលភាគហ៊ុនដែលមានសិទ្ធិត្រូវបានផ្តល់ ព្រមទាំងវិសាលភាពដែល និយោជិតបានផ្តល់សេវាកម្មរហូតដល់បច្ចុប្បន្ន។

**ប្រតិបត្តិការទូទាត់តាមភាគហ៊ុនដោយមានជំរើសជាសាច់ប្រាក់**

៣៤ សម្រាប់ប្រតិបត្តិការទូទាត់តាមភាគហ៊ុន ដែលមានលក្ខខណ្ឌនៃការព្រមព្រៀងផ្តល់ដល់ក្រុមហ៊ុន និងភាគីដៃគូនូវជំរើសថាតើក្រុមហ៊ុនទូទាត់ជំរះជាសាច់ប្រាក់ (ឬទ្រព្យសម្បត្តិផ្សេងទៀត) ឬដោយការបោះផ្សាយនូវឧបករណ៍ទ្រព្យម្ចាស់ ក្រុមហ៊ុនត្រូវកត់ត្រាចំពោះប្រតិបត្តិការ ឬផ្នែកខ្លះនៃប្រតិបត្តិការដូចជាប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនជំរះដោយសាច់ប្រាក់ ប្រសិនបើ ក្រុមហ៊ុនកើតមានបំណុលដើម្បីជំរះទូទាត់ជា សាច់ប្រាក់ ឬទ្រព្យសម្បត្តិដ៏ទៃទៀត ឬកត់ដូចជាប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនទូទាត់

**ជំរះដោយទ្រព្យម្ចាស់ប្រសិនបើមិនមានបំណុលបែបនេះកើតឡើងទេ។**

**ប្រតិបត្តិការទូទាត់តាមភាគហ៊ុនដែលលក្ខខណ្ឌនៃការព្រមព្រៀងផ្តល់ដល់ភាគីដៃគូនូវជំរើសទូទាត់ជំរះ**

៣៥ ប្រសិនបើក្រុមហ៊ុនបានផ្តល់ភាគីដៃគូនូវសិទ្ធិជ្រើសរើសថាតើ ការទូទាត់ផ្អែកតាមភាគហ៊ុនអាចត្រូវបាន ទូទាត់ជំរះជាសាច់ប្រាក់[1] ឬដោយការបោះផ្សាយឧបករណ៍ទ្រព្យម្ចាស់ក្រុមហ៊ុនបានផ្តល់នូវល្បាយឧបករណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលនូវសមាសធាតុបំណុល (គឺជាសិទ្ធិ នៃភាគីដៃគូទាមទារការទូទាត់ជាសាច់ប្រាក់) និងសមាសធាតុទ្រព្យម្ចាស់ (គឺសិទ្ធិនៃភាគីដៃគូទាមទារការទូទាត់ជំរះ ជាឧបករណ៍ទ្រព្យម្ចាស់ ជាជាងជាសាច់ប្រាក់)។ សម្រាប់ប្រតិបត្តិការជាមួយភាគីផ្សេងពីនិយោជិត ដែលតំលៃសមស្របនៃទំនិញ ឬសេវាកម្មបានទទួលត្រូវបានវាស់វែងដោយផ្ទាល់ ក្រុមហ៊ុនត្រូវវាស់វែងសមាសធាតុទ្រព្យម្ចាស់នៃល្បាយឧបករណ៍ហិរញ្ញវត្ថុ ជាភាពខុសគ្នារវាងតំលៃសមស្របនៃទំនិញ ឬសេវាកម្មបានទទួលនិងតំលៃសមស្របនៃសមាសធាតុបំណុល នៅថ្ងៃដែលទំនិញ ឬសេវាកម្មត្រូវបានទទួល។

៣៦ សម្រាប់ប្រតិបត្តិការដ៏ទៃទៀត រួមមានប្រតិបត្តិការជាមួយនិយោជិតក្រុមហ៊ុនត្រូវវាស់វែងតំលៃសមស្របនៃ ល្បាយឧបករណ៍ហិរញ្ញវត្ថុនាថ្ងៃធ្វើការវាស់វែង ដោយគិតពីលក្ខខណ្ឌ និងស្ថានភាពដែលសិទ្ធិទទួលសាច់ប្រាក់ ឬឧបករណ៍ទ្រព្យម្ចាស់ត្រូវបានផ្តល់។

៣៧ ដើម្បីអនុវត្តកថាខ័ណ្ឌ៣ ៦ ជាដំបូងក្រុមហ៊ុនត្រូវវាស់វែងនូវតំលៃសមស្របនៃសមាសធាតុបំណុល បន្ទាប់មកវាស់វែងតំលៃសមស្របនៃសមាស

1 ក្នុងកថាខណ្ឌ៣៥-៤៣ រាល់ការយោងពីសាច់ប្រាក់ក៏រួមមានទ្រព្យសម្បត្តិផ្សេងទៀតរបស់ក្រុមហ៊ុន

ធាតុទ្រព្យម្ចាស់ ដោយគិតថាភាគីដៃគូត្រូវតែដកហូតនូវសិទ្ធិ ដើម្បីទទួលបាននូវឧបករណ៍ទ្រព្យម្ចាស់។ តំលៃសមស្របនៃល្បាយឧបករណ៍ហិរញ្ញវត្ថុជាសរុបនៃតំលៃសមស្របរបស់សមាសធាតុទាំងពីរ។ ក៏ប៉ុន្តែ ប្រតិបត្តិ-ការដែលភាគីដៃគូមានជំរើសទូទាត់ជំរះ ច្រើនតែត្រូវរៀបចំ ដូច្នេះតំលៃសមស្រប នៃជំរើសទូទាត់ជំរះមួយ ដូចគ្នាទៅនឹង ជំរើសមួយទៀត។ ឧទាហរណ៍ ភាគីដៃគូអាចមានជំរើសនៃការទទួលបានសិទ្ធិទិញភាគហ៊ុននាពេលអនាគត ឬទូទាត់ជំរះជាសាច់ប្រាក់ភាគហ៊ុនមានសិទ្ធិ ក្នុងករណីនេះតំលៃសមស្រប នៃសមាសធាតុទ្រព្យម្ចាស់គឺសូន្យ ដូច្នេះតំលៃសមស្រប នៃល្បាយឧបករណ៍ហិរញ្ញវត្ថុ ដូចគ្នាទៅនឹងតំលៃសមស្រប នៃសមាសធាតុបំណុល។ ផ្ទុយមកវិញ ប្រសិនបើ តំលៃសមស្រប នៃជំរើសការទូទាត់ជំរះខុសគ្នាតំលៃសមស្រប នៃសមាធាតុទ្រព្យម្ចាស់ជាទូទៅធំជាងសូន្យ ដែលធ្វើឱ្យតំលៃសមស្របនៃល្បាយឧបករណ៍ហិរញ្ញវត្ថុនឹងធំជាងតំលៃសមស្របសមាសធាតុបំណុល។

៣៨ ក្រុមហ៊ុនត្រូវធ្វើគណនេយ្យកម្មដាច់ដោយឡែកពីគ្នា សម្រាប់ទំនិញ ឬសេវាកម្មបានទទួល ឬទិញតាមសមាសធាតុនីមួយៗ នៃល្បាយឧបករណ៍ហិរញ្ញវត្ថុ។ ចំពោះសមាសធាតុបំណុល ក្រុមហ៊ុនត្រូវទទួលស្គាល់ ទំនិញ ឬសេវាកម្មបានទទួល និងបំណុលដើម្បីសងទំនិញ ឬសេវាកម្មទាំងនោះតាមការផ្គត់ផ្គង់ទំនិញ ឬផ្តល់សេវាកម្មរបស់ភាគីដៃគូ ស្របតាមលក្ខខណ្ឌតំរូវអនុវត្តចំពោះការជំរះទូទាត់ជាសាច់ប្រាក់ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន (កថខណ្ឌ ៣០-៣៣) ចំពោះសមាសធាតុទ្រព្យម្ចាស់ (បើមាន) ក្រុមហ៊ុនត្រូវទទួលស្គាល់ទំនិញ ឬសេវាកម្មបានទទួល និងកើនឡើងនៃទ្រព្យម្ចាស់តាមការផ្គត់ផ្គង់ទំនិញ ឬផ្តល់សេវាកម្មរបស់ភាគីដៃគូ ស្របតាម

ការព្រមព្រៀងដែលអនុវត្ត ចំពោះប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុន ដែលជំរះជាទ្រព្យម្ចាស់ (កថខណ្ឌ ១០-២៩)។

៣៩ នៅថ្ងៃទូទាត់ជំរះ ក្រុមហ៊ុនត្រូវធ្វើការវាស់វែងជាថ្មីនូវបំណុលតាមតំលៃសមស្របរបស់វាប្រសិនបើក្រុមហ៊ុនបោះផ្សាយឧបករណ៍ទ្រព្យម្ចាស់នាពេលទូទាត់ជំរះ ជាជាងការទូទាត់ជាសាច់ប្រាក់បំណុល ត្រូវផ្ទេរផ្ទាល់ទៅក្នុងទ្រព្យម្ចាស់តាមតំលៃតបស្នងរបស់ឧបករណ៍ទ្រព្យម្ចាស់បានបោះផ្សាយ។

៤០ ប្រសិនបើក្រុមហ៊ុនទូទាត់សងជាសាច់ប្រាក់លើការជំរះ ជាជាងការបោះផ្សាយឧបករណ៍ទ្រព្យម្ចាស់ ការទូទាត់សងនោះត្រូវបានប្រើប្រាស់ ដើម្បីទូទាត់ជំរះបំណុលទាំងអស់។ រាល់សមាសធាតុទ្រព្យម្ចាស់ ដែលបានទទួលស្គាល់ពីមុន ត្រូវរក្សាទុកក្នុងទ្រព្យម្ចាស់ដដែល។ តាមរយៈការជ្រើសរើសដើម្បីទទួលជាសាច់ប្រាក់លើការទូទាត់ជំរះ ភាគីដៃគូបានដកហូតនូវសិទ្ធិដើម្បីទទួលនូវឧបករណ៍ទ្រព្យម្ចាស់។ ប៉ុន្តែ លក្ខខណ្ឌតំរូវនេះមិនរារាំងក្រុមហ៊ុនពីការទទួលស្គាល់ការផ្ទេរ នៅក្នុងទ្រព្យម្ចាស់ ដូចជាការផ្ទេរពីសមាសធាតុមួយទៅសមាសថាទ្រព្យម្ចាស់ផ្សេងទៀត។

**ប្រតិបត្តិការទូទាត់តាមភាគហ៊ុនដែលលក្ខខណ្ឌនៃការព្រមព្រៀងផ្តល់ដល់ក្រុមហ៊ុននូវជំរើសទូទាត់ជំរះ**

៤១ សម្រាប់ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន មានលក្ខខណ្ឌ នៃការព្រមព្រៀងផ្តល់ឱ្យក្រុមហ៊ុននូវជំរើស ថាតើត្រូវទូទាត់ជាសាច់ប្រាក់ ឬដោយការបោះផ្សាយឧបករណ៍ទ្រព្យម្ចាស់ ក្រុមហ៊ុនត្រូវកំណត់ថាថាតើ ក្រុមហ៊ុនមានកាតព្វកិច្ចបច្ចុប្បន្នដើម្បីទូទាត់ជំរះជាសាច់ប្រាក់និងត្រូវធ្វើគណនេយ្យកម្មតាមប្រតបត្តិការ ទូទាត់ផ្អែកតាមភាគហ៊ុនដែលសមស្រប។ ក្រុមហ៊ុនមានកាតព្វកិច្ចបច្ចុប្បន្នដើម្បីទូទាត់ជាសាច់ប្រាក់ ប្រសិនបើ ជំរើសនៃការ

ទូទាត់ជំរះ ជាឧបករណ៍ទ្រព្យម្ចាស់មិនមានសមាសធាតុពាណិជ្ជកម្ម (ឧ. ពីព្រោះ ក្រុមហ៊ុនត្រូវបានហាមឃាត់តាមច្បាប់ ក្នុងការបោះផ្សាយភាគហ៊ុន) ឬក្រុមហ៊ុនមានការអនុវត្តន៍ពីអតីតកាល ឬគោលនយោបាយបានចែងពីការទូទាត់ជាសាច់ប្រាក់ ឬជាទូទៅទូទាត់ជំរះជាសាច់ប្រាក់ នៅពេលភាគីដៃគូស្នើសុំការទូទាត់ជាសាច់ប្រាក់។

៤២ ប្រសិនបើ ក្រុមហ៊ុនមានកាតព្វកិច្ចបច្ចុប្បន្ន ដើម្បីទូទាត់ជាសាច់ប្រាក់ ក្រុមហ៊ុនត្រូវធ្វើគណនេយ្យកម្មចំពោះ ប្រតិបត្តិការស្របាមលក្ខខណ្ឌតំរូវ ដែលអនុវត្តចំពោះប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដែលជំរះទូទាត់ ជាសាច់ប្រាក់ក្នុងកថាខ័ណ្ឌ៣០-៣៣។

៤៣ ប្រសិនបើក្រុមហ៊ុនគ្មានកាតព្វកិច្ចបែបនេះទេ ក្រុមហ៊ុនត្រូវធ្វើគណនេយ្យកម្ម ចំពោះប្រតិបត្តិការស្របតាម លក្ខខណ្ឌតំរូវ ដែលអនុវត្ត ចំពោះប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុន ដែលជំរះទូទាត់ជាទ្រព្យម្ចាស់ក្នុងកថាខ័ណ្ឌ១០-២៩។ នៅពេលការទូទាត់ជំរះ:

(ក) បើក្រុមហ៊ុនជ្រើសរើសយកទូទាត់ជាសាច់ប្រាក់ ការបង់ជាសាច់ប្រាក់ ត្រូវធ្វើគណនេយ្យកម្ម សម្រាប់ការទិញត្រលប់វិញ នៃភាគកម្មទ្រព្យម្ចាស់ ដូចជាការកាត់ពីទ្រព្យម្ចាស់ លើកលែងតែចំនុច (គ) ខាងក្រោម។

(ខ) បើក្រុមហ៊ុនជ្រើសរើសយកការបោះផ្សាយឧបករណ៍ទ្រព្យម្ចាស់ មិនមានការធ្វើគណនេយ្យកម្ម បន្ថែមនោះទេ (ក្រៅពីការផ្ទេរពីសមាសធាតុមួយទៅសមាសថាទ្រព្យម្ចាស់ផ្សេងទៀត ប្រសិនបើចាំបាច់)លើកលែងតែចំនុច (គ) ខាងក្រោម។

(គ) បើក្រុមហ៊ុនជ្រើសរើសយកជំរើសការទូទាត់ជំរះ ដែលមានតំលៃសមស្របខ្ពស់ជាងនៅថ្ងៃនៃការ ទូទាត់ជំរះ ក្រុមហ៊ុនត្រូវទទួលស្គាល់ចំណាយបន្ថែមចសម្រាប់តំលៃលើសដែលត្រូវបានផ្តល់ឱ្យដែលជាភាពខុសគ្នារវាងសាច់ប្រាក់បានសង និងតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់ដែលគិតថានឹងបោះផ្សាយ ឬជាភាពខុសគ្នារវាងតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានបោះផ្សាយនិងចំនួនសាច់ប្រាក់ដែលអាចត្រូវបានបង់។

## ប្រតិបត្តិការទូទាត់ផ្អែកលើភាគហ៊ុនរវាងក្រុមនៃក្រុមហ៊ុន (វិសោធនកម្មឆ្នាំ២០០៩)

៤៣ក នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកឬនីយមួយៗ ក្រុមហ៊ុនទទួលបានទំនិញ ឬសេវាកម្ម ត្រូវវាស់វែងទំនិញ ឬសេវាកម្មបានទទួល ដូចជាប្រតិបត្តិការផ្អែកតាមភាគហ៊ុនដែលទូទាត់ជាទ្រព្យម្ចាស់ ឬទូទាត់ជាសាច់ប្រាក់ ចំពោះប្រតិបត្តិកាទូទាត់ផ្អែកតាមភាគហ៊ុនរវាងក្រុម នៃក្រុមហ៊ុន ដោយធ្វើការវាយតំលៃៈ

(ក) លក្ខណៈនៃរង្វាន់ដែលបានផ្តល់ និង

(ខ) សិទ្ធិ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនចំនួន ដែលបានទទួលស្គាល់ដោយក្រុមហ៊ុនទទួលទំនិញ ឬសេវាកម្ម អាចខុសពីចំនួន ដែលបានទទួល ស្គាល់របស់ក្រុមរួម ឬដោយក្រុមនៃក្រុមហ៊ុនដ៏ទៃដែលទូទាត់ជំរះប្រតិបត្តិការផ្អែកតាមភាគហ៊ុន។

៤៣ខ ក្រុមហ៊ុនទទួលទំនិញ ឬសេវាកម្មត្រូវវាស់វែងទំនិញ ឬសេវាកម្មបានទទួល ជាប្រតិបត្តិការទូទាត់ផ្អែកតាម ភាគហ៊ុនដែលទូទាត់ជាទ្រព្យម្ចាស់ នៅពេលដែល:

(ក) រង្វាន់ដែលបានផ្តល់ជាឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនខ្លួនឯង

(ខ) ក្រុមហ៊ុនមិនមានកាតព្វកិច្ចដើម្បីទូទាត់ជំរះនូវប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុននៅពេលក្រោយក្រុមហ៊ុនត្រូវវាស់វែងជាថ្មីនូវប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុន ចំពោះតែការប្រែប្រួល នៃលក្ខខណ្ឌ ផ្ទេរមិនមែនទីផ្សារស្របតាមកថាខណ្ឌ ១៩ -២១ ។ ក្នុងគ្រប់កាលៈទេសៈទាំងអស់ ក្រុមហ៊ុន ទទួលទំនិញ ឬសេវាកម្មត្រូវវាស់វែងទំនិញ ឬសេវាកម្មបានទទួល ជាប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដែលជំរះទូទាត់ជាសាច់ប្រាក់។

៤៣គ ក្រុមហ៊ុនទូទាត់ជំរះនូវប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន នៅពេលដែលក្រុមហ៊ុនមួយទៀត ក្នុងក្រុមទទួលទំនិញ ឬសេវាកម្ម ត្រូវទទួលស្គាល់ប្រតិបត្តិការជាប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុន ដែលទូទាត់ជំរះជាទ្រព្យម្ចាស់ តែក្នុងពេលដែលក្រុមហ៊ុនត្រូវបានទូទាត់ក្នុងឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនខ្លួន បើមិនដូច្នោះទេ ប្រតិបត្តិការត្រូវទទួលស្គាល់ជាប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដែលជំរះទូទាត់ជាសាច់ប្រាក់។

៤៣ឃ ប្រតិបត្តិការរបស់ក្រុមខ្លះទាក់ទងនឹង ការព្រមព្រៀងសងវិញ ដែលតំរូវឱ្យក្រុមនៃក្រុមហ៊ុនមួយសងទៅ ក្រុមផ្សេងទៀតចំពោះការផ្តល់ នូវការទូទាត់សង ផ្អែកតាមភាគហ៊ុនសម្រាប់ការផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម។ ក្នុងករណីដូចនេះ ក្រុមហ៊ុនដែលទទួលទំនិញ ឬសេវាកម្មត្រូវធ្វើ គណនេយ្យ

កម្មប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុន ស្របតាមកថាខ័ណ្ឌ ៤៣ខ ដោយមិនគិតថាជាការព្រមព្រៀងការសងរវាងក្រុម។

## ការលាតត្រដាងព័ត៌មាន

**៤៤ ក្រុមហ៊ុនត្រូវលាតត្រដាងព័ត៌មានដែលជួយអ្នកប្រើប្រាស់ នូវរបាយការណ៍ហិរញ្ញវត្ថុយល់នូវលក្ខណៈ និងវិសាលភាពនៃការព្រមព្រៀងការទូទាត់សងផ្អែកតាមភាគហ៊ុនដែលកើតមានក្នុងកំឡុងគ្រា។**

៤៥ ដើម្បីបង្ហាញនូវលទ្ធផលនៃគោលការណ៍ក្នុងកថាខ័ណ្ឌ ៤៤ ក្រុមហ៊ុនត្រូវលាតត្រដាងព័ត៌មានយ៉ាងហោច ណាស់ដូចខាងក្រោមៈ

(ក) ការពិព័ណ៌នានូវប្រភេទនីមួយៗនៃការព្រមព្រៀង ទូទាត់ផ្អែកតាមភាគហ៊ុន ដែលមាននាពេលណា មួយក្នុងកំឡុងពេល ដោយរួមមានរយៈពេល និងលក្ខខណ្ឌទូទៅ នៃការព្រមព្រៀងនីមួយៗ ដូចជាលក្ខខណ្ឌតំរូវនៃការផ្ទេរ រយៈពេលអតិបរមាសិទ្ធិទិញ នាពេលអនាគតដែលបានផ្តល់ ព្រមទាំងវិធីសាស្រ្តទូទាត់ជំរះ (ដូចជាថាតើជាសាច់ប្រាក់ ឬទ្រព្យម្ចាស់)។ ក្រុមហ៊ុនដែលមានប្រភេទការព្រមព្រៀងទូទាត់សងផ្អែកតាមភាគហ៊ុនដូចគ្នាជាចំបង អាចប្រមូលផ្តុំនូវព័ត៌មាននេះ លើកលែង តែចាំបាច់មានការលាតត្រដាងព័ត៌មានដាច់ដោយឡែកនៃការព្រមព្រៀងនីមួយៗ ដើម្បីបំពេញតាមគោលការណ៍នៅក្នុងកថាខ័ណ្ឌ៤៤។

(ខ) ចំនួន និងថ្លៃអនុវត្តមធ្យមរបស់សិទ្ធិនៃការទិញភាគហ៊ុន នាពេលអនាគត សម្រាប់ក្រុមនៃសិទ្ធិទិញនាពេលអនាគតដូចខាងក្រោមៈ

(i) នៅសល់នាដើមគ្រា

(ii) បានផ្តល់ក្នុងកំឡុងគ្រា

(iii) បានដកហូតក្នុងកំឡុងគ្រា

(iv) បានអនុវត្តក្នុងកំឡុងគ្រា

(v) ហួសកាលកំណត់ក្នុងកំឡុងគ្រា

(vi) នៅសល់នាចុងគ្រា និង

(vii) អាចអនុវត្តបាននាចុងគ្រា

(គ) សម្រាប់សិទ្ធិទិញភាគហ៊ុននាពេលអនាគត ដែលបានអនុវត្តក្នុងកំឡុងគ្រា ថ្លៃភាគហ៊ុនជាមធ្យមនា ថ្ងៃពេលអនុវត្ត។ បើសិនសិទ្ធិទិញនាពេលអនាគតត្រូវបានអនុវត្តជាប្រចាំក្នុងកំឡុងគ្រា ក្រុមហ៊ុន អាចជំនួសដោយការលាតត្រដាងព័ត៌មាននៃថ្លៃភាគហ៊ុនជាមធ្យមក្នុងកំឡុងគ្រា។

(ឃ) សម្រាប់សិទ្ធិនៃការទិញភាគហ៊ុន នាពេលអនាគតដែលនៅសល់ក្នុងកំឡុងគ្រា លំដាប់នៃថ្លៃអនុវត្ត និងអាយុកាល ដែលនៅសល់ជាមធ្យម។ ប្រសិនបើលំដាប់នៃថ្លៃអនុវត្តទូលាយ សិទ្ធិទិញនាពេលអនាគតនៅសល់ត្រូវបែងចែកតាមលំដាប់ ដែលមានន័យចំពោះការវាយតំលៃនូវចំនួន និងពេលវេលានៃភាគហ៊ុនបន្ថែម ដែលអាចត្រូវបានបោះផ្សាយ និងសាច់ប្រាក់ដែលអាចត្រូវបានទទួលបន្ទាប់ពីអនុវត្តនូវសិទ្ធិនៃការទិញនាពេលអនាគតទាំងនោះ។

**៤៦ ក្រុមហ៊ុនត្រូវលាតត្រដាងព័ត៌មាន ដែលជួយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុយល់អំពីរបៀបកំណត់តំលៃសមស្របនៃទំនិញ ឬសេវាកម្មបានទទួល ឬតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ នៅកំឡុងគ្រា។**

៤៧ ប្រសិនបើក្រុមហ៊ុនបានវាស់វែងតំលៃសមស្របនៃទំនិញ ឬសេវាកម្មបាន ទទួលដូចជាតំលៃតបស្នងចំពោះឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនដោយ ប្រយោលដោយយោងតាមតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់។ ដើម្បី បង្ហាញនូវលទ្ធផលនៃគោលការណ៍ក្នុងកថាខ័ណ្ឌ៤៤ ក្រុមហ៊ុនត្រូវលាត ត្រដាងព័ត៌មាន យ៉ាងហោចដូចខាងក្រោម:

(ក) សម្រាប់សិទ្ធិទិញភាគហ៊ុនដែលបានផ្តល់ក្នុងកំឡុងគ្រាលាតត្រដាង នូវតំលៃសមស្របជាមធ្យមនៃ សិទ្ធិទាំងនោះនាថ្ងៃធ្វើការវាស់វែង ព្រមទាំងព័ត៌មានស្តីពីរបៀបដែលតំលៃសមស្របនោះបានវាស់ វែង រួមមាន:

(i) គំរូកំណត់ថ្លៃសិទ្ធិទិញ នាពេលអនាគត ដែលបានប្រើ ប្រាស់ ព្រមទាំងធនធានទៅក្នុងគំរូនោះ ដោយរួមមាន ថ្លៃភាគហ៊ុនមធ្យម ថ្លៃអនុវត្ត និងការប្រែប្រួលដែលរំពឹង ទុក អាយុកាលនៃសិទ្ធិទិញនាពេលអនាគត ភាគលាភ ដែលរំពឹងទុក អត្រាការប្រាក់មិនមានហានិភ័យ និង ធនធានដ៏ទៃទៀតដែលត្រូវដាក់ក្នុងគំរូរួមទាំងវិធីសាស្ត្រ ប្រើប្រាស់និងការសន្មតដែលបានបង្កើត ដើម្បីរួមបញ្ចូល នូវផលប៉ះពាល់នៃការអនុវត្តមុនពេលដែលបានរំពឹង ទុក

(ii) របៀបដែលការប្រែប្រួលបានរំពឹងទុក ត្រូវបានកំណត់ ដោយរួមមានការពន្យល់ពីទំហំ ដែលការប្រែប្រួលរំពឹង ទុកនោះផ្អែកតាមការប្រែប្រួលជាប្រវត្តិ និង

(iii) ថាតើ និងរបៀបដែលលក្ខណៈផ្សេងៗទៀត នៃសិទ្ធិទិញនាពេលអនាគតបានផ្តល់ឱ្យ ត្រូវបានរួមបញ្ចូលទៅក្នុងការវាស់វែងតំលៃសមស្របដូចជាលក្ខខណ្ឌទីផ្សារ

(ខ) ចំពោះឧបករណ៍ទ្រព្យម្ចាស់ ដ៏ទៃទៀតបានផ្តល់ ក្នុងកំឡុងគ្រា (ក្រៅពីសិទ្ធិទិញភាគហ៊ុននាពេលអនាគត) នូវចំនួន និងតំលៃសមស្របជាមធ្យមរបស់ឧបករណ៍ទ្រព្យម្ចាស់នាថ្ងៃវាស់វែង ព្រមទាំង ព័ត៌មានស្តីពីតំលៃសមស្របត្រូវបានវាស់វែង ដោយរួមមានៈ

(i) ប្រសិនបើតំលៃសមស្របមិនត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានថ្លៃទីផ្សារ ដែលអាចអង្កេតបាន ត្រូវលាតត្រដាងពីរបៀបដែលវាស់វែងវា

(ii) ថាតើ និងរបៀបដែលភាគលាភរំពឹងទុក ត្រូវបានដាក់បញ្ចូលក្នុងការវាស់វែងតំលៃសមស្របព្រមទាំង

(iii) ថាតើ និងរបៀបដែលលក្ខណៈដ៏ទៃទៀតនៃឧបករណ៍បានផ្តល់ ត្រូវបានដាក់បញ្ចូលក្នុងការវាស់វែងនូវតំលៃសមស្រប។

(គ) សម្រាប់ការព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន ដែលបានកែសំរួលក្នុងកំឡុងគ្រាៈ

(i) ការពន្យល់ពីការកែសំរួល

(ii) ការកើនឡើង នូវតំលៃសមស្របដែលបានផ្តល់ (ជាលទ្ធផលនៃការកែសំរួលទាំងនោះ) ព្រមទាំង

(iii) ព័ត៌មានអំពីរបៀបដែលការកើនឡើងតំលៃសមស្របបានផ្តល់ត្រូវបានវាស់វែង ដោយ មានសង្គតភាពជាមួយ

កថាខណ្ឌមានចែងក្នុង (ក) និង(ខ) ខាងលើ តាមដែល
អាចអនុវត្តបាន។

៤៨ ប្រសិនបើក្រុមហ៊ុនបានវាស់វែងដោយផ្ទាល់នូវតំលៃសមស្របនៃទំនិញ ឬសេវាកម្មបានទទួលក្នុងកំឡុងគ្រា ក្រុមហ៊ុន ត្រូវលាតត្រដាងព័ត៌មានពីរបៀបដែលតំលៃសមស្របត្រូវបានកំណត់ ឧ. ថាតើតំលៃសម ស្របត្រូវបានវាស់វែងតាមតំលៃទីផ្សាររបស់ទំនិញ ឬសេវាកម្ម។

៤៩ ប្រសិនបើក្រុមហ៊ុនបានបញ្ជាក់ថាការសន្មតមិនត្រឹមត្រូវក្នុងកថាខណ្ឌ១៣ ក្រុមហ៊ុនត្រូវលាតត្រដាងបញ្ហានេះ និងផ្ដល់ការពន្យល់ពីហេតុផល ដែលការសន្មតត្រូវបានបញ្ជាក់ថាមិនត្រឹមត្រូវ។

**៥០ ក្រុមហ៊ុនត្រូវលាតត្រដាងព័ត៌មានដែលជួយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុយល់ពីផលប៉ះពាល់នៃ ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនទៅលើប្រាក់ចំណេញ ឬខាតរបស់ក្រុមហ៊ុនប្រចាំគ្រា និងលើស្ថានភាពហិរញ្ញវត្ថុ។**

៥១ ដើម្បីបង្ហាញនូវលទ្ធផលនៃគោលការណ៍ក្នុងកថាខ័ណ្ឌ៤៤ ក្រុមហ៊ុនត្រូវលាតត្រដាងព័ត៌មាន យ៉ាងហោចដូចខាងក្រោមៈ

(ក) ចំណាយសរុប បានទទួលស្គាល់ប្រចាំគ្រា ដែលកើតឡើងពីប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុន ដែលទំនិញ ឬសេវាកម្មបានទទួលមិនអាចបំពេញសមស្រប ចំពោះការទទួលស្គាល់ជាទ្រព្យសម្បត្តិ ដូច្នេះត្រូវបានទទួលស្គាល់ជាចំណាយភ្លាមៗ ដោយរួមមានការលាតត្រដាង ដាច់ដោយឡែក នូវចំណែកនៃចំណាយសរុបទាំងនោះ ដែលកើតឡើងពីប្រតិបត្តិការ ដែលត្រូវបានធ្វើ

គណនេយ្យកម្ម ជាប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដោយទូទាត់ជាទ្រព្យម្ចាស់។

(ខ) សម្រាប់បំណុលដែលកើតឡើងពីប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុនៈ

(i) តំលៃពិតគណនេយ្យសរុបនាចុងគ្រា និង

(ii) តលៃមជ្ឈន្តិកៈសរុបនាចុងគ្រានៃបំណុលត្រូវបានផ្ទេរនៅចុងគ្រា ដែលជាសិទ្ធិរបស់ភាគីដៃគូទាមទារសាច់ប្រាក់ ឬទ្រព្យសម្បត្តិផ្សេងទៀត (ភាគហ៊ុនទទួលបានសិទ្ធិបានផ្ទេរ)។

៥២ ប្រសិនបើព័ត៌មានដែលតំរូវឱ្យលាតត្រដាង ដោយ ស.រ.ហ.អ នេះមិនអាចបំពេញបាននូវគោលការណ៍ ក្នុងកថាខណ្ឌ៤៤ ៤៦ និង៥០ ក្រុមហ៊ុនត្រូវលាតត្រដាងព័ត៌មានបន្ថែមនេះ ដោយការចាំបាច់ ដើម្បីបំពេញការពេញចិត្តរបស់អ្នកប្រើប្រាស់។

## បទប្បញ្ញត្តិអន្តរកាល

៥៣ សម្រាប់ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដោយទូទាត់ជាទ្រព្យម្ចាស់ ក្រុមហ៊ុនត្រូវអនុវត្តនូវ ស.រ.ហ.អ នេះដើម្បីផ្តល់ភាគហ៊ុន សិទ្ធិទិញភាគហ៊ុននាពេលអនាគត ឬឧបករណ៍ទ្រព្យម្ចាស់ដ៏ទៃៗទៀត ដែលត្រូវបានផ្តល់ក្រោយថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០២ ហើយមិនទាន់បានផ្ទេរនៅថ្ងៃចូលជាធរមាននៃស.រ.ហ.អ នេះ។

៥៤ ក្រុមហ៊ុនត្រូវបានលើកទឹកចិត្ត ប៉ុន្តែមិនតំរូវឱ្យអនុវត្តនូវ ស.រ.ហ.អ នេះដើម្បីផ្តល់នូវឧបករណ៍ទ្រព្យម្ចាស់ ប្រសិនបើក្រុមហ៊ុនបានលាតត្រដាង

ជាសាធារណៈនូវតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់ ដែលបានកំណត់នៅថ្ងៃវាស់វែង។

៥៥ សម្រាប់ការផ្តល់ឧបករណ៍ទ្រព្យម្ចាស់ដែលអនុវត្តស.រ.ហ.អ នេះ ក្រុមហ៊ុនត្រូវរាយការណ៍ឡើងវិញនូវ ព័ត៌មានប្រៀបធៀប និងបើអាចអនុវត្តបានកែតំរូវនូវសមតុល្យដើមគ្រា នៃប្រាក់ចំណេញរក្សាទុកសម្រាប់ គ្រាដើមដំបូងដែលបានបង្ហាញ។

៥៦ សម្រាប់រាល់ការផ្តល់នូវឧបករណ៍ទ្រព្យម្ចាស់ដែល ស.រ.ហ.អ នេះមិនទាន់អាចអនុវត្តបាន (ឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់នៅមុន និងនាថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០២) ក្រុមហ៊ុនត្រូវលាត្រដាងព័ត៌មានដែលតំរូវដោយកថាខ័ណ្ឌ៤៤និង៤៥។

៥៧ ក្រោយពេលស.ហ.រ.អ ចូលជាធរមាន ប្រសិនបើ ក្រុមហ៊ុនកែតំរូវរយៈពេល និងលក្ខខណ្ឌនៃការផ្តល់ ឧបករណ៍ទ្រព្យម្ចាស់ដែល ស.ហ.រ.អ នេះមិនទាន់ត្រូវបានដាក់ឱ្យប្រើប្រាស់ ក្រុមហ៊ុនត្រូវប្រើប្រាស់ កថាខ័ណ្ឌ២៦-២៩ ដើម្បីកត់ត្រាការកែសំរួលនេះ។

៥៨ សម្រាប់បំណុលកើតឡើងពីប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដែលមានអត្ថិភាពនាថ្ងៃចូលជាធរមាន របស់ ស.រ.ហ.អ នេះ ក្រុមហ៊ុនត្រូវអនុវត្តនូវស.រ.ហ.អ នេះត្រលប់ក្រោយ។ ចំពោះបំណុលទាំងនេះ ក្រុមហ៊ុនត្រូវរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀប ដោយរួមទាំងការកែតំរូវនូវសមតុល្យដើមគ្រានៃ ប្រាក់ចំណេញរក្សាទុកនាគ្រាដើមបំផុត ដែលបានបង្ហាញ ដែលព័ត៌មានប្រៀបធៀបត្រូវបានរាយការណ៍ឡើងវិញ លើកលែងថាក្រុមហ៊ុនមិនតំរូវឱ្យរាយការណ៍ឡើងវិញនូវព័ត៌មានប្រៀបធៀបចំពោះព័ត៌មានទាក់ទងនឹងគ្រាឬមុនពេលថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០២។

៥៩ ក្រុមហ៊ុនត្រូវបានលើកទឹកចិត្ត ប៉ុន្តែមិនតំរូវឱ្យអនុវត្តត្រលប់ក្រោយនូវ ស.រ.ហ.អ នេះចំពោះបំណុលដែលកើតឡើងពីប្រតិបត្តិការទូទាត់ផ្អែកតាម ភាគហ៊ុន ដូចជាបំណុលដែលត្រូវបានទូទាត់ជំរះ នៅកំឡុងគ្រា ដែល ព័ត៌មានប្រៀបធៀបត្រូវបានបង្ហាញ។

## ថ្ងៃចូលជាធរមាន

៦០ ក្រុមហ៊ុនត្រូវអនុវត្តស.រ.ហ.អនេះជាប្រចាំឆ្នាំ ចាប់ផ្តើមពីឬក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ការអនុវត្តមុនពេលនេះត្រូវបានលើកទឹកចិត្ត។ ប្រសិនបើក្រុមហ៊ុនអនុវត្តនូវស.រ.ហ.អ នេះសម្រាប់គ្រា ចាប់ផ្តើមមុន ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ក្រុមហ៊ុនត្រូវលាតត្រដាងហេតុការណ៍នេះ។

៦១ ស.រ.ហ.អ ៣ (បានកែសំរួលឡើងវិញឆ្នាំ២០០៨) និង*ការធ្វើឱ្យប្រសើរ ឡើងនូវស.រ.ហ.អ* ចេញផ្សាយនៅ ខែមេសា ឆ្នាំ២០០៩ បានកែសំរួល កថាខ័ណ្ឌ៥។ ក្រុមហ៊ុនត្រូវអនុវត្ត នូវការកែសំរួលទាំងនោះចំពោះគ្រា ប្រចាំឆ្នាំចាប់តាំងពី ឬមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩ ការអនុវត្តន៍មុន ពេលនេះត្រូវបានអនុញ្ញាត។ ប្រសិនបើ ក្រុមហ៊ុនអនុវត្តស.រ.ហ.អ ៣ (បានកែសំរួលឡើងវិញឆ្នាំ២០០៨) ចំពោះគ្រាមុនបង្អស់ ការកែសំរួលក៏ ត្រូវអនុវត្តសម្រាប់គ្រាមុនបង្អស់ដែរ។

៦២ ក្រុមហ៊ុនត្រូវអនុវត្តត្រលប់ក្រោយនូវការកែសំរួលខាងក្រោម ទៅក្នុងគ្រា ប្រចាំឆ្នាំចាប់ផ្តើមនៅ ឬមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ ហើយក្រុមហ៊ុន ត្រូវលាតត្រដាងព័ត៌មានទាំងនោះ :

(ក) លក្ខខណ្ឌក្នុងកថាខ័ណ្ឌ២១ក ទាក់ទងនឹងប្រព្រឹត្តកម្មនៃលក្ខខ័ណ្ឌ មិនផ្ទេរ

(ខ) និយមន័យដែលបានកែសំរួលនៃ "ការផ្ទេរ" និង "លក្ខខណ្ឌការផ្ទេរ" ក្នុងឧបសម្ព័ន្ធ ក

(គ) ការកែសំរួលក្នុងកថាខ័ណ្ឌ២៨ និង២៨ក ទាក់ទងនឹងការលប់

៦៣ ក្រុមហ៊ុនត្រូវអនុវត្តត្រលប់ក្រោយ នូវការកែសំរួលខាងក្រោម ដែលធ្វើឡើងដោយ*ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដែលទូទាត់ជាសាច់ប្រាក់របស់ក្រុម* ដែលបានចេញផ្សាយនៅខែមិថុនា ឆ្នាំ២០០៩ ដោយយោងតាមបទប្បញ្ញត្តិអន្តរកម្ម ក្នុងមាត្រា ៥៣-៥៩ ស្របតាមស.គ.អ ៨ *គោលនយោបាយគណនេយ្យ ការប្រែប្រួលនៃការប៉ាន់ស្មានគណនេយ្យ និងកំហុស* សម្រាប់គ្រាប្រចាំឆ្នាំចាប់ផ្តើមមុន ឬនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០:

(ក) ការកែសំរួលកថាខណ្ឌ ២ ការលប់កថាខ័ណ្ឌ៣ និងការបន្ថែមកថាខ័ណ្ឌ៣ក និង៤៣ក-៤៣ឃ ព្រមទាំងកថាខ័ណ្ឌខ៤៥ ខ៤៧ ខ៥០ ខ៥៦-៥៨ និងខ៦០ ពាក់ព័ន្ធនឹងគណនេយ្យកម្មនៃប្រតិបត្តិការក្នុងក្រុមនៃក្រុមហ៊ុន។

(ខ) និយមន័យបានកែសំរួលក្នុងឧបសម្ព័ន្ធ ក ចំពោះវាក្យស័ព្ទខាងក្រោម:

- ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដោយទូទាត់ជាសាច់ប្រាក់
- ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដោយទូទាត់ជាទ្រព្យម្ចាស់
- កិច្ចព្រមព្រៀងប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន និង
- ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន

ប្រសិនបើព័ត៌មានចាំបាច់សម្រាប់ការអនុវត្តត្រលប់ក្រោយ មិនអាចប្រើប្រាស់បានក្រុមហ៊ុនត្រូវឆ្លុះបញ្ចាំងក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ ដោយឡែក ឬទីមួយៗ នូវចំនួនដែលបានទទួលស្គាល់ ពីមុនជារបាយការណ៍ហិរញ្ញវត្ថុ រួមរបស់ក្រុម។ ការអនុវត្តន៍មុនពេលនេះត្រូវបានអនុញ្ញាត។ ប្រសិនបើក្រុមហ៊ុនអនុវត្តនូវការកែសំរួលចំពោះគ្រាចាប់ផ្តើមមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ ក្រុមហ៊ុនត្រូវលាតត្រដាងព័ត៌មានអំពីការណ៍នេះ។

## ការដកចេញនូវការបកស្រាយ

៦៤ ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដែលទូទាត់ជាសាច់ប្រាក់របស់ក្រុម ដែលបានចេញផ្សាយនៅខែ មិថុនា ឆ្នាំ២០០៩ មានភាពលើសលប់លើ គណៈកម្មការបកស្រាយស្តង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ ៨ វិសាលភាពនៃស.រ.ហ.អ ២ គណៈកម្មការបកស្រាយស្តង់ដារបាយ-ការណ៍ទាក់ទងហិរញ្ញវត្ថុ អន្តរជាតិ ១១ សរ.ហ.អ២ ស្តីពី*ប្រតិបត្តិការភាគហ៊ុនរបស់ក្រុម និងរតនាគារ*។ ការកែសំរួលដែលធ្វើដោយឯកសារនោះរួមបញ្ចូលទាំងលក្ខខណ្ឌតំរូវពីមុនដែលមានចែងក្នុងគណៈកម្មការបកស្រាយស្តង់ដា របាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ ៨ និងគណៈកម្មការបកស្រាយស្តង់ដារបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិ១១ ដូចខាងក្រោមៈ

(ក) កែសំរួលកថាខ័ណ្ឌ ២ និងបន្ថែមកថាខ័ណ្ឌ ១៣ក ទាក់ទងនឹងគណនេយ្យកម្ម នៃប្រតិបត្តិការដែល ក្រុមហ៊ុនមិនអាចកំណត់ជាក់លាក់នូវផ្នែកខ្លះ ឬទាំងអស់ នៃទំនិញ និងសេវាកម្មបានទទួល។ លក្ខខណ្ឌតំរូវនេះមានប្រសិទ្ធភាពចាប់តាំងពី និងក្រោយថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៦។

(ខ) បន្ថែមកថាខ័ណ្ឌខ៤៦ ខ៤៨ ខ៤៩ ខ៥១ -ខ៥៣ ខ៥៥ និង ខ៦១ ក្នុងឧបសម្ព័ន្ធ ខ ទាក់ទងនឹងគណនេយ្យកម្មនៃប្រតិបត្តិការរវាងក្រុមនៃក្រុមហ៊ុន។ លក្ខខណ្ឌទាំងនោះមានប្រសិទ្ធភាពចាប់តាំងពី និងក្រោយថ្ងៃទ០១ ខែមីនា ឆ្នាំ២០០៧។

លក្ខខណ្ឌគំរូវត្រូវបានអនុវត្តត្រលប់ក្រោយដោយមានលក្ខខណ្ឌគំរូវនៃស.គ.អ៨ ស្របតាមបទប្បញ្ញត្តិ អន្តរកាលនៃ ស.រ.ហ.អ ២។

## ឧបសម្ព័ន្ធក

## ការកំណត់ន័យវាក្យស័ព្ទ

( ឧបសម្ព័ន្ធនេះជាផ្នែកសំខាន់មួយនៃស.រ.ហ.អ )

| | |
|---|---|
| **ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដោយទូទាត់ជាសាច់ប្រាក់** | **ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន**មួយដែលក្រុមហ៊ុនទទួលបាននូវទំនិញឬសេវាកម្មដោយកើតមាននូវបំណុល ដើម្បីផ្ទេរសាច់ប្រាក់ ឬទ្រព្យ សម្បត្តិដ៏ទៃទៅឱ្យអ្នកផ្គត់ផ្គង់ទំនិញ ឬសេវា កម្មទាំងនោះនូវចំនួនដែលផ្អែកលើថ្លៃ (ឬតំលៃ) នៃ**ឧបករណ៍ ទ្រព្យម្ចាស់** (រួមមានភាគហ៊ុន ឬ**សិទ្ធិទិញភាគហ៊ុននាពេលអនាគត**) របស់ក្រុមហ៊ុន ឬក្រុមនៃក្រុមហ៊ុនដ៏ទៃទៀត |
| **និយោជិត និង អ្នកដ៏ទៃដែលផ្តល់ សេវកម្មប្រហាក់ប្រហែលគ្នា** | បុគ្គលដែលផ្តល់នូវសេវាកម្មផ្ទាល់ខ្លួនទៅឱ្យក្រុមហ៊ុន និងជា (ក)បុគ្គលដែលត្រូវចាត់ទុកជានិយោជិតតាមគោលបំណងពន្ធ (ខ) បុគ្គលធ្វើការឱ្យក្រុមហ៊ុនក្រោមការដឹកនាំរបស់ក្រុមហ៊ុនដែលដូចគ្នាទៅនឹងបុគ្គលដែលត្រូវចាត់ទុកជានិយោជិតតាមគោលបំណងពន្ធ ឬ (គ) សេវាដែលបានផ្តល់ស្រដៀងទៅនឹងសេវា ដែលត្រូវបានផ្តល់ដោយនិយោជិត ឧទាហរណ៍ ពាក្យនេះរួមបញ្ចូលរាល់បុគ្គលិក ដែលជាអ្នកគ្រប់ |

គ្រង គឺជាអ្នកដែលមាន អំណាច និងការទទួលខុសត្រូវចំពោះការធ្វើផែនការការដឹកនាំ និងការត្រួតពិនិត្យសកម្មភាពរបស់ក្រុមហ៊ុន ព្រមទាំងនាយក មិនប្រតិបត្តិទាំងឡាយផងដែរ។

**ឧបករណ៍ទ្រព្យម្ចាស់**

កិច្ចសន្យាមួយ ដែលជាភស្តុតាងនូវភាគកម្មដែលនៅសល់ ក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនក្រោយដកនូវរាល់បំណុល* ទាំងអស់

**ឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ឱ្យ**

សិទ្ធិ (មានលក្ខខណ្ឌ ឬគ្មានលក្ខខណ្ឌ) កាន់កាប់**ឧបករណ៍ទ្រព្យម្ចាស់** របស់ក្រុមហ៊ុន ដែលផ្តល់ដោយក្រុមហ៊ុនចំពោះភាគីមួយ ទៀតនៅក្រោម**ការព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន**

**ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដោយទូទាត់ជាទ្រព្យម្ចាស់**

**ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន** ដែលក្រុមហ៊ុន

(ក) បានទទួលទំនិញ ឬសេវាកម្មជាតំលៃតបស្នងសម្រាប់ **ឧបករណ៍ទ្រព្យម្ចាស់** របស់ខ្លួន (រួមមានភាគហ៊ុន ឬ**សិទ្ធិ**នៃ

---

* *ក្របខ័ណ្ឌទស្សនទាននៃការរាយការណ៍ហិរញ្ញវត្ថុ*បានកំណត់ន័យបំណុលជាកាតព្វកិច្ចបច្ចុប្បន្នរបស់ក្រុមហ៊ុនកើតឡើងពីព្រឹត្តការណ៍អតីតកាល ដែលការទូទាត់សងត្រូវបានរំពឹងថានឹងមានការហូរចេញនូវធនធានដោយភ្ជាប់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចពីក្រុមហ៊ុន (ជាការហូរចេញនូវសាច់ប្រាក់ ទ្រព្យសម្បត្តិដ៏ទៃទៀតពីក្រុមហ៊ុន)

**ការទិញភាគហ៊ុននាពេលអនាគត)**

(ខ) ទទួលទំនិញ ឬសេវាកម្ម ប៉ុន្តែមិនមានកាតព្វកិច្ច ដើម្បីជំរះទូទាត់ប្រតិបត្តិការជាមួយអ្នកផ្គត់ផ្គង់

**តំលៃសមស្រប**

ចំនួនទឹកប្រាក់ដែលទ្រព្យសម្បត្តិអាចត្រូវបានដោះដូរ បំណុល អាចត្រូវបានទូទាត់សង ឬ **ឧបករណ៍ទ្រព្យម្ចាស់បានផ្តល់** អាចត្រូវបានដោះដូរ រវាងភាគីដែលមានការយល់ដឹង និងមានបំណងនៅក្នុងប្រតិបត្តិការស្មើភាពគ្នា

**កាលបរិច្ឆេទផ្តល់**

ថ្ងៃដែលក្រុមហ៊ុន និងភាគីមួយទៀត (រួមទាំងនិយោជិត) យល់ព្រមលើ**កិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន** គឺជាពេលណា ដែលក្រុមហ៊ុន និងភាគីដៃគូមានការយល់ដឹងរួមលើរយៈពេល និងលក្ខខណ្ឌ នៃការព្រមព្រៀង។ នាកាលបរិច្ឆេទផ្តល់ ក្រុមហ៊ុន ផ្តល់ឱ្យភាគីដៃគូនូវសិទ្ធិទទួលសាច់ប្រាក់ ឬទ្រព្យសម្បត្តិដ៏ទៃទៀត ឬ**ឧបករណ៍ទ្រព្យម្ចាស់** របស់ក្រុមហ៊ុនដោយនាំមកនូវ ការបំពេញ**លក្ខខណ្ឌនៃការផ្ទេរជាក់លាក់**ប្រសិនបើមាន។ ប្រសិនបើការព្រមព្រៀង អាស្រ័យលើដំណើរការអនុម័ត

យល់ព្រម (ឧទាហរណ៍ ដោយភាគហ៊ុនិក) កាលបរិច្ឆេទផ្តល់ជាថ្ងៃ ដែលទទួលបានការអនុម័តយល់ព្រមនោះ

**តំលៃមជ្ឈន្តិកៈ:** ភាពខុសគ្នារវាង**តំលៃសមស្រប**របស់ភាគហ៊ុន ដែលភាគីដៃគូមានសិទ្ធិ (ដោយមានលក្ខខណ្ឌ ឬឥតលក្ខខណ្ឌ) ចូលរួម ឬមានសិទ្ធិទទួលជាមួយនិងថ្លៃ (ប្រសិនមាន) ដែលភាគីដៃគូ (ឬនឹង) ត្រូវការដើម្បីទូទាត់សងនូវភាគហ៊ុនទាំងនោះ ឧទាហរណ៍ **សិទ្ធិទិញភាគហ៊ុននាពេលអនាគត** ដែលមានថ្លៃអនុវត្ត CU 15* សម្រាប់ភាគហ៊ុនដែលមានតំលៃសមស្រប CU 20 ដូច្នេះមានតំលៃមជ្ឈន្តិកៈចំនួន CU5

**លក្ខខណ្ឌទីផ្សារ** លក្ខខណ្ឌដែលថ្លៃអនុវត្តអាចផ្ទេរ ឬអាចអនុវត្តបាននូវ**ឧបករណ៍ទ្រព្យម្ចាស់** អាស្រ័យលើពាក់ព័ន្ធទៅនឹងថ្លៃទីផ្សារនៃ **ឧបករណ៍ទ្រព្យម្ចាស់** របស់ក្រុមហ៊ុន ដូចជាការសម្រេចបាននូវថ្លៃភាគហ៊ុនជាក់លាក់ ឬចំនួនជាក់លាក់នៃ**តំលៃមជ្ឈន្តិកៈ**នៃ**សិទ្ធិទិញភាគហ៊ុននាពេលអនាគត**

* ក្នុងឧបសម្ព័ន្ធនេះ ចំនួនជារូបិយវត្ថុត្រូវបានកំណត់ជា "ឯកតារូបិយវត្ថុ (CU)"

ឬការសម្រេចបាននូវគោលដៅជាក់លាក់ដែលផ្អែកលើថ្លៃទីផ្សារនៃ**ឧបករណ៍ទ្រព្យម្ចាស់**របស់ក្រុមហ៊ុន ទាក់ទងទៅនឹងសន្ទស្សន៍ថ្លៃទីផ្សារនៃ**ឧបករណ៍ទ្រព្យម្ចាស់**របស់ក្រុមហ៊ុន

**កាលបរិច្ឆេទវាស់វែង**

ថ្ងៃដែល**តំលៃសមស្រប** នៃ**ឧបករណ៍ទ្រព្យម្ចាស់បានផ្តល់** ត្រូវបានវាស់វែងសម្រាប់គោលបំណងនៃស.រ.ហ.អនេះ។ ចំពោះ ប្រតិបត្តិការជាមួយ**និយោជិត និងអ្នកដ៏ទៃដែលផ្តល់សេវាប្រហាក់ប្រហែល** កាលបរិច្ឆេទវាស់វែងជាថ្ងៃផ្តល់។ ចំពោះ ប្រតិបត្តិការជាមួយភាគីផ្សេងក្រៅពីនិយោជិត (និងអ្នកដ៏ទៃដែលផ្តល់សេវាប្រហាក់ប្រហែល) កាលបរិច្ឆេទវាស់វែងជាថ្ងៃដែលក្រុមហ៊ុនទទួលបានានូវទំនិញ ឬភាគីដៃគូផ្តល់សេវាកម្ម

**លក្ខណៈបំពេញជាថ្មី**

លក្ខណៈដែលនាំមកនូវការផ្តល់ជាស្វ័យប្រវត្តិនូវ**សិទ្ធិទិញភាគហ៊ុននាពេលអនាគត** នៅពេលណា ដែលអ្នកកាន់កាប់សិទ្ធិបាន អនុវត្តសិទ្ធិទិញនាពេលអនាគតផ្តល់នាពេលមុន ដោយប្រើប្រាស់ភាគហ៊ុនរបស់ក្រុមហ៊ុន ជាជាងសាច់ប្រាក់ ដើម្បីបំពេញនូវថ្លៃអនុវត្ត

**ជំរើសបំពេញជាថ្មី**

**សិទ្ធិនៃការទិញភាគហ៊ុននាពេលអនាគត** បានផ្តល់នៅពេលដែល ភាគហ៊ុនត្រូវបានប្រើប្រាស់ដើម្បីបំពេញនូវថ្លៃអនុវត្តនៃ **សិទ្ធិទិញភាគហ៊ុននាពេលអនាគត** កាលពីមុន

**កិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន**

កិច្ចព្រមព្រៀងរវាងក្រុមហ៊ុន (ឬក្រុម*នៃក្រុមហ៊ុនមួយទៀត ឬភាគហ៊ុនិក ឬក្រុមនៃក្រុមហ៊ុនផ្សេងៗ) និង ភាគីមួយទៀត (រួមមាននិយោជិត) ដែលផ្តល់សិទ្ធិឱ្យភាគីមួយទៀតទទួលបាន:

(ក) សាច់ប្រាក់ ឬទ្រព្យសម្បត្តិផ្សេងទៀតរបស់ក្រុមហ៊ុន សម្រាប់ចំនួនទឹកប្រាក់ដែលអាស្រ័យលើថ្លៃ (ឬតំលៃ) នៃ **ឧបករណ៍ទ្រព្យម្ចាស់** (រួមមានភាគហ៊ុន ឬ **សិទ្ធិនៃការទិញភាគហ៊ុននាពេលអនាគត**) របស់ក្រុមហ៊ុន ឬក្រុមនៃក្រុមហ៊ុនមួយទៀត ឬ

(ខ) **ឧបករណ៍ទ្រព្យម្ចាស់** (រួមមានភាគហ៊ុន

---

* “ក្រុម” ត្រូវបានកំណត់ន័យក្នុងកថាខ័ណ្ឌ៤ នៃស.គ.អ២៧ *របាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែក* “ជាក្រុមហ៊ុនមេ និងបុត្រសម្ព័ន្ធទាំងអស់របស់ខ្លួន” ក្រោមទស្សនៈនៃក្រុមហ៊ុនមេរបស់ក្រុមហ៊ុនរាយការណ៍ចុងក្រោយ

ឬ**សិទ្ធិនៃការទិញ ភាគហ៊ុននាពេលអនាគត**) របស់ក្រុមហ៊ុន ឬក្រុមនៃក្រុមហ៊ុនមួយទៀតក្នុងករណីថា **លក្ខខណ្ឌនៃការផ្ទេរ**ជាក់លាក់ ប្រសិនបើមានត្រូវបានបំពេញ

| | |
|---|---|
| **ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន** | ប្រតិបត្តិការដែលក្រុមហ៊ុន<br>(ក) ទទួលទំនិញ ឬសេវាកម្ម ពីអ្នកផ្គត់ផ្គង់ទំនិញ ឬសេវាកម្មទាំងនោះ (រួមទាំងនិយោជិត)ក្រោម**កិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន**<br>(ខ) កើតឡើងនូវកាតព្វកិច្ចដើម្បីទូទាត់សងប្រតិបត្តិការ ជាមួយអ្នកផ្គត់ផ្គង់ទំនិញក្រោម**កិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន**នោះពេលដែលក្រុមមួយទៀតទទួលទំនិញ ឬសេវាទាំងនោះ |
| **សិទ្ធិទិញភាគហ៊ុននាពេលអនាគត** | កិច្ចសន្យាដែលផ្តល់ឱ្យអ្នកកាន់នូវសិទ្ធិ ប៉ុន្តែមិនមែនជាកាតព្វកិច្ច ដើម្បីចូលរួមចំពោះភាគហ៊ុនរបស់ក្រុមហ៊ុននាថ្ងៃថេរ ឬថ្ងៃបានកំណត់ទុកជាមុនមួយក្នុងរយៈពេលមួយជាក់លាក់ |

**ការផ្ទេរ**

ដើម្បីក្លាយជាមានសិទ្ធិ។ នៅក្រោម**កិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន** សិទ្ធិរបស់ភាគីដៃគូ ដើម្បីទទួលបានសាច់ប្រាក់ ទ្រព្យសម្បត្តិផ្សេងទៀត ឬ**ឧបករណ៍ហិរញ្ញវត្ថុ** របស់ក្រុមហ៊ុនផ្ទេរ នៅពេលដែល សិទ្ធិអនុញ្ញាតរបស់ភាគីដៃគូមិនមានលក្ខខណ្ឌជា បន្តទៀតលើការបំពេញតាម**លក្ខខណ្ឌនៃការផ្ទេរ**

**លក្ខខណ្ឌនៃការផ្ទេរ**

លក្ខខណ្ឌដែលកំណត់ថាតើក្រុមហ៊ុនទទួលសេវាដែលផ្តល់សិទ្ធិ ដល់ភាគីដៃគូនូវការទទួលជាសាច់ប្រាក់ទ្រព្យសម្បត្តិផ្សេងទៀត ឬ**ឧបករណ៍ហិរញ្ញវត្ថុ**នៅក្រោម**កិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន**។ លក្ខខណ្ឌនៃការផ្ទេរអាចជាលក្ខខណ្ឌសេវាឬលក្ខខណ្ឌប្រតិបត្តិ។លក្ខខណ្ឌសេវាតំរូវឱ្យភាគីដៃគូបំពេញនូវ រយៈពេលជាក់លាក់នៃសេវាកម្ម។ លក្ខខណ្ឌប្រតិបត្តិតំរូវឱ្យភាគី ដៃគូបំពេញនូវរយៈពេលជាក់លាក់ នៃសេវាកម្ម ព្រមទាំងគោល ដៅនៃកិច្ចប្រតិបត្តិជាក់លាក់ (ដូចជាការកើនឡើងជាក់លាក់នៃប្រាក់ចំណេញ របស់ក្រុមហ៊ុនក្នុងរយៈពេលជាក់លាក់)។ លក្ខខណ្ឌប្រតិបត្តិអាចរួមមាន **លក្ខខណ្ឌទីផ្សារ**

| | |
|---|---|
| **រយៈពេលផ្ទេរ** | រយៈពេលក្នុងកំឡុងពេលដែល**លក្ខខណ្ឌការផ្ទេរនៃកិច្ចព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន**ត្រូវបានបំពេញ |

## ឧបសម្ព័ន្ធខ

## គោលការណ៍ណែនាំអនុវត្ត

*ឧបសម្ព័ន្ធនេះជាផ្នែកមួយសំខាន់នៃស.រ.ហ.អនេះ*

### ការប៉ាន់ស្មាននូវតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់

ខ១ កថាខ័ណ្ឌខ២-៤១ នៃឧបសម្ព័ន្ធនេះពិភាក្សាអំពីការវាស់វែងនូវតំលៃសមស្របនៃភាគហ៊ុន និងសិទ្ធិទិញ ភាគហ៊ុននាពេលអនាគត ដែលបានផ្តល់ ដោយផ្តោតទៅលើរយៈពេល និងលក្ខខណ្ឌជាក់លាក់ទាំងឡាយដែលជាលក្ខណៈរួមនៃការផ្តល់ភាគហ៊ុន ឬសិទ្ធិទិញភាគហ៊ុន នាពេលអនាគតទៅឱ្យនិយោជិត ដូច្នេះវាមិនមានលក្ខណៈល្អិតល្អន់ទេ។ ជាបន្ថែមដោយសារតែបញ្ហាវាយតំលៃដែលពិភាក្សាខាងក្រោមផ្តោតលើភាគហ៊ុន និងសិទ្ធិទិញភាគហ៊ុន នាពេលអនាគត ដែលបានផ្តល់ដល់និយោជិត ដូចនេះវាត្រូវបានសន្មតថា តំលៃសមស្រប នៃភាគហ៊ុន និងសិទ្ធិទិញភាគហ៊ុននាពេលអនាគតត្រូវបានវាស់វែងនាកាលបរិច្ឆេទផ្តល់។ ប៉ុន្តែបញ្ហានៃការវាយតំលៃជាច្រើនពិភាក្សាខាងក្រោម (ឧ. ការកំណត់នូវភាពប្រែប្រួល) ក៏ប្រើប្រាស់ផង ដែរក្នុងបរិបទនៃការប៉ាន់ស្មាននូវតំលៃសមស្របនៃភាគហ៊ុន និងសិទ្ធិទិញភាគហ៊ុននាពេលអនាគត ដែលបានផ្តល់ដល់ភាគីដ៏ទៃក្រៅពីនិយោជិតនាថ្ងៃ ដែលក្រុមហ៊ុនទទួលទំនិញ ឬភាគីដៃគូផ្តល់សេវាកម្ម។

### ភាគហ៊ុន

ខ២ ចំពោះភាគហ៊ុនបានផ្តល់ទៅឱ្យនិយោជិត តំលៃសមស្របនៃភាគហ៊ុនត្រូវបានវាស់វែងតាមថ្លៃទីផ្សារនៃ ភាគហ៊ុនរបស់ក្រុមហ៊ុន (តាមថ្លៃទីផ្សារ

ប៉ាន់ស្មាន ប្រសិនបើ ភាគហ៊ុនរបស់ក្រុមហ៊ុនមិនបានធ្វើពាណិជ្ជកម្ម ជាសាធារណៈ) ដោយកែតម្រូវតាមលក្ខខ័ណ្ឌ និងស្ថានភាពដែលភាគហ៊ុនត្រូវបានផ្តល់ (លើកលែង លក្ខខណ្ឌផ្ទេរដែលមិនរួមបញ្ចូលក្នុងការវាស់វែងតំលៃសមស្របគោរពតាមកថាខណ្ឌ១៩-២១)

ខ៣ ឧទាហរណ៍ បើសិនជានិយោជិតមិនត្រូវបានផ្តល់សិទ្ធិ ដើម្បីទទួលបាននូវភាគលាភក្នុងកំឡុងគ្រាផ្ទេរ កត្តានេះត្រូវយកមកគិតពេលប៉ាន់ស្មានតំលៃសមស្របនៃភាគហ៊ុនបានផ្តល់។ ដូចគ្នានេះដែរ ប្រសិនបើភាគ ហ៊ុនស្ថិតនៅក្រោមការដាក់កំហិតលើការផ្ទេរក្រោយរយៈពេលផ្ទេរ កត្តានេះត្រូវយកមកគិត ប៉ុន្តែចំពោះតែ ការដាក់កំហិតក្រោយរយៈពេលផ្ទេរមានឥទ្ធិពលដល់ថ្លៃ ដែលទីផ្សារចូលរួមមានបំណងនិងការយល់ដឹង អាចបង់ចំពោះភាគហ៊ុននោះប៉ុណ្ណោះ ឧទហរណ៍ ប្រសិនជាភាគហ៊ុនត្រូវបានធ្វើពាណិជ្ជ-កម្មយ៉ាងសកម្ម នៅក្នុងទីផ្សារជំរៅ និងមានសន្ទនីយភាព នោះការដាក់កំហិតលើក្រោយការផ្ទេរអាចមានឥទ្ធិពលតិចតួច លើថ្លៃដែលទីផ្សារចូលរួមដែលមានបំណងនិងការយល់ដឹងនឹងអាចបង់ចំពោះភាគហ៊ុនទាំងនោះ។ ការដាក់កំហិតលើការផ្ទេរ ឬការដាក់កំហិតផ្សេងទៀតដែលមានក្នុងកំឡុងពេលផ្ទេរត្រូវយកមកគិត នៅពេលប៉ាន់ស្មានតំលៃសមស្រប នាថ្ងៃផ្តល់ដោយសារការដាក់កំហិតទាំងអស់នោះបណ្តាលមកពីអត្ថិភាពនៃលក្ខខណ្ឌការផ្ទេរ ដែលត្រូវបានធ្វើគណនេយ្យកម្មតាមកថាខ័ណ្ឌ ១៩-២១។

## សិទ្ធិទិញភាគហ៊ុននាពេលអនាគត

ខ៤ ចំពោះសិទ្ធិទិញភាគហ៊ុននាពេលអនាគតដែលបានផ្តល់ទៅឱ្យនិយោជិតដែលក្នុងករណីជាច្រើនថ្លៃទីផ្សារ មិនអាចរកបានដោយសារតែសិទ្ធិទិញ

នាពេលអនាគតបានផ្ដល់ស្ថិតនៅក្រោមរយៈពេល និងលក្ខខណ្ឌ មិនអាចប្រើប្រាស់តាមសិទ្ធិទិញនាពេលអនាគតដែលធ្វើពាណិជ្ជកម្ម។ ប្រសិនបើសិទ្ធិទិញនាពេលអនាគត បានធ្វើពាណិជ្ជកម្មដោយមានរយៈពេល និងលក្ខខណ្ឌស្រដៀងគ្នាមិនមានតំលៃសមស្របនៃសិទ្ធិទិញ នាពេលអនាគតត្រូវប៉ាន់ស្មានដោយប្រើប្រាស់គំរូកំណត់ថ្លៃសិទ្ធិទិញនាពេលអនាគត។

១៥ ក្រុមហ៊ុនត្រូវពិចារណាកត្តានានាដែលទីផ្សារចូលរួមមានបំណង និងការយល់ដឹង អាចពិចារណាក្នុងការជ្រើសរើសនូវគំរូកំណត់ថ្លៃសិទ្ធិទិញ នាពេលអនាគត ដែលត្រូវយកមកអនុវត្ត ឧទាហរណ៍ សិទ្ធិទិញនាពេលអនាគតរបស់និយោជិតជាច្រើនមានអាយុវែង ដែលជាធម្មតាអាចអនុវត្តបានក្នុងកំឡុងគ្រារវាងថ្ងៃផ្ទេរ និងចុងបញ្ចប់នៃអាយុកាលរបស់សិទ្ធិទិញនាពេលអនាគត ហើយជាញឹកញាប់ត្រូវបានអនុវត្តមុនពេល។ កត្តាទាំងនេះអាចត្រូវបានពិចារណានៅពេលប៉ាន់ស្មានតំលៃសមស្របនៃសិទ្ធិទិញនាពេលអនាគតនោះថ្ងៃផ្ដល់ ក្រុមហ៊ុនជាច្រើន កត្តានេះអាចរាំងស្ទះការប្រើប្រាស់នូវ រូបមន្ត Black-Scholes-Merton ដែលមិនអនុញ្ញាតចំពោះលទ្ធភាពនៃការអនុវត្តនោះមុនអាយុកាលរបស់សិទ្ធិទិញ នាពេលអនាគត ហើយអាចមិន ឆ្លុះបញ្ចាំងសមស្របនូវឥទ្ធិពលនៃការរំពឹងទុកការអនុវត្តមុនពេល។ វាក៏មិនអនុញ្ញាតចំពោះលទ្ធភាព ដែលការប្រែប្រួលរំពឹងទុក និងធាតុចូលរបស់គំរូផ្សេងទៀតអាចខុសគ្នាក្នុងកំឡុងអាយុកាលរបស់សិទ្ធិទិញនាពេលអនាគត ប៉ុន្តែចំពោះសិទ្ធិទិញនាពេលអនាគត ដែលមានអាយុកាលខ្លី ឬដែលត្រូវតែអនុវត្ត នៅក្នុងកំឡុងពេលខ្លី ក្រោយពីកាលបរិច្ឆេទផ្ទេរ កត្តាដែលបានកំណត់ខាងលើអាចមិនត្រូវបានយកមកប្រើប្រាស់ទេ។ ក្នុងករណីនេះ រូបមន្ត Black-Scholes-Merton អាចផ្ដល់

នូវតំលៃដែលដូចគ្នាជាចំបង ទៅនឹងគំរូកំណត់ថ្លៃ នៃសិទ្ធិទិញ នាពេលអនាគតផ្សេងទៀត។

១៦ រាល់គំរូកំណត់ថ្លៃសិទ្ធិទិញនាពេលអនាគតទាំងអស់ត្រូវពិចារណានូវកត្តាខាងក្រោមៈ

(ក) ថ្លៃអនុវត្តនៃសិទ្ធិទិញនាពេលអនាគត

(ខ) អាយុកាលនៃសិទ្ធិទិញនាពេលអនាគត

(គ) ថ្លៃបច្ចុប្បន្ននៃភាគហ៊ុនជាគោល

(ឃ) ភាពប្រែប្រួលរំពឹងទុកនៃថ្លៃភាគហ៊ុន

(ង) ភាគលាភរំពឹងទុកលើភាគហ៊ុន (ប្រសិនបើសមស្រប) និង

(ច) ការប្រាក់ ដែលមិនមានហានិភ័យ សម្រាប់អាយុកាលរបស់សិទ្ធិទិញនាពេលអនាគត

១៧ កត្តាផ្សេងទៀត ដែលទីផ្សារចូលរួមមានបំណង និងការយល់ដឹង អាចពិចារណាក្នុងការកំណត់ថ្លៃត្រូវយកមកគិត (លើកលែងសម្រាប់ លក្ខខណ្ឌនៃការផ្ទេរ និងលក្ខណៈបំពេញជាថ្មី ដែលមិនរួមបញ្ចូលក្នុងការ វាស់វែងនូវតំលៃសមស្របអនុលោមតាមកថាខ័ណ្ឌ១៩-២២)

១៨ ឧទាហរណ៍ ជាទូទៅសិទ្ធិទិញភាគហ៊ុននាពេលអនាគតមួយបានផ្តល់ដល់និយោជិត មិនអាចអនុវត្តក្នុង កំឡុងពេលមួយជាក់លាក់ (ឧ. កំឡុងពេលនៃការផ្ទេរ ឬកំឡុងពេលដែលបានកំណត់ដោយនិយ័តករ មូលប័ត្រ) កត្តានេះត្រូវយកមកគិតប្រសិនបើគំរូកំណត់ថ្លៃសិទ្ធិទិញនាពេលអនាគត អាចត្រូវបានអនុវត្ត គ្រប់ពេលវេលា ក្នុងកំឡុងអាយុកាលរបស់វា។ ប៉ុន្តែប្រសិនបើក្រុមហ៊ុនប្រើប្រាស់គំរូកំណត់ថ្លៃសិទ្ធិទិញនាពេលអនាគត ដែលផ្តល់តំលៃសិទ្ធិទិញ នាពេលអនាគត ដែលអាចអនុវត្តនាចុងអាយុកាល

ប៉ុណ្ណោះ មិនមានត្រូវការការកែតម្រូវ ចំពោះអសមត្ថភាពអនុវត្តសិទ្ធិទិញនាពេលអនាគតទាំងនោះក្នុងកំឡុងពេលផ្ទេរ (ឬគ្រាផ្សេងទៀតក្នុងកំឡុងអាយុកាលរបស់សិទ្ធិទិញ នាពេលអនាគត) ពីព្រោះតម្រូវសន្មតថាសិទ្ធិទិញនាពេលអនាគតមិនអាចអនុវត្តបាននៅរយៈពេលនោះទេ។

ខ៩ ដូចគ្នានេះដែរ កត្តារួមផ្សេងទៀតចំពោះសិទ្ធិទិញ នាពេលអនាគតរបស់និយោជិត គឺជាលទ្ធភាពនៃការ អនុវត្តមុនពេលនៃសិទ្ធិទិញ នាពេលអនាគត ឧទាហរណ៍ ពីព្រោះសិទ្ធិទិញនាពេលអនាគតមិនអាចផ្ទេរបានដោយសេរី ឬដោយសារនិយោជិតត្រូវអនុវត្តរាល់សិទ្ធិទិញនាពេលអនាគតនៅពេលបញ្ចប់ការធ្វើការ។ ផលប៉ះពាល់ នៃការអនុវត្តមុនពេលរំពឹងទុកត្រូវយកមកពិចារណា ដូចមានក្នុងកថាខ័ណ្ឌខ១៦-២១។

ខ១០ កត្តាដែលទីផ្សារចូលរួមមានបំណង និងការយល់ដឹង នឹងមិនពិចារណាក្នុងការទូទាត់សងថ្លៃសិទ្ធិទិញភាគហ៊ុន នាពេលអនាគត (ឬឧបករណ៍ទ្រព្យម្ចាស់ផ្សេងទៀត) មិនត្រូវបានយកមកគិតនៅពេលប៉ាន់ស្មាន តំលៃសមស្របនៃសិទ្ធិទិញភាគហ៊ុននាពេលអនាគត (ឬឧបករណ៍ទ្រព្យម្ចាស់ផ្សេងទៀត)ដែលបានផ្តល់។ ឧទាហរណ៍ ចំពោះសិទ្ធិទិញភាគហ៊ុននាពេលអនាគតបានផ្តល់ដល់និយោជិត កត្តាដែលអាចមានឥទ្ធិពល លើតំលៃនៃសិទ្ធិទិញនាពេលអនាគតពីទស្សនៈរបស់និយោជិតប៉ុណ្ណោះ មិនទាក់ទងនឹងការប៉ាន់ស្មាននូវ តំលៃដែលអាចកំណត់ ដោយទីផ្សារចូលរួមមានបំណង និងការយល់ដឹង។

## ធាតុចូលចំពោះគំរូកំណត់ថ្លៃទិញនាពេលអនាគត

១១១ ក្នុងការប៉ាន់ស្មាននូវការប្រែប្រួលរំពឹងទុក និងភាគលាភរបស់ភាគហ៊ុនគោល កម្មវត្ថុគឺត្រូវធ្វើការប្រហាក់ ប្រហែលនូងការរំពឹងទុក ដែលអាចមានឆ្លុះបញ្ចាំងក្នុងទីផ្សារបច្ចុប្បន្ន ឬថ្លៃដោះដូរបានចរចាររបស់សិទ្ធិទិញ នាពេលអនាគត។ ដូចគ្នានេះ នៅពេលប៉ាន់ស្មាននូងផលប៉ះពាល់ នៃការអនុវត្តមុនរបស់សិទ្ធិទិញនាពេលអនាគតរបស់និយោជិតកម្មវត្ថុ គឺត្រូវធ្វើការប្រហាក់ប្រហែលនូវការរំពឹងទុកដែលភាគីខាងក្រៅដែលបានចូលទៅដល់ព័ត៌មានលំអិតអំពីឥរិយាបទអនុវត្តរបស់និយោជិត អាចបង្កើតជាមូលដ្ឋានគោលដែលអាចរកបាននាកាលបរិច្ឆេទផ្ទេរ។

១១២ ជាញឹកញាប់ វាអាចមានលំដាប់នៃការរំពឹងទុកសមហេតុផលជាច្រើន អំពីការប្រែប្រួលនាពេលអនាគត ភាគលាភ និងឥរិយាបទរបស់និយោជិត ប្រសិនបើជាដូច្នេះ តំលៃរំពឹងទុកត្រូវគណនាដោយថ្លឹងចំនួន ទឹកប្រាក់នីមួយៗ ក្នុងលំដាប់ដោយប្រូបាប៊ីលីតេនៃការកើតមានរបស់វា។

១១៣ ការរំពឹងទុកស្ដីអំពីអនាគតជាទូទៅអាស្រ័យលើបទពិសោធន៍ និងត្រូវបានកែសំរួលប្រសិនបើអនាគតដែល បានរំពឹងទុកយ៉ាងសមហេតុផលខុសពីអតីតកាល។ ក្នុងកាលៈទេសៈខ្លះ កត្តាដែលអាចកំណត់បានអាច បង្ហាញថាបទពិសោធន៍ពីអតីតដែលត្រូវកែសំរួលគឺជាអ្នកព្យាករណ៍ដ៏ខ្សោយពីបទពិសោធន៍អនាគត។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុន ដែលមានស្រឡាយអាជីវកម្មខុសគ្នាចំនួនពីរ ការលក់ស្រឡាយអាជីវកម្មមួយដែលមានហានិភ័យតិចជាងយ៉ាងច្រើន ដូចនេះការប្រែប្រួលចាប្រវត្តិអាចមិនមែនជាព័ត៌មានប្រសើរបំផុត ដែលផ្អែកលើការរំពឹងទុកសមហេតុផលនាពេលអនាគត។

១១៤ ក្នុងកាលៈទេសៈផ្សេងទៀត ព័ត៌មានប្រវត្តិមិនអាចរកបានទេ ឧទាហរណ៍ ក្រុមហ៊ុនដែលទើបចុះបញ្ជីថ្មី នឹងមានទិន្នន័យជាប្រវត្តិតិចតួច ស្ដីពីភាពប្រែប្រួលនៃថ្លៃភាគហ៊ុន។ ក្រុមហ៊ុនដែលមិនចុះបញ្ជីនិងចុះបញ្ជីថ្មីពិភាក្សាខាងក្រោម។

១១៥ សរុបមក ក្រុមហ៊ុនមួយមិនគួរគ្រាន់តែផ្អែកលើការប៉ាន់ស្មានភាពប្រែប្រួលឥរិយាបទនិយោជិត និងភាគលាភផ្អែកលើព័ត៌មានជាប្រវត្តិ ដោយមិនពិចារណានូវទំហំដែលបទពិសោធន៍អតីតកាលត្រូវបានរំពឹងទុកថា ជាការព្យាករណ៍សមហេតុផលនៃបទពិសោធន៍អនាគត។

## ការអនុវត្តមុនពេលដែលបានរំពឹងទុក

១១៦ និយោជិតច្រើនតែអនុវត្តសិទ្ធិទិញភាគហ៊ុន នាពេលអនាគត មុនពេលកំណត់ ដោយសារហេតុផលជាច្រើន ឧទាហរណ៍ សិទ្ធិទិញភាគហ៊ុននាពេលអនាគតរបស់និយោជិត ជាទូទៅមិនអាចផ្ទេរទៅមកបាន ដែលនាំឱ្យនិយោជិតអនុវត្តសិទ្ធិទិញភាគហ៊ុននាពេលអនាគតរបស់គេមុនពេលកំណត់ពីព្រោះនេះជាមធ្យោបាយតែមួយគត់ ដែលអាចឱ្យគេជំរះស្ថានភាពរបស់គេបាន។ រីឯនិយោជិតដែលឈប់ធ្វើការក៏តម្រូវ ឱ្យអនុវត្តនូវសិទ្ធិទិញភាគហ៊ុននាពេលអនាគតដែលបានផ្ទេរ ក្នុងកំឡុងពេលមួយខ្លីដែរ បើមិនដូច្នោះសិទ្ធិទិញភាគហ៊ុននាពេលអនាគតនឹងត្រូវដកហូត។ កត្តានេះធ្វើឱ្យមានការអនុវត្តន៍សិទ្ធិទិញភាគហ៊ុន នាពេលអនាគត មុនពេលកំណត់។ កត្តាផ្សេងទៀតដែលធ្វើឱ្យមានការអនុវត្តន៍មុនពេលកំណត់គឺការមិនចូលចិត្តហានិភ័យ និងការខ្វះខាតនូវពិពិធកម្មទ្រព្យសម្បត្តិ។

១១៧ មធ្យាបាយដែលផលប៉ះពាល់នៃការអនុវត្តន៍សិទ្ធិទិញភាគហ៊ុន នាពេលអនាគតមុនពេលកំណត់ ត្រូវបានធ្វើគណនេយ្យកម្ម អាស្រ័យនឹងប្រភេទនៃគំរូកំណត់ថ្លៃសិទ្ធិទិញនាពេលអនាគត ឧទាហរណ៍ ការអនុវត្តន៍មុនពេលកំណត់អាចត្រូវបានយកមកគិតដោយប្រើការប៉ាន់ស្មាននូវអាយុរបស់សិទ្ធិទិញនាពេលអនាគត (ចំពោះសិទ្ធិទិញភាគហ៊ុននាពេលអនាគតរបស់និយជិតគឺជារយៈពេលពីថ្ងៃផ្តល់ ដល់ថ្ងៃដែលសិទ្ធិទិញ នាពេលអនាគតរំពឹងថានឹងត្រូវអនុវត្ត) ធ្វើជាធនធាននៃគំរូកំណត់ថ្លៃ សិទ្ធិទិញនាពេលអនាគត (រូបមន្ត Black-Scholes-Merton)។ ម្យ៉ាងទៀតការអនុវត្តន៍មុនពេលកំណត់ដែលរំពឹងទុកអាចត្រូវបានយកគំរូតាមបន្សំរវាងផលបូក និងផលដក ឬគំរូកំណត់ថ្លៃសិទ្ធិទិញ នាពេលអនាគតដ៏ទៃទៀត ដែលប្រើប្រាស់នូវអាយុកាលជាធនធាន។

១១៨ កត្តាពិចារណាក្នុងការកំណត់ការអុវត្តន៍មុនពេលកំណត់រួមមានៈ

(ក) រយៈពេលនៃកំឡុងពេលផ្ទេរ ពីព្រោះសិទ្ធិទិញភាគហ៊ុន នាពេលអនាគតជាទូទៅមិនអាចត្រូវបាន អនុវត្តរហូតដល់ចុងនៃគ្រាផ្ទេរដូចនេះផលវិបាកការកំណត់វាយតំលៃនៃការអនុវត្តន៍មុនពេលកំណត់ គឺផ្អែកលើការសន្មតថាសិទ្ធិទិញនាពេលអនាគតនឹងត្រូវផ្ទេរ។ ផលវិបាកនៃលក្ខខណ្ឌផ្ទេរនេះមាននិយាយក្នុងកថាខ័ណ្ឌ ១៩-២១។

(ខ) រយៈពេលមធ្យមនៃសិទ្ធិទិញ នាពេលអនាគតប្រហាក់ប្រហែលគ្នាមាននៅសល់នាពេលអតីតកាល

(គ) ថ្លៃនៃភាគហ៊ុនគោល។ បទពិសោធន៍អាចបង្ហាញថា និយោជិតមានទំនោរអនុវត្តសិទ្ធិទិញ នាពេលអនាគត មុនកាលកំណត់នៅ

ពេលថ្លៃភាគហ៊ុនឈានដល់កំរិតមួយជាក់លាក់ ដែលច្រើនជាងថ្លៃ អនុវត្ត។

(ឃ) កំរិតនៃនិយោជិតនៅក្នុងក្រុមហ៊ុន។ឧទាហរណ៍ តាមបទពិសោធន៍បង្ហាញថានិយោជិតមានឋានៈ ខ្ពស់មានទំនោរអនុវត្តសិទ្ធិទិញ នាពេលអនាគតតិចជាងនិយោជិតដែលមានឋានៈទាបជាង (ពិភាក្សាបន្ថែមនៅកថាខ័ណ្ឌ២១)

(ង) ភាពប្រែប្រួលរំពឹងទុកនៃភាគហ៊ុនគោល។ ជាមធ្យម និយោជិតអាចមាននិន្នាការអនុវត្តសិទ្ធិទិញនាពេលអនាគតណាដែលមានភាពប្រែប្រួលខ្ពស់មុនពេលកំណត់ជាងភាគហ៊ុន ដែលមានភាពប្រែប្រួលទាបជាង។

១១៩ ដូចដែលបានកត់សំគាល់ក្នុងកថាខ័ណ្ឌ១១៧ ផលប៉ះពាល់នៃការអនុវត្តន៍មុពេលកំណត់ អាចត្រូវបានយកមកគិត ដោយប្រើប្រាស់ការប៉ាន់ស្មានអាយុកាលរបស់សិទ្ធិទិញនាពេលអនាគតជាធនធានក្នុងគំរូកំណត់ថ្លៃសិទ្ធិទិញនាពេលអនាគត។ នៅពេលប៉ាន់ស្មាននូវអាយុកាលរបស់សិទ្ធិទិញភាគហ៊ុននាពេលអនាគតដែលបានផ្តល់ទៅកាន់ក្រុមនិយោជិត ក្រុមហ៊ុនត្រូវផ្អែកការប៉ាន់ស្មានទាំងនោះលើអាយុកាលជាមធ្យមដ៏សមស្របសម្រាប់ក្រុមនិយោជិតទាំងមូល ឬលើអាយុកាលជាមធ្យមរបស់អនុក្រុមនិយោជិតដោយ ផ្អែកលើទិន្នន័យលំអិត ស្តីពីឥរិបទការអនុវត្តន៍របស់និយោជិត (ពិភាក្សាបន្ថែមខាងក្រោម)

១២០ ការបែងចែកសិទ្ធិទិញនាពេលអនាគតដែលបានផ្តល់ជាអំនោយដល់ក្រុមនិយោជិត ទៅតាមឥរិយាបទដូចៗគ្នាក្នុងការអនុវត្តន៍ គឺមានសារៈសំខាន់។ តំលៃសិទ្ធិទិញនាពេលអនាគតមិនស្របគ្នាតាមរយៈពេលនៃសិទ្ធិនោះទេ

តំលៃកើនឡើងតាមអត្រាថយចុះនៃចំនួនរយៈពេលរបស់សិទ្ធិទិញនាពេលអនាគត។ ឧទាហរណ៍ ប្រសិនបើការសន្មតផ្សេងៗទៀតស្មើគ្នា សូម្បីតែសិទ្ធិទិញនាពេលអនាគតរយៈពេល ២ឆ្នាំ មានតំលៃជាងសិទ្ធិទិញ នាពេលអនាគតរយៈពេល១ឆ្នាំ តែវាមិនបានមានតំលៃច្រើនជាងពីរដងនោះទេ។ នេះមានន័យថាការគណនាតំលៃសិទ្ធិទិញនាពេលអនាគតដែលបានប៉ាន់ស្មានផ្អែកលើមូលដ្ឋានអាយុកាលមធ្យមដែលប្រកបដោយភាពខុសគ្នាជាច្រើននៃអាយុកាលរបស់សិទ្ធិទិញនាពេលអនាគតនីមួយៗ នឹងអាចនាំឱ្យមានការរាយការណ៍លើសនូវតំលៃសមស្របសរុបនៃសិទ្ធិទិញនាពេលអនាគតបានផ្តល់។ ការញែកដោយឡែកពីគ្នានូវសិទ្ធិទិញ នាពេលអនាគតបានផ្តល់ជាក្រុមជាច្រើន ដែលក្រុមនីមួយៗមានលំដាប់អាយុកាលមិនសូវឃ្លាតគ្នា ដើម្បីរួមបញ្ចូលក្នុងអាយុកាលមធ្យមរបស់សិទ្ធិទិញ នាពេលអនាគតនោះ អាចជួយ កាត់បន្ថយនូវការរាយការណ៍លើស។

ខ២១ ការពិចារណាស្រដៀងគ្នាអាចយកទៅប្រើប្រាស់ចំពោះការប្រើប្រាស់បន្សំ ឬវិធីស្រដៀងៗនេះ។ ឧទាហរណ៍ បពិសោធន៍របស់ក្រុមហ៊ុនដែលផ្តល់យ៉ាងទូលាយនូវសិទ្ធិទិញនាពេលអនាគតទៅឱ្យនិយោជិត គ្រប់លំដាប់ថ្នាក់ អាចបង្ហាញថា អ្នកប្រតិបត្តិកំរិតខ្ពស់ មានទំនោរនឹងកាន់កាប់សិទ្ធិទិញនាពេលអនាគត របស់គេយូរជាងអ្នកគ្រប់គ្រងថ្នាក់កណ្តាល ក៏ដូចជាក្រុមដ៏ទៃទៀត។ ម្យ៉ាងទៀត និយោជិតដែលបានលើកទឹកចិត្ត ឬដែលតំរូវឱ្យកាន់កាប់នូវចំនួនអប្បរមានៃឧបករណ៍ទ្រព្យម្ចាស់របស់និយោជក រួមមានសិទ្ធិទិញនាពេលអនាគត អាចនឹងអនុវត្តនូវសិទ្ធិនេះយូរជាងអ្នកដែលមិនមានបញ្ញត្តិខាងលើនេះ។ ក្នុងស្ថានភាពបែបនេះការចែកនូវសិទ្ធិទិញ នាពេលអនាគតជាក្រុមនៃអ្នកទទួល ដែលមានឥរិយាបទអនុវត្តសិទ្ធិទិញ នា

ពេលអនាគតដូចៗគ្នា នឹងធ្វើឱ្យមានការប៉ាន់ស្មាននូវតំលៃសមស្របនៃសិទ្ធិទិញនាពេលអនាគតកាន់តែបានត្រឹមត្រូវ។

## ការប្រែប្រួលរំពឹងទុក

១២២ ការប្រែប្រួលរំពឹងទុក គឺជាការវាស់វែងនូវចំនួនដែលថ្លៃត្រូវបានរំពឹងថានឹងប្រែប្រួលក្នុងកំឡុងគ្រាមួយ។ ការវាស់វែងការប្រែប្រួលដែលប្រើក្នុងគំរូកំណត់ថ្លៃសិទ្ធិទិញ នាពេលអនាគត ជាស្តង់ដាបំរែបំរួលជាប្រចាំឆ្នាំ នៃអត្រារួមផ្សំជាបន្តនៃសំណងរបស់ភាគហ៊ុនក្នុងរយៈពេលមួយ។ ការប្រែប្រួលត្រូវបានបង្ហាញជាទំរង់ប្រចាំឆ្នាំ ដែលអាចប្រៀបធៀបបានមិនគិតពីរយៈពេលដែលបានប្រើប្រាស់ក្នុងការគណនា ឧទាហរណ៍ ការអង្កេតថ្លៃប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រចាំខែ។

១២៣ អត្រាសងត្រលប់ (ដែលអាចវិជ្ជមាន ឬអវិជ្ជមាន) នៃភាគហ៊ុន សម្រាប់រយៈពេលវាស់វែងនូវចំនួនដែល ភាគហ៊ុនបានផ្តល់អត្ថប្រយោជន៍ ជាភាគលាភ និងការកើនឡើង (ឬការរំលស់) នៃថ្លៃភាគហ៊ុន។

១២៤ ការប្រែប្រួលជាប្រចាំឆ្នាំរបស់ភាគហ៊ុនដែលរំពឹងទុក ជាកំរិតលំដាប់នៅក្នុងអត្រាសងបង្វិលរួមបញ្ចូលគ្នាជាប្រចាំដែលត្រូវបានរំពឹងទុកថាធ្លាក់ចុះប្រហែល២/៣នៃពេលវេលា។ ឧទាហរណ៍ សន្មតថាភាគហ៊ុនមួយមានប្រូបាប៊ីលីតេនៃអត្រាសងបង្វិលរួមបញ្ចូលគ្នាជាប្រចាំ ១២ ភាគរយ មានភាពប្រែប្រួល ៣០ ភាគរយមានន័យថាប្រូបាប៊ីលីតេ ដែលអត្រាអត្រាសងបង្វិលរបស់ភាគហ៊ុនក្នុងរយៈពេល១ឆ្នាំនឹងធ្លាក់រវាង ១៨ភាគរយ (១២%-៣០%) និង ៤២ ភាគរយ (១២ % + ៣០ % ) ជាចំនួនប្រហែលពីរភាគបី។ ប្រសិនបើថ្លៃភាគហ៊ុនចំនួន CU១០០ នាដើមឆ្នាំ និងមិនមាន

ការបង់ភាគលាភ ថ្លៃនាចុងឆ្នាំនឹងរំពឹងថានៅ ចន្លោះរវាង CU៨៣,៥៣ (CU ១០០ x $e^{-០,១៨}$) និង CU152–20 (CU ១០០ x $e^{-០,៤២}$) ប្រហាក់ប្រហែលពីរភាគបីនៃពេលវេលា។

១២៥ កត្តាត្រូវពិចារណាក្នុងការប៉ាន់ស្មានន្ទូវភាពប្រែប្រួលរំពឹងទុកមានៈ

(ក) ភាពប្រែប្រួលដែលអនុវត្ត ពីសិទ្ធិទិញភាគហ៊ុននាពេលអនាគត ដែលបានធ្វើពាណិជ្ជកម្ម របស់ភាគហ៊ុនក្រុមហ៊ុន ឬឧបករណ៍ទ្រព្យម្ចាស់ដែលបានធ្វើពាណិជ្ជកម្មដ៏ទៃទៀតរបស់ក្រុមហ៊ុនដែលរួមមានលក្ខណៈសិទ្ធទិញនាពេលអនាគត (ដូចជាបំណុល ដែលអាចបំលែងបាន) ប្រសិនជាមាន

(ខ) ភាពប្រែប្រួលដំបូងនៃថ្លៃភាគហ៊ុនក្នុងកំឡុងពេលថ្មីៗ ដែលជាទូទៅសមាមាត្រទៅនឹងរយៈពេល រំពឹងទុករបស់សិទ្ធិទិញ នាពេលអនាគតដែលបានរំពឹងទុក (ដោយគិតពីអាយុកាលនៅសល់នៃសិទ្ធិ ទិញនាពេលអនាគត និងផលប៉ះពាល់នៃការអនុវត្តមុនពេលកំណត់)

(គ) រយៈពេល នៃភាគហ៊ុនក្រុមហ៊ុន ដែលបានធ្វើពាណិជ្ជកម្ម ជាសាធារណៈ។ ក្រុមហ៊ុនទើបចុះឈ្មោះថ្មី អាចមានភាពប្រែប្រួលជាប្រវត្តិខ្ពស់ ធៀបទៅនឹងក្រុមហ៊ុនដូចគ្នាដែលបានចុះឈ្មោះយូរជាង។ ការណែនាំបន្ថែមស្តីពីក្រុមហ៊ុន ទើបចុះឈ្មោះថ្មីនឹងមាននៅខាងក្រោម

(ឃ) ទំនោរនៃភាពប្រែប្រួលដើម្បីត្រលប់ទៅមធ្យមរបស់វា ដូចជាកំរិតមធ្យមរយៈពេលវែង និងកត្តាផ្សេងទៀត ដែលបង្ហាញថាភាពប្រែប្រួលនាពេលអនាគត អាចខុសពីការប្រែប្រួល ពីអតីត។

ឧទាហរណ៍ ប្រសិនបើថ្លៃភាគហ៊ុនក្រុមហ៊ុន មានភាពប្រែប្រួលយ៉ាងខ្លាំងក្នុងរយៈពេលកំណត់មួយ ដោយសារតែការខកខានមិនបានទទួលបាននូវការដេញថ្លៃ ឬការកែទិរង់ធំៗ រយៈពេលនោះនឹង មិនយកមកប្រើក្នុងការគណនាភាពប្រែប្រួលជាមធ្យមប្រចាំឆ្នាំជាប្រវត្តិ

(ង) រយៈពេលចន្លោះសមស្រប និងទៀងទាត់ចំពោះការអង្កេតថ្លៃ។ ការអង្កេតថ្លៃ ត្រូវស្របគ្នាពីគ្រា មួយទៅគ្រាមួយ ឧទាហរណ៍ ក្រុមហ៊ុនមួយអាចប្រើប្រាស់នូវថ្លៃបិទសម្រាប់ប្រចាំសប្តាហ៍ ឬថ្លៃខ្ពស់ជាងគេក្នុងសប្តាហ៍ ប៉ុន្តែក្រុមហ៊ុនមិនត្រូវប្រើប្រាស់ថ្លៃបិទនៃសប្តាហ៍មួយចំនួន និងថ្លៃខ្ពស់ជាងគេសម្រាប់សប្តាហ៍ផ្សេងៗ។ ដូចគ្នានេះ ការអង្កេតថ្លៃត្រូវបង្ហាញក្នុងរូបិយប័ណ្ណដូចគ្នានឹងថ្លៃអនុវត្ត។

## *ក្រុមហ៊ុនទើបបង្កើតថ្មី*

ខ២៦ ដូចមានកត់សំគាល់ក្នុងកថាខ័ណ្ឌ ២៥ ក្រុមហ៊ុនគួរពិចារណានូវភាពប្រែប្រួលជាប្រវត្តិនៃថ្លៃភាគហ៊ុន ក្នុងកឡុងពេលថ្មីៗបំផុត ដែលសមាមាត្រទៅនឹងរយៈពេលសិទ្ធិនៃការទិញទាពេលអនាគតដែលរំពឹងទុក។ បើសិនជាក្រុមហ៊ុនទើបចុះឈ្មោះថ្មីមិនមានព័ត៌មានគ្រប់គ្រាន់ស្តីពីការប្រែប្រួលជាប្រវត្តិទេ ក្រុមហ៊ុនត្រូវ គណនាភាពប្រែប្រួលជាប្រវត្តិសម្រាប់រយៈពេលដែលសកម្មភាពពាណិជ្ជកម្មអាចរកបាន។ ក្រុមហ៊ុនត្រូវពិចារណាផងដែរនូវការប្រែប្រួលជាប្រវត្តិនៃក្រុមហ៊ុនស្រដៀងគ្នាក្នុងរយៈពេលប្រៀបធៀបគ្នាបាននៃអាយុកាលរបស់វា។ ឧទាហរណ៍ ក្រុមហ៊ុនដែលបានចុះឈ្មោះ

រយៈពេលទើប ១ឆ្នាំ និងសិទ្ធិទិញ នាពេលអនាគតបានផ្តល់ឱ្យមានរយៈពេល ៥ឆ្នាំ អាចពិចារណាពីគំរូ នៃកំរិតភាពប្រែប្រួល ជាប្រវត្តិរបស់ក្រុមហ៊ុន នៅក្នុងឧស្សាហកម្មតែមួយក្នុងរយៈពេល៦ឆ្នាំដំបូង ដែលភាគហ៊ុនរបស់ក្រុមហ៊ុនទាំងនោះត្រូវបានធ្វើ ពាណិជ្ជកម្មជាសាធារណៈ។

### *ក្រុមហ៊ុនដែលមិនបានចុះឈ្មោះ*

ខ២៧ ក្រុមហ៊ុនមិនបានចុះឈ្មោះ នឹងមិនមានព័ត៌មានប្រវត្តិ ដើម្បីពិចារណានៅពេលប៉ាន់ស្មាន ការប្រែប្រួលដែលរំពឹងទុក។ កត្តាមួយចំនួនដើម្បីពិចារណាជំនួសមានចែងខាងក្រោម។

ខ២៨ ក្នុងករណីខ្លះ ក្រុមហ៊ុន ដែលមិនបានចុះឈ្មោះ បានបោះផ្សាយសិទ្ធិទិញនាពេលអនាគត ឬភាគហ៊ុនជាទៀងទាត់ទៅឱ្យនិយោជិត (ឬភាគីផ្សេងទៀត) អាចមានបង្កើតនូវទីផ្សារផ្ទៃក្នុងសម្រាប់ភាគហ៊ុនរបស់ខ្លួន។ ភាពប្រែ ប្រួលនៃថ្លៃភាគហ៊ុនទាំងនោះអាចត្រូវបានពិចារណានៅពេលប៉ាន់ស្មានពីភាពប្រែប្រួលដែលបានរំពឹងទុក។

ខ២៩ ម្យ៉ាងទៀត ក្រុមហ៊ុនអាចពិចារណានូវការប្រែប្រួលជាប្រវត្តិ ឬបានអនុវត្តនៃក្រុមហ៊ុនបានចុះឈ្មោះ ហើយមានលក្ខណៈស្រដៀងគ្នា ដែលព័ត៌មាននៃថ្លៃភាគហ៊ុន ឬថ្លៃសិទ្ធិទិញនាពេលអនាគតអាចរកបាន ដើម្បីប្រើប្រាស់នៅពេលប៉ាន់ស្មានការប្រែប្រួលរំពឹងទុក។ វាអាចសមស្រប ប្រសិនបើក្រុមហ៊ុនបានផ្អែកតំលៃភាគហ៊ុនរបស់ខ្លួន លើថ្លៃភាគហ៊ុន នៃក្រុមហ៊ុនចុះឈ្មោះស្រដៀងគ្នានេះ។

ខ៣០ ប្រសិនបើ ក្រុមហ៊ុនមិនបានផ្អែក នូវការប៉ាន់ស្មានតំលៃភាគហ៊ុនលើថ្លៃភាគហ៊ុនរបស់ក្រុមហ៊ុនស្រដៀងគ្នា ដែលបានចុះឈ្មោះ និងបានប្រើនូវ

វិធីសាស្ត្រវាយតំលៃផ្សេងទៀតដើម្បីកំណត់តំលៃភាគហ៊ុនរបស់ក្រុមហ៊ុន ដូចនេះក្រុមហ៊ុនអាចទាញការប៉ាន់ស្មានភាពប្រែប្រួលរំពឹងទុកស្របជាមួយ វិធីសាស្រស្តកំណត់តំលៃនោះ ឧទាហរណ៍ ក្រុមហ៊ុនអាចកំណត់តំលៃ ភាគហ៊ុនផ្អែកលើមូលដ្ឋានទ្រព្យសម្បត្តិពិត ឬមូលដ្ឋានចំណូលក្រុមហ៊ុន អាចពិចារណានូវការប្រែប្រួលដែលរំពឹងទុកនៃតំលៃទ្រព្យសម្បត្តិពិតឬចំណូលទាំងនោះ។

## ភាគលាភរំពឹងទុក

៦៣១ ការយកមកគិត នូវភាគលាភដែលរំពឹងទុក នៅពេលវាស់វែងតំលៃសមស្របនៃភាគហ៊ុន អាស្រ័យលើភាគី ដៃគូត្រូវបានអនុញ្ញាតទទួលភាគលាភ ឬភាគលាភសមមូល។

៦៣២ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនត្រូវបានផ្តល់នូវសិទ្ធិទិញនាពេលអនាគត និងត្រូវបានអនុញ្ញាតទទួលភាគលាភពីភាគហ៊ុនគោល ឬភាគលាភសម-មូល រវាងថ្ងៃដែលបានផ្តល់ និងថ្ងៃអនុវត្ត (ដែលអាចត្រូវបានបង់ជាសាច់ប្រាក់ ឬប្រើប្រាស់សម្រាប់កាត់បន្ថយថ្លៃអនុវត្ត) សិទ្ធិដែលបានផ្តល់ អាចត្រូវបានកំណត់តំលៃហាក់ ដូចជាមិនមានភាគលាភ ត្រូវបានបង់លើភាគហ៊ុនគោល គឺធនធាននៃភាគលាភដែលបានទទួលស្មើសូន្យ។

៦៣៣ ស្រដៀងគ្នានេះ នៅពេលតំលៃសមស្របនៃភាគហ៊ុនបានផ្តល់នៅថ្ងៃផ្តល់ឱ្យនិយោជិតត្រូវបានប៉ាន់ស្មាន មិនមានត្រូវការកែសម្រួល ចំពោះភាគលាភដែលរំពឹងទុក ប្រសិនបើនិយោជិតត្រូវបានអនុញ្ញាតចំពោះភាគលាភដែលបានបង់នៅកំឡុងពេលនៃការផ្ទេរ។

២៣៤ ផ្ទុយមកវិញ ប្រសិនបើនិយោជិតមិនត្រូវបានផ្តល់សិទ្ធិចំពោះភាគលាភ ឬភាគលាភសមមូល ក្នុងកំឡុងពេលនៃការផ្ទេរ (ឬមុនពេលអនុវត្តក្នុងករណីនៃសិទ្ធិនៃការទិញនាពេលអនាគត) ការកំណត់តំលៃ នាថ្ងៃផ្តល់នូវការមានសិទ្ធិចំពោះភាគហ៊ុន ឬសិទ្ធិទិញនាពេលអនាគតគួរតែយកភាគលាភដែលបានរំពឹងទុកមកគិតផងដែរ។គឺថានៅពេលដែលតំលៃសមស្រប នៃអំណោយជាសិទ្ធិទិញនាពេលអនាគតត្រូវបានប៉ាន់ស្មានភាគលាភ ដែលពឹងទុកត្រូវបញ្ចូល ក្នុងការប្រើប្រាស់ នូវគំរូកំណត់ថ្លៃសិទ្ធិទិញ នាពេលអនាគត។ នៅពេលដែលតំលៃសមស្របនៃអំណោយជាភាគហ៊ុន ត្រូវបានប៉ាន់ស្មាននោះ ការកំណត់តំលៃ ត្រូវបានកាត់បន្ថយ ដោយតំលៃបច្ចុប្បន្ននៃភាគលាភដែលរំពឹងទុកថានឹងបង់នៅក្នុងកំឡុងពេលផ្ទេរ។

២៣៥ ជាទូទៅគំរូកំណត់ថ្លៃសិទ្ធិទិញនាពេលអនាគត ត្រូវការអត្រាភាគលាភ។ ទោះជាយ៉ាងណាក៏ ដោយគំរូអាចត្រូវបានកែតំរូវ ដើម្បីប្រើប្រាស់ចំនួនភាគលាភបានរំពឹងទុក ជាជាងអត្រាភាគលាភ។ ក្រុមហ៊ុនមួយត្រូវប្រើប្រាស់ នូវអត្រាភាគលាភរំពឹងទុក ឬការសងភាគលាភ ដែលរំពឹងទុក។ ប្រសិនបើក្រុមហ៊ុនប្រើប្រាស់ជំរើសខាងក្រោយ ក្រុមហ៊ុនគួរពិចារណានូវគំរូជាប្រវត្តិនៃការកើនឡើងរបស់ភាគលាភ ឧទាហរណ៍ ប្រសិនបើ គោលនយោបាយក្រុមហ៊ុន មាននិន្នាការបង្កើននូវភាគលាភប្រហែល ៣ភាគរយក្នុងមួយឆ្នាំ តំលៃនៃសិទ្ធិទិញនាពេលអនាគតរំពឹងទុក មិនត្រូវសន្មតនូវចំនួនភាគលាភថេរក្នុងកំឡុងអាយុកាលរបស់សិទ្ធិទិញនាពេលអនាគត លើកលែងតែមានភស្តុតាងគាំទ្រការសន្មតនេះ។

២៣៦ ជាទូទៅ ការសន្មតលើភាគលាភដែលបានរំពឹងទុក គួរត្រូវផ្អែកលើព័ត៌មានដែលអាចរកបានជាសាធារណៈ ក្រុមហ៊ុនមួយដែលមិនបង់ភាគលាភ និង

មិនមានផែនការធ្វើដូច្នេះ ត្រូវសន្មតនូវអត្រាភាគលាភស្មើសូន្យ ប៉ុន្តែក្រុមហ៊ុនមានការប្រែប្រួលលឿន ដែលមិនមានប្រវត្តិបង់ភាគលាភ អាចរំពឹងនឹងចាប់ផ្តើមបង់ ភាគលាភនៅកំឡុងពេល នៃអាយុកាលសិទ្ធិទិញភាគហ៊ុន នាពេលអនាគតរបស់និយោជិតខ្លួន ក្រុមហ៊ុនទាំងនោះ អាចប្រើប្រាស់នូវអត្រាមធ្យម នៃភាគលាភអតីតកាលរបស់គេ (សូន្យ) និងមធ្យមនៃអត្រា ភាគលាភរបស់ក្រុមដូចគ្នាដែលអាចប្រៀបធៀបបាន។

## ការប្រាក់មិនមានហានិភ័យ

១៣៧ ជាទូទៅ អត្រាការប្រាក់មិនមានហានិភ័យ ជាអត្រាបច្ចុប្បន្ន ដែលអនុវត្តលើសញ្ញាប័ណ្ណរដ្ឋដែលគ្មានការប្រាក់ នៃប្រទេសមួយ ដែលមានរូបិយប័ណ្ណរបស់ថ្លៃអនុវត្តបានបង្ហាញ ដោយមានរយៈពេលនៅសល់ ស្មើនឹងរយៈពេលរបស់សិទ្ធិទិញនាពេលអនាគតដែលត្រូវកំណត់តំលៃ (ផ្អែកលើអាយុកាលនៅសល់នៃសិទ្ធិទិញនាពេលអនាគត ព្រមទាំងយកមកគិតនូវផលប៉ះពាល់នៃការអនុវត្តន៍មុនកាលកំណត់)។ ក្រុមហ៊ុន អាចចាំបាច់ប្រើប្រាស់នូវការជំនួសដែលសមស្រប ប្រសិនជាគ្មានការបោះផ្សាយរបស់រដ្ឋាភិបាល ឬកាលៈទេសៈបង្ហាញថា អត្រាត្រូវអនុវត្តនៃសញ្ញាប័ណ្ណរដ្ឋដែលគ្មានការប្រាក់ មិនមែនតំណាងឱ្យអត្រាការប្រាក់ គ្មានហានិភ័យ (ឧទាហរណ៍ ក្នុងសេដ្ឋកិច្ចមានអតិផរណាខ្ពស់)។ ការជំនួសដ៏សមស្របក៏ត្រូវ បានប្រើប្រាស់ផងដែរ ប្រសិនបើអ្នកចូលរួមទីផ្សារកំណត់នូវអត្រាការប្រាក់មិនមានហានិភ័យដោយប្រើប្រាស់ការជំនួសនោះ ជាជាងសញ្ញាប័ណ្ណរដ្ឋដែលគ្មានការប្រាក់ នៅពេលប៉ាន់ស្មាននូវតំលៃសមស្របនៃសិទ្ធិ

ទិញនាពេលអនាគតដែលមានអាយុកាលស្មើទៅនឹងរយៈពេលនៃសិទ្ធិទិញនាពេលអនាគតដែលត្រូវ កំណត់តំលៃ។

### ផលប៉ះពាល់នៃទំរង់មូលធន

១៣៨ ជាទូទៅ តតិយជនមិនមែនក្រុមហ៊ុនទេ ដែលជាអ្នកសរសេរនូវសិទ្ធិទិញភាគហ៊ុននាពេលអនាគតដែល បានធ្វើពាណិជ្ជកម្ម។ នៅពេលសិទ្ធិទិញភាគហ៊ុននាពេលអនាគតត្រូវបានអនុវត្ត អ្នកសរសេរប្រគល់ភាគហ៊ុនទៅឱ្យអ្នកកាន់កាប់សិទ្ធិទិញនាពេលអនាគត។ ភាគហ៊ុនទាំងនោះ ត្រូវបានទិញពីភាគហ៊ុនិក ដែលមានស្រាប់ ដូច្នេះការអនុវត្តនូវសិទ្ធិទិញភាគហ៊ុននាពេលអនាគតដែលបានធ្វើពាណិជ្ជកម្មមិនមាន ផលប៉ះពាល់នៃការកាត់បន្ថយ។

១៣៩ ផ្ទុយមកវិញ ប្រសិនបើ សិទ្ធិទិញភាគហ៊ុននាពេលអនាគតត្រូវបានសរសេរដោយក្រុមហ៊ុន ភាគហ៊ុនថ្មីត្រូវបានបោះផ្សាយនោះពេលសិទ្ធិទិញភាគហ៊ុននាពេលអនាគតទាំងនោះត្រូវបានអនុវត្ត (ទាំងបោះផ្សាយជាក់ស្តែង ឬបោះផ្សាយជាសារធាតុប្រសិនបើប្រើប្រាស់ភាគហ៊ុនត្រូវវបានទិញត្រលប់មកវិញកាលពីមុន និងត្រូវបានកាន់កាប់នៅរតនាគារ) ដូចនេះភាគហ៊ុននឹងបោះផ្សាយនូវថ្លៃអនុវត្ត ជាជាងថ្លៃទីផ្សារបច្ចុប្បន្ន នាថ្ងៃអនុវត្តការថយចុះជាក់ស្តែងឬជាសក្តានុពលនេះ អាចកាត់បន្ថយនូវថ្លៃភាគហ៊ុន ដូច្នេះអ្នកកាន់កាប់ ភាគហ៊ុនមិនមានការចំណេញច្រើន លើការអនុវត្តដូចការអនុវត្តន៍នូវសិទ្ធិទិញនាពេលអនាគតប្រហាក់ប្រហែលគ្នាដ៏ទៃដែលមិនមានការថយថ្លៃ។

១៤០ ការដែលវាអាចមានផលប៉ះពាល់ លើតំលៃនៃអំណោយជាសិទ្ធិទិញភាគហ៊ុន នាពេលអនាគតអាស្រ័យលើកត្តាផ្សេងៗ ដូចជាចំនួនភាគហ៊ុន ដែលនឹងត្រូវបោះផ្សាយនាពេលអនុវត្តសិទ្ធិទិញនាពេលអនាគត ធៀបជាមួយចំនួនភាគហ៊ុនដែលបានបោះផ្សាយរួច។ ប្រសិនបើទីផ្សាររំពឹងទុកជាស្រេចថាអំណោយជាសិទ្ធិទិញ នាពេលអនាគតនឹងកើតមានទីផ្សារអាចរួមបញ្ចូលនូវការថយចុះដែលអាចមានពេលគិតថ្លៃភាគហ៊ុននាថ្ងៃ ដែលបានផ្តល់អំណោយ។

១៤១ ក៏ប៉ុន្តែ ក្រុមហ៊ុនគួរពិចារណាថាតើ ភាពថយចុះដែលអាចមាន នាពេលអនុវត្តខាងមុខនូវសិទ្ធិទិញភាគហ៊ុននាពេលអនាគតដែលបានផ្តល់ អាចមានឥទ្ធិពលលើការប៉ាន់ស្មាននូវតំលៃសមស្របនាថ្ងៃផ្តល់។ គំរូកំណត់ថ្លៃសិទ្ធិទិញនាពេលអនាគតអាចត្រូវបានកែសម្រួល ដើម្បីយកមកពិចារ-ណា នូវផលប៉ះពាល់នៃការ ធ្លាក់ចុះដែលអាចមាន។

## ការកែសម្រួលនូវការព្រមព្រៀងបង់ដោយផ្អែកតាមភាគហ៊ុនតាមរយៈការទូទាត់ជាទ្រព្យម្ចាស់ និងជាភាគហ៊ុន

១៤២ កថាខ័ណ្ឌ ២៧ តំរូវថាដោយមិនគិតពីការកែសម្រួលលើរយៈពេល និងលក្ខខណ្ឌឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ឱ្យ ឬការលប់ ឬការទូទាត់ជំរះការផ្តល់ឧបករណ៍ទ្រព្យម្ចាស់នោះទេ ក្រុមហ៊ុនត្រូវទទួលស្គាល់ក្នុងកំរិតអប្បរមានូវទំនិញបានទទួលដែលវាស់វែងនៅថ្ងៃផ្តល់នូវតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បានផ្តល់ឱ្យ លើកលែងតែឧបករណ៍ទាំងនោះ មិនត្រូវបានផ្ទេរ ដោយសារការមិនបានបំពេញនូវលក្ខខណ្ឌការផ្ទេរត្រឹមត្រូវ (ក្រៅពីលក្ខខណ្ឌទីផ្សារ) ដូចដែលបានកំណត់នាថ្ងៃផ្តល់។ ជាបន្ថែម ក្រុម

ហ៊ុនត្រូវទទួលស្គាល់ ផលប៉ះពាល់នៃការកែសម្រួលដែលធ្វើឱ្យកើនឡើងនូវតំលៃសមស្រប នៃការព្រមព្រៀងទូទាត់តាមភាគហ៊ុន ឬធ្វើឱ្យមានប្រយោជន៍ដល់និយោជិត។

៦៤៣ ដើម្បីអនុវត្តតាមលក្ខខណ្ឌតំរូវនៃកថាខណ្ឌ២៧:

(ក) ប្រសិនបើ ការកែសំរួលបង្កើននូវតំលៃ សមស្របនៃឧបករណ៍ទ្រព្យម្ចាស់ ដែលបានផ្តល់អំណោយ (ឧ. ដោយកាតើបន្ថយថ្លៃអនុវត្ត) ដែលបានវាស់វែងភ្លាមៗនៅមុន និងក្រោយការសំរួល ក្រុមហ៊ុនត្រូវរួមបញ្ចូលការកើនឡើងនៃតំលៃសមស្របដែលបានផ្តល់ទៅក្នុងការវាស់វែងនៃចំនួនទទួល ស្គាល់សម្រាប់សេវាបានទទួល ថាជាតំលៃតបស្នងសម្រាប់ឧបករណ៍ទ្រព្យម្ចាស់ ដែលបានផ្តល់។ ការកើនឡើងនៃតំលៃសមស្របបានផ្តល់អំណោយ គឺជាភាពខុសគ្នារវាងតំលៃសមស្រប នៃឧបករណ៍ទ្រព្យម្ចាស់ ដែលបានកែសំរួលរួច និងឧបករណ៍ទ្រព្យម្ចាស់ដើម ដែលទាំងពីរត្រូវបាន វាស់វែងនាថ្ងៃកែសំរួល។ ប្រសិនបើការកែសំរួលកើតឡើងនៅកំឡុងពេលការផ្ទេរ ការកើនឡើងនៃ តំលៃសមស្របបានផ្តល់ត្រូវបានរួមបញ្ចូល ក្នុងការវាស់វែង នៃចំនួនបានទទួលស្គាល់សម្រាប់សេវា

បានទទួលក្នុងកំឡុងពេលពីថ្ងៃធ្វើការកែសំរួលរហូតដល់ថ្ងៃដែលឧបករណ៍ទ្រព្យម្ចាស់ ដែលកែសំរួលរួចត្រូវបានផ្ទេរ បន្ថែមទៅលើចំនួនដែលផ្អែកលើថ្ងៃផ្តល់នៃឧបករណ៍ទ្រព្យម្ចាស់ដើម ហើយដែលត្រូវទទួលស្គាល់ក្នុងកំឡុងពេលនៅសល់នៃរយៈពេលផ្ទេរ។ ប្រសិនបើការកែសំរួលកើតមាន ក្រោយរយៈពេលផ្ទេរ ការកើន

ឡើងនៃតំលៃសមស្រប ដែលបានផ្តល់ត្រូវទទួលស្គាល់ភ្លាមៗ ឬក្នុងកំឡុងរយៈពេលនៃការផ្ទេរ ប្រសិនបើ និយោជិតត្រូវបានទាមទារឱ្យបញ្ចប់នូវរយៈពេលបន្ថែម នៃការផ្តល់សេវាមុនពេលក្លាយជាមានសិទ្ធិ ដោយគ្មានលក្ខខណ្ឌលើឧបករណ៍ទ្រព្យម្ចាស់ដែលបានកែសំរួលទាំងនោះ។

(ខ) ស្រដៀងគ្នានេះដែរ ប្រសិនបើ ការកែសំរួលបង្កើននូវចំនួនឧបករណ៍ទ្រព្យម្ចាស់ ដែលបានផ្តល់អំណោយ ក្រុមហ៊ុនត្រូវរួមបញ្ចូលទៅក្នុងការវាស់វែងនូវចំនួនដែលត្រូវទទួលស្គាល់ចំពោះសេវាកម្មបានទទួល នូវតំលៃសមស្រប នៃឧបករណ៍ទ្រព្យម្ចាស់បន្ថែមដែលបានផ្តល់ បានវាស់វែងនាថ្ងៃកែសំរួល ដូចជាតំលៃតបស្នងនៃឧបបករណ៍ទ្រព្យម្ចាស់បានផ្តល់អំណោយ ដោយស្របតាមលក្ខខណ្ឌតំរូវ (ក) ខាងលើ។ ឧទាហរណ៍ ប្រសិនបើការកែសំរួលកើតមាននៅកំឡុងពេលនៃការផ្ទេរ តំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់បន្ថែមដែលបានផ្តល់ ត្រូវបានរួមបញ្ចូលទៅក្នុងការវាស់វែងនូវចំនួនដែលត្រូវទទួលស្គាល់ចំពោះសេវាកម្មបានទទួលក្នុងកំឡុងពេលមួយចាប់ពីថ្ងៃធ្វើការកែសំរួលរហូតដល់ថ្ងៃ ដែលឧបករណ៍ទ្រព្យម្ចាស់ត្រូវបានផ្ទេរបន្ថែមពីលើចំនួនដែលបានផ្អែកលើតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់ដំបូងដែលបានផ្តល់ឱ្យនាថ្ងៃផ្តល់អំណោយ ហើយត្រូវបានទទួលស្គាល់ក្នុងកំឡុងពេលនៅសល់នៃរយៈពេលផ្ទេរដំបូង។

(គ) ប្រសិនបើក្រុមហ៊ុនកែសំរួលនូវលក្ខខណ្ឌផ្ទេរក្នុងទំរង់ ដែលមានប្រយោជន៍ដល់និយោជិត ឧទាហរណ៍ ដោយកាត់បន្ថយនូវគ្រា

ផ្ទេរ ឬដោយកែសំរួល ឬដោយលប់ចេញនូវលក្ខខណ្ឌប្រតិបត្តិ (ក្រៅពីលក្ខខណ្ឌទីផ្សារការប្រែប្រួល ដែលត្រូវបានកត់ត្រាតាម (ក)ខាងលើ) ក្រុមហ៊ុនត្រូវទទួល យកលក្ខខណ្ឌផ្ទេរ ដែលបានកែសំរួលទៅគិតពេលអនុវត្តលក្ខខណ្ឌតំរូវនៃកថាខណ្ឌ១៩-២១។

ខ៤៤ បន្ថែមពីនេះទៀត ប្រសិនបើក្រុមហ៊ុនកែសំរួលនូវរយៈពេល និងលក្ខខណ្ឌនៃឧបករណ៍ទ្រព្យម្ចាស់បាន ផ្តល់ក្នុងលក្ខណៈកាត់បន្ថយនូវតំលៃសមស្របសរុបនៃការព្រមព្រៀងទូទាត់សងផ្អែកតាមភាគហ៊ុន ឬម្យ៉ាងទៀតមិនមានអត្ថប្រយោជន៍ចំពោះនិយោជិត ក្រុមហ៊ុនត្រូវបន្តការកត់ត្រាសេវាដែលបានទទួលដូចជាតំលៃតបស្នងនៃឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់ហាក់ដូចជាការកែសំរួលមិនបានកើតឡើង (ក្រៅពី ការលប់នូវផ្នែកខ្លះ ឬទាំងអស់នៃឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់ ដែលត្រូវកត់ត្រាតាមកថាខណ្ឌ ២៨) ឧទាហរណ៍:

(ក) ប្រសិនបើការកែសំរួលកាត់បន្ថយ តំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់ ដែលបានផ្តល់បានវាស់វែងភ្លាមៗមុន និងក្រោយការកែសំរួល ក្រុមហ៊ុនត្រូវគិតគូពីការធ្លាក់ចុះនៃតំលៃសមស្រប និងបន្ត វាស់វែងចំនួនដែលបានទទួលស្គាល់ ចំពោះសេវាបានទទួលដូចជាតំលៃតបស្នងនៃឧបករណ៍ទ្រព្យម្ចាស់ផ្អែកតាមតំលៃសមស្របនៃឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់នាថ្ងៃផ្តល់ឱ្យ។

(ខ) ប្រសិនបើការកែសំរួលកាត់បន្ថយ នូវចំនួនឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់ចំពោះនិយោជិត ការកាត់បន្ថយនោះនឹងត្រូវកត់ត្រាជាការលប់នូវផ្នែកនៃការផ្តល់នោះស្របតាមលក្ខខណ្ឌតំរូវនៃកថាខណ្ឌ២៨។

(គ) ប្រសិនបើក្រុមហ៊ុនកែសំរួលលក្ខខណ្ឌផ្ទេរ ក្នុងទំរង់ដែលមិនមានអត្ថប្រយោជន៍ដល់និយោជិត ឧទាហរណ៍ ដោយការបង្កើននូវរយៈពេលផ្ទេរ ឬដោយការកែសំរួល ឬបន្ថែមនូវលក្ខខណ្ឌប្រតិបត្តិ (ក្រៅពីលក្ខខណ្ឌទីផ្សារការប្រែប្រួល ដែលត្រូវបានកត់ត្រាតាម (ក)ខាងលើ) ក្រុមហ៊ុនមិនត្រូវយក ការកែសំរួលលើលក្ខខណ្ឌនៃការផ្ទេរមក គិតនៅពេលអនុវត្តនូវ លក្ខខណ្ឌតំរូវនៃ មាត្រា ១៩-២១។

## ប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនរវាងក្រុមនៃក្រុមហ៊ុន (ការធ្វើវិសោធនកម្មឆ្នាំ២០០៩)

ខ៤៥ កថាខណ្ឌ ៤៣ក-៤៣គ បង្ហាញពីការធ្វើគណនេយ្យកម្មនៃប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនរវាងក្រុមនៃក្រុមហ៊ុនក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ឬរបាយកាណ៍របស់ក្រុមហ៊ុននីមួយៗ។ កថាខ័ណ្ឌ ខ46-ខ៦១ ពិភាក្សាពីរបៀបដែលត្រូវអនុវត្តលក្ខខណ្ឌតំរូវនៃកថាខ័ណ្ឌ ៤៣ក-៤៣គ។ ដូចដែលបានកត់ សំគាល់ក្នុងកថាខ័ណ្ឌ ៤៣ឃ ថាប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនរវាងក្រុមនៃក្រុមហ៊ុនអាចធ្វើឡើង ក្នុងមូលហេតុជាច្រើនអាស្រ័យនឹងហេតុការណ៍ និងកាលៈទេសៈ។ ដូច្នេះ ការពិភាក្សានេះមិនមានលក្ខណៈល្អិតល្អន់ និងសន្មតថា នៅពេលក្រុមហ៊ុនទទួលនូវទំនិញ ឬសេវាកម្ម ដែលមិនមានកាតព្វកិច្ចជំរះទូទាត់សងប្រតិបត្តិការ ជាការរួមចំណែករបស់ក្រុមហ៊ុនមេ ចំពោះបុត្រសម្ព័ន្ធ ដោយមិនគិតពីកិច្ចការទូទាត់សង វិញនៅក្នុងក្រុមនោះទេ។

២៤៦ ទោះបីជាការពិភាក្សាខាងក្រោមផ្តោតលើប្រតិបត្តិការ ជាមួយនិយោជិត ក៏វាអាចអនុវត្តបានចំពោះប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដែលមានអ្នកផ្គត់ផ្គង់ទំនិញឬសេវាកម្មជានិយោជិត។ ការព្រមព្រៀងរវាងក្រុមហ៊ុនមេ និងបុត្រសម្ព័ន្ធ អាចតំរូវឱ្យបុត្រសម្ព័ន្ធសងក្រុមហ៊ុនមេ ចំពោះការផ្តល់នូវឧបករណ៍ទ្រព្យម្ចាស់ ដល់និយោជិត។ ការពិភាក្សាខាងក្រោមមិនបង្ហាញពីរបៀបកត់ត្រាចំពោះការព្រមព្រៀងទូទាត់សងរវាង ក្រុមនោះទេ។

២៤៧ មានបញ្ហាចំនួន ៤ ដែលត្រូវជួបប្រទះជារួម នៅក្នុងប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនរវាងក្រុមនៃក្រុមហ៊ុន។ ដើម្បីឱ្យកាន់តែងាយស្រួល ឧទាហរណ៍ខាងក្រោមពិភាក្សានូវបញ្ហា ក្រោមទំរង់ជាក្រុមហ៊ុនមេ និង បុត្រសម្ព័ន្ធរបស់វា។

## ការព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុនទាក់ទងនឹងឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនផ្ទាល់

២៤៨ បញ្ហាទីមួយគឺថាតើប្រតិបត្តិខាងក្រោម ទាក់ទងនឹងឧបករណ៍ទ្រព្យម្ចាស់ ត្រូវបានកត់ត្រាជាការជំរះជាទ្រព្យម្ចាស់ ឬជាសាច់ប្រាក់ ដោយអនុលោមតាមលក្ខខណ្ឌតំរូវនៃស.ហ.រ.អ នេះ។

(ក) ក្រុមហ៊ុនមួយ ផ្តល់អំណោយដល់និយោជិតនូវ សិទ្ធិកាន់កាប់ឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុន (ឧ. សិទ្ធិនៃការទិញភាគហ៊ុននាពេលអនាគត) និងអាចជ្រើសរើស ឬតំរូវឱ្យទិញនូវឧបករណ៍ទ្រព្យម្ចាស់ (ដូចជារតនះភាគហ៊ុន) ពីភាគីដ៏ទៃ ដើម្បីបំពេញនូវកាតព្វកិច្ចចំពោះនិយោជិត និង

(ខ) និយោជិតក្រុមហ៊ុនមួយ ត្រូវបានផ្តល់សិទ្ធិកាន់កាប់ ឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុន (ដូចជា រតនៈភាគហ៊ុន) តាមរយៈក្រុមហ៊ុនខ្លួនឯងឬដោយភាគហ៊ុនិក ហើយភាគហ៊ុនិកនៃក្រុមហ៊ុនផ្តល់នូវឧបករណ៍ទ្រព្យម្ចាស់ដែលត្រូវការ។

ខ៤៩ ក្រុមហ៊ុនត្រូវកត់ត្រាប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដែលក្រុមហ៊ុនទទួលសេវាកម្មជាតំលៃតបស្នងនៃ ឧបករណ៍ទ្រព្យម្ចាស់ដូចជាការទូទាត់ជំរះដោយទ្រព្យម្ចាស់។ វាត្រូវបានអនុវត្តចំពោះមិនថាតើក្រុមហ៊ុនជ្រើសឬត្រូវបានតំរូវឱ្យទិញឧបករណ៍ទ្រព្យម្ចាស់ទាំងនោះពីភាគីផ្សេង ដើម្បីបំពេញនូវកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងការទូទាត់ ផ្អែកតាមភាគហ៊ុន។ វាក៏ត្រូវបានអនុវត្តចំពោះដោយមិនគិតថាតើៈ

(ក) សិទ្ធិរបស់និយោជិត ចំពោះឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនដែលត្រូវបានផ្តល់ឱ្យដោយក្រុមហ៊ុនខ្លួនឯង ឬដោយភាគហ៊ុនិក ឬ

(ខ) ការព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន ត្រូវបានទូទាត់ជំរះដោយអង្គភាព ឬដោយភាគហ៊ុនិក

ខ៥០ ប្រសិនបើ ភាគហ៊ុនិក មានកាតព្វកិច្ចដើម្បីជំរះទូទាត់ នូវប្រតិបត្តិការជាមួយនិយោជិតរបស់អ្នកវិនិយោគ ភាគហុនិកនឹងផ្តល់ឧបករណ៍ទ្រព្យម្ចាស់របស់អ្នកវិនិយោគជាជាងរបស់ខ្លួន។ ដូច្នេះ ប្រសិនបើអ្នកវិនិយោគស្ថិតនៅក្នុងក្រុមតែមួយជាមួយភាគហ៊ុនិក ដោយអនុលោមតាមកថាខ័ណ្ឌ ៤៣ ភាគហ៊ុនិកត្រូវ វាស់វែងនូវកាតព្វកិច្ចស្របតាមលក្ខខណ្ឌតំរូវ ដែលអាចប្រើប្រាស់ចំពោះប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដោយជំរះសង តាមសាច់ប្រាក់ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក របស់

ភាគហ៊ុនិក និងចំពោះប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនដោយជំរះសង តាមទ្រព្យម្ចាស់ត្រូវកត់ត្រាក្នុងរបាយការណ៍ ហិរញ្ញវត្ថុរួម។

**ការព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុនទាក់ទងនឹងឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនមេ**

ខ៥១ បញ្ហាទីពីរ ពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុនទាក់ទងរវាងក្រុមហ៊ុនពីរ ឬច្រើនក្នុងក្រុមតែមួយ ពាក់ព័ន្ធនឹងឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមនៃក្រុមហ៊ុនដ៏ទៃ។ ឧទាហរណ៍ និយោជិតនៃបុត្រសម្ព័ន្ធត្រូវបានផ្តល់សិទ្ធិកាន់កាប់ឧករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនមេជាតំលៃតបស្នងចំពោះសេវាកម្មបានផ្តល់ដល់ ក្រុមហ៊ុនបុត្រសម្ព័ន្ធ។

ខ៥២ ដូច្នេះ បញ្ហាទីពីរទាក់ទងនឹងការព្រមព្រៀងទូទាត់សងផ្អែកតាមភាគហ៊ុនដូចខាងក្រោមៈ

(ក) ក្រុមហ៊ុនមេ ផ្តល់សិទ្ធិកាន់កាប់ឧបករណ៍ទ្រព្យម្ចាស់ដោយផ្ទាល់ដល់និយោជិតតនៃក្រុមហ៊ុនបុត្រសម្ព័ន្ធៈ ក្រុមហ៊ុនមេ (មិនមែនក្រុមហ៊ុនបុត្រសម្ព័ន្ធ) មានកាតព្វកិច្ចដើម្បីផ្តល់នូវនិយោជិតរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនូវឧបករណ៍ទ្រព្យម្ចាស់ និង

(ខ) ក្រុមហ៊ុនបុត្រសម្ព័ន្ធ ផ្តល់សិទ្ធិកាន់កាប់ឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនមេរបស់ខ្លួនទៅឱ្យនិយោជិតៈ ក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចផ្តល់ដល់និយោជិតនូវឧបករណ៍ទ្រព្យម្ចាស់

*ក្រុមហ៊ុនមេផ្តល់សិទ្ធិចំពោះឧបករណ៍ទ្រព្យម្ចាស់ដល់និយោជិតនៃក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន (កថាខ័ណ្ឌ ខ៥២ (ក))*

ខ៥៣ ក្រុមហ៊ុនបុត្រសម្ព័ន្ធ មិនមានកាតព្វកិច្ច ផ្តល់ឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនមេទៅឱ្យនិយោជិតរបស់ ក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ដូច្នេះ អនុលោម

តាមកថាខ័ណ្ឌ ៤៣ខ ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវវាស់វែងនូវសេវាកម្ម បានទទួលពីនិយោជិតស្របតាមលក្ខខណ្ឌតំរូវដែលប្រើប្រាស់ចំពោះប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដោយជំរះតាមទ្រព្យម្ចាស់ និងទទួលស្គាល់នូវការកើនឡើងនៃទ្រព្យម្ចាស់ជាការរួមចំណែកពីក្រុមហ៊ុនមេ។

១៥៤ ក្រុមហ៊ុនមេមានកាតព្វកិច្ច ដើម្បីទូទាត់ជំរះនូវប្រតិបត្តិការ ជាមួយនិយោជិត របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយផ្តល់នូវឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនខ្លួន។ ដូច្នេះ ស្របតាមកថាខ័ណ្ឌ ៤៣គ ក្រុមហ៊ុនមេត្រូវវាស់វែងកាតព្វកិច្ចនេះតាម លក្ខខ័ណ្ឌតំរូវ ដែលអាចប្រើប្រាស់ ចំពោះប្រតិបត្តិការទូទាត់ផ្អែកតាមភាគហ៊ុន ដោយជំរះតាមទ្រព្យម្ចាស់។

*ក្រុមហ៊ុនបុត្រសម្ព័ន្ធផ្តល់សិទ្ធិចំពោះឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនមេចំពោះនិយោជិតរបស់ខ្លួន (កថាខ័ណ្ឌ ១៥២ ខ(ខ))*

១៥៥ ដោយសារតែក្រុមហ៊ុនបុត្រសម្ព័ន្ធ មិនបានបំពេញនូវលក្ខខណ្ឌណាមួយនៃកថាខ័ណ្ឌ ៤៣ខ ដូចនេះ វាត្រូវកត់ត្រាចំពោះប្រតិបត្តិការជាមួយបុគ្គលិកជាការទូទាត់ជំរះជាសាច់ប្រាក់។ លក្ខខណ្ឌតំរូវប្រើប្រាស់មិនគិតពីរបៀបនៃការទទួលបានឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដើម្បីបំពេញកាតព្វកិច្ចចំពោះ បុគ្គលិកទេ។

## ការព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុនទាក់ទងនឹងការទូទាត់សងជាសាច់ប្រាក់ដល់និយោជិត

១៥៦ បញ្ហាទីបី គឺរបៀបដែលក្រុមហ៊ុនទទួលទំនិញ ឬសេវាកម្មពីអ្នកផ្គត់ផ្គង់ (រួមមាននិយោជិត) គួរត្រូវបានកត់ត្រាការព្រមព្រៀងទូទាត់ ផ្អែកតាមភាគហ៊ុនទាក់ទងនឹងការទូទាត់សងជាសាច់ប្រាក់ នៅពេលដែលក្រុមហ៊ុន

ខ្លួនឯងមិនមានកាតព្វកិច្ចដើម្បីធ្វើការទូទាត់សងដែលត្រូវការទៅកាន់អ្នកផ្គត់ផ្គង់របស់ខ្លួន។ ឧទាហរណ៍ ពិចារណានូវការព្រមព្រៀងខាងក្រោម ដែលក្រុមហ៊ុនមេ (មិនមែន ក្រុមហ៊ុនខ្លួនឯង) មានកាតព្វកិច្ចធ្វើការទូទាត់សងជាសាច់ប្រាក់ដែលតំរូវ ដល់និយោជិតនៃក្រុមហ៊ុនៈ

(ក) និយោជិតរនៃក្រុមហ៊ុននឹងទទួលការទូទាត់ជាសាច់ប្រាក់ ដែលបានទាក់ទងនឹងថ្លៃនៃឧបករណ៍ ទ្រព្យម្ចាស់របស់ក្រុមហ៊ុន

(ខ) និយោជិតនៃក្រុមហ៊ុននឹងទទួលនូវការទូទាត់ជាសាច់ប្រាក់ ដែលទាក់ទងនឹងថ្លៃនៃឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនមេ។

ខ៥៧ ក្រុមហ៊ុនបុត្រសម្ព័ន្ធ មិនមានកាតព្វកិច្ចទូទាត់ជំរះ ប្រតិបត្តិការជាមួយនិយោជិតរបស់ខ្លួននោះទេ ដូច្នេះ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវកត់ត្រាចំពោះប្រតិបត្តិការជាមួយនិយោជិតជាការជំរះនូវទ្រព្យម្ចាស់ ហើយទទួលស្គាល់នូវការកើនឡើងនៃទ្រព្យម្ចាស់ជាការរួមចំណែកពីក្រុមហ៊ុនមេ។ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវវាស់វែងថ្លៃដើមនៃប្រតិបត្តិការ ដែលកើតឡើងក្រោយការផ្លាស់ប្តូរ ដោយសារតែលក្ខខណ្ឌនៃការផ្ទេរមិនមែនទីផ្សារ មិនត្រូវបានបំពេញតាមកថាខ័ណ្ឌ ១៩-២១។ ភាពខុសគ្នាពីការវាស់វែងនៃប្រតិបត្តិការទូទាត់ជាសាច់ប្រាក់ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ក្រុមនៃក្រុមហ៊ុន។

ខ៥៨ ពីព្រោះក្រុមហ៊ុនមេមានកាតព្វកិច្ចដើម្បីទូទាត់ប្រតិបត្តិការជាមួយនិយោជិតនិងតំលៃតបស្នងជាមានសាច់ប្រាក់ ក្រុមហ៊ុនមេ (និងក្រុមរួម) ត្រូវវាស់វែងនូវកាតព្វកិច្ចរបស់ខ្លួនស្របតាមលក្ខខ័ណ្ឌដែលអាចអនុវត្តបាន ចំពោះប្រតិបត្តិការផ្អែកតាមភាគហ៊ុន ដែលទូទាត់ជាសាច់ប្រាក់ ដូចកថាខ័ណ្ឌ ៤៣គ។

## ការផ្ទេរនិយោជិតរវាងក្រុមនៃក្រុមហ៊ុន

១៥៩ បញ្ហាទី៤ទាក់ទងនឹងការព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុន ដែលពាក់ព័ន្ធនឹងនិយោជិតរបស់ក្រុមនៃក្រុមហ៊ុនលើសពីមួយ។ ឧទាហរណ៍ ក្រុមហ៊ុនមេមួយអាចផ្តល់ឱ្យនូវសិទ្ធិកាន់កាប់ឧបករណ៍ទ្រព្យម្ចាស់ ចំពោះនិយោជិតរបស់ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ដែលមានលក្ខខ័ណ្ឌអាស្រ័យតាមការបញ្ចប់នូវការ បំពេញសេវាកម្មជាមួយក្រុម ក្នុងរយៈពេលមួយជាក់លាក់។ និយោជិតនៃក្រុមហ៊ុនបុត្រសម្ព័ន្ធអាចផ្ទេរការងារពី ក្រុមហ៊ុនបុត្រសម្ព័ន្ធមួយទៅក្រុមហ៊ុនបុត្រសម្ព័ន្ធមួយទៀតក្នុងកំឡុងពេលនៃការផ្ទេរជាក់លាក់ ដោយនិយោជិតមិនមានសិទ្ធិកាន់កាប់ឧបករណ៍ទ្រព្យម្ចាស់នៃក្រុមហ៊ុនមេទៅតាមផលប៉ះពាល់នៃកិច្ច ព្រមព្រៀងទូទាត់ផ្អែកតាមភាគហ៊ុនដំបូង ។ ប្រសិនបើក្រុមហ៊ុនបុត្រសម្ព័ន្ធមិនមានកាតព្វកិច្ចដើម្បីទូទាត់នូវប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុន ជាមួយនិយោជិត ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវកត់ត្រាជាប្រតិបត្តិការទូទាត់ ជាទ្រព្យម្ចាស់។ ក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗ ត្រូវវាស់វែងសេវាកម្មបានទទួលពីនិយោជិតតាមតំលៃសមស្របនាថ្ងៃដែលសិទ្ធិកាន់កាប់លើឧបករណ៍ទ្រព្យម្ចាស់ត្រូវបានផ្តល់ឱ្យជាដំបូងដល់ក្រុមហ៊ុនមេ ដូចមានកំនត់ន័យ ក្នុងកថាខ័ណ្ឌ ក និងតាមសមាមាត្រនៃរយៈពេលផ្ទេរ ដែលនិយោជិត បានបំរើការក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗ។

១៦០ ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចទូទាត់ប្រតិបត្តិការជាមួយនិយោជិតជាឧបករណ៍ទ្រព្យម្ចាស់របស់ក្រុមហ៊ុនមេ ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវកត់ត្រាប្រតិបត្តិការទាំងនោះជាការទូទាត់ជាសាច់ប្រាក់។ ក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗ ត្រូវវាស់វែងសេវាកម្មបានទទួលតាមមូលដ្ឋាននៃតំលៃសមស្រប

របស់ឧបករណ៍ទ្រព្យម្ចាស់ នាថ្ងៃផ្តល់តាមសមាមាត្រនឹង រយៈពេលផ្ទេរដែលនិយោជិតបានបំរើការក្នុងក្រុមហ៊ុនបុត្រ សម្ព័ន្ធនីមួយៗ។ ជាបន្ថែមក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗ ត្រូវទទួលស្គាល់នូវការប្រែប្រួលណាមួយនៃតំលៃសមស្របរបស់ឧបករណ៍ទ្រព្យម្ចាស់ ក្នុងកំឡុងពេលនៃរយៈពេលនិយោជិត ធ្វើការក្នុងក្រុមហ៊ុនមេនីមួយៗ។

ខ៦១ ក្រោយពេលផ្ទេររវាងក្រុមនៃក្រុមហ៊ុន និយោជិតបែបនេះអាចនឹងមិនបានបំពេញតាមលក្ខខណ្ឌ នៃការផ្ទេរក្រៅពីលក្ខខណ្ឌទីផ្សារ ដូចមានកំណត់ន័យក្នុងឧបសម្ព័ន្ធក ឧ. និយោជិតចាកចេញពីក្រុមហ៊ុនមុនពេលបញ្ចប់រយៈពេលផ្តល់សេវា ក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗត្រូវកែតំរូវចំនួនដែលបានទទួលស្គាល់ពីមុនពាក់ព័ន្ធនឹងសេវាកម្មបានទទួលពិនិយោជិតស្របតាមគោលការណ៍ ក្នុងកថាខ័ណ្ឌ ១៩។ ដូច្នេះមិនមានចំនួននៃមូលដ្ឋានបូកបន្តនៃសេវាកម្មបានទទួលពីនិយោជិតនោះក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមនៃក្រុមហ៊ុនប្រសិនបើ សិទ្ធិកាន់កាប់ឧបករណ៍ទ្រព្យម្ចាស់ដែលបានផ្តល់ឱ្យដោយក្រុមហ៊ុនមេមិនបានផ្ទេរពីព្រោះតែនិយោជិតបរាជ័យក្នុងការបំពេញនូវលក្ខខណ្ឌនៃការផ្ទេរក្រៅពីលក្ខខ័ណ្ឌទីផ្សារ ។

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ